00877823

E1/157.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2013, 13:15
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៧នាទី**

**សវនាការលើកទី១៤៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវ៉ាស

(*Mr. Michael G. Karnavas)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

(*Ms. Christine MARTINEAU)*

លោកស្រី បេនី យេ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ស វិ (TCW-620) | ខ្មែរ |
| លោក អ៊ុំង រ៉ែន(TCW-754) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស ទិ** (TCW-620)

សួរបន្តដោយលោក អាកឡូវ វែកគែន ផ្ដើមពី៖..........ទំព័រ ៣

សួរដោយលោក អាង ឧត្តម ផ្ដើមពី៖..........ទំព័រ ១៥

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុំ រ៉ែន** (TCW-754)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖..........ទំព័រ ២០

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី៖..........ទំព័រ ២៤

សួរដោយលោក ខេល លីសាក់ ផ្ដើមពី៖..........ទំព័រ ៥១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៥៤]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស វិ បញ្ចប់ ហើយនឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-754 តាមកាលវិភាគដែលបានគ្រោងទុក។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមានលើកលែងតែលោក ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីឲ្យលោក អៀង សារី អវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ចំណែកឯជនជាប់ចោទ អៀង សារី និង នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនេះ ដោយមូលហេតុសុខភាព។

នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មសាក្សីលោក ស វិ ហើយលោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ចំណែកឯសាក្សីបន្ទាប់ ដែលអង្គជំនុំជម្រះនឹងកោះហៅមកផ្តល់សក្ខីកម្មគឺសាក្សីដែលមានរហស្សនាម TCW-754។ សាក្សីរូបនេះមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, អៀង សារី និងខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ ហើយគាត់បានធ្វើសម្បថនៅចំពោះមុខរូបសំណាកលោកតាដំបងដែកនៅព្រឹកមិញនេះរួចហើយ។

សាក្សីរូបនេះមិនមានមេធាវីប្រឹក្សានោះទេ។ សូមអរគុណ។

[០៩:០៩:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគី និងសាធារណជនជ្រាបផងដែរថា នៅព្រឹកមិញនេះតាមកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទលោក អៀង សារី មុនពេលសវនាការ ដោយលោកវេជ្ជបណ្ឌិតប្រចាំការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺលោក លឹម ស៊ីវុតថា បានពិនិត្យសុខភាពលោក អៀង សារី គាត់មានអាការៈអស់កម្លាំង វិលមុខ ហើយមិនអាចអង្គុយបាន។ លោកគ្រូពេទ្យបានផ្ដល់អនុសាសន៍ថា ប្រធានអង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោម។ ហើយបញ្ហានេះ គឺស្របទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះកន្លង ក៏ដូចជាកាលពីម្សិលមិញ អង្គជំនុំជម្រះបានពិនិត្យលទ្ធភាពនៃបញ្ហាសុខភាពរបស់គាត់ហ្នឹង គឺនៅប្រហាក់ប្រហែលកាលពីម្សិលមិញដែរ ហើយឲ្យគាត់ -- ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់មកចូលរួមកិច្ចដំណើរការសវនាការត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានពីចម្ងាយ។

[០៩:១១:១០]

ស្រដៀងនឹងនេះដែរ គឺនៅព្រឹកមិញនេះ អង្គជំនុំជម្រះក៏បានទទួលរបាយការណ៍ពីលោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា ដែលបានពិនិត្យសុខភាពលោក នួន ជា មុនពេលសវនាការនេះ និងបានកត់សម្គាល់ឃើញថា លោក នួន ជា មានបញ្ហាសុខភាព អស់កម្លាំងខ្លាំង វិលមុខ ពេលអង្គុយ ហើយមានសភាពទន់ដៃទន់ជើង ហើយគាត់មិនអាចអង្គុយបានយូរ។ អាស្រ័យហេតុនេះ លោកគ្រូពេទ្យបានផ្ដល់អនុសាសន៍ថា ប្រធានអង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យគាត់អាចចូលរួម -- ឲ្យគាត់ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោម។

ហើយពិតមែនតែលោក នួន ជា មានបញ្ហាសុខភាព តែគាត់អាចចូលរួមសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោម តាមអនុសាសន៍របស់លោកវេជ្ជបណ្ឌិត។ ហេតុដូច្នេះដើម្បីជៀសវាងការពន្យារពេលសវនាការ និងដើម្បីប្រយោជន៍យុត្តិធម៌ ដោយផ្អែកលើរបាយការណ៍របស់លោកវេជ្ជបណ្ឌិតប្រចាំការនៅ អ.វ.ត.ក អង្គជំនុំជម្រះបង្គាប់ឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដែលធ្វើសវនាការពេញ ១ថ្ងៃនេះ។

[០៩:១២:៣៦]

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទទាំងពីររូបអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញ១ថ្ងៃនេះ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**ស៖** ជម្រាបសួរលោកសាក្សី។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីសក្ខីកម្មដែលបានផ្តល់ជូនលោកកាលពីម្សិលមិញដោយខាងសហព្រះរាជអាជ្ញា ហើយសក្ខីកម្មនោះគឺជារបស់ តាសុត ឈ្មោះថា សុត (សូមទោស)។ គាត់ត្រូវបានស្តាប់ចម្លើយនៅឆ្នាំ២០០៨ ដោយអ្នកស៊ើបអង្កេតតុលាការ ហើយឥឡូវនេះគាត់បានទទួលមរណភាពទៅហើយ គឺមុនពេលដែលគាត់ស្លាប់នោះ សហព្រះរាជអាជ្ញា -- (សូមទោស) ខាងសហចៅក្រមស៊ើបអង្កេតបានស្តាប់ចម្លើយរបស់គាត់។

[០៩:១៣:៥៧]

ឥឡូវនេះខ្ញុំសូមលើកនូវឃ្លាមួយចំនួននៃសក្ខីកម្មរបស់គាត់ ពីព្រោះថាលោកផ្ទាល់នោះ ក៏លោកបាននិយាយអំពីលោក ថា សុត នេះដែរ។ ហើយគាត់ថា គាត់ជាអនុប្រធាន ក-១ ដែលស្ថិតនៅក្រោមបង្គាប់របស់ តាន។ ដូច្នេះខ្ញុំចង់សួរបញ្ជាក់លោក ថាតើលោកនៅតែរក្សាចម្លើយដែលថា តាសុត ហ្នឹងគឺជាអនុរបស់ តាន នៅ ក-១ តើអ៊ីចឹងមែនទេ?

**លោក ស វិ៖**

**ឆ៖** បាទ សុត នេះជាអនុប្រធាន ក-១ មែនបាទ។

**ស៖** ប្រសិនបើលោកនៅចាំនោះថា តើគាត់ជាអនុរបស់ តាន នោះរយៈពេលប៉ុន្មានដែរ? តើនៅពេលដែលវៀតណាមចូលមកភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ នោះ គាត់នៅតែធ្វើជាអនុប្រធានរបស់ តាន នេះដែរឬទេ?

**ឆ៖** បាទ សំណួរទី១ គាត់ -- រយៈពេលដែលធ្វើអនុប្រធានមន្ទីរ ក-១ គឺរយៈពេលពីឆ្នាំ

និយាយរួមត្រឹមឆ្នាំ៧៨ តាមខ្ញុំចាំ។ ហើយទី២ ក្នុងពេលដែលវៀតណាមចូលភ្នំពេញឆ្នាំ៧៩ ប៉ុល ពត និងក្រុមការពារទាំងអស់ដែលថយទៅរស់នៅភាគខាងលិចប្រទេស គឺសុត មិនបានជាអនុប្រធានទេ។ គាត់ត្រូវទទួលការពារជំនួស តាន ជាប្រធានតែម្តង។

[០៩:១៦:០៨]

**ស៖** ប្រសិនបើខ្ញុំ យល់មិនច្រឡំនោះទេ គឺថានៅឆ្នាំ១៩៧៩ សុត បានក្លាយទៅជាប្រធាន ក-១ ជំនួស តាន។ តើអ៊ីចឹងមែនទេ ចម្លើយរបស់លោកអម្បាញ់មិញនេះ?

**ឆ៖** បាទ ពីឆ្នាំ៧៩ទៅ យើងលែងមាន ក-១ ហើយ។ បាទ អង្គភាពទាំងមូលត្រូវរស់នៅកន្លែងមួយនៅភាគខាងលិចប្រទេស។ គឺយើងលែងឈ្មោះ ក-១ កប៉ុន្មានទៀតហើយ គឺពេលនោះគាត់ជាប្រធាន បាទ ដូចខ្ញុំបញ្ជាក់។

**ស៖** បាទ លោកសាក្សី។ ខ្ញុំយោងទៅសំណួររបស់ខ្ញុំមុន គឺថាមុនពេលវៀតណាមចូលមក គឺថាចុង៧៨ ឬក៏ដើមឆ្នាំ៧៩ សុត បានឡើងជំនួសតាន ជាប្រធាន ក-១ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់ទេ ព្រោះនៅក្នុង ក-១ នៅចុង៧៨ហ្នឹង សុត ជាអនុប្រធានទេ ដល់ដើម៧៩ ហ្នឹងក៏ជាអនុប្រធានដែរ មុនពេលដែលភៀសខ្លួនចេញពីភ្នំពេញ គាត់នៅជាអនុប្រធានដដែល។

**ស៖** បាទ សូមអរគុណ។ ជាដំបូង ខ្ញុំរៀបរាប់ពីចំណុចត្រួសៗ ដែល ថា សុត បានឆ្លើយនៅឆ្នាំ២០០៨ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គេបានសួរគាត់ថា តើគាត់ធ្វើអ្វីខ្លះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ? គាត់មិនដែលបញ្ជាក់ថា គាត់ជាប្រធាន ក-១ទេ។ គាត់ថា គាត់ជាប្រធានមន្ទីរ ក-១២ ដែលជាមន្ទីរទទួលខុសត្រូវអ្នកបើកបរឡាន ដែលស្ថិតនៅចន្លោះមន្ទីរពេទ្យព្រះសង្ឃ ហើយនិងផ្សារថ្មី។ គាត់ថា ចាប់ពីចុងឆ្នាំ៧៦ គាត់បានចាកចេញពីទីក្រុងភ្នំពេញ ហើយគាត់បានទៅដឹកនាំកងទ័ពមួយក្រុមនៅព្រំដែនជាមួយវៀតណាម។

[០៩:១៨:៤៣]

ហើយគាត់ស្ថិតនៅព្រំដែននោះ គាត់ឆ្លើយបញ្ជាក់ថា គាត់ជាមេបញ្ជាការកងទ័ពវៀតណាម នៅព្រំដែនវៀតណាមរហូតទៅដល់វៀតណាមចូល។ តើលោកយល់យ៉ាងណាដែរចំពោះចម្លើយរបស់ តា សុត នេះដែលគាត់ថា គាត់មិនមែននៅភ្នំពេញទេ គឺថាគាត់មិនទទួលខុសត្រូវ គាត់មិនអនុប្រធាន ក-១ នោះទេ គឺថាគាត់នៅព្រំដែនវៀតណាមឯណោះវិញទេ។ តើលោកមានយោបល់យ៉ាងណាដែរ ចំពោះចម្លើយរបស់គាត់នេះ?

**ឆ៖** ចន្លោះពីឆ្នាំ៧៦, ៧៧ ខ្ញុំអត់ក្តាប់ប្រវត្តិគាត់បានទេ មិនដឹងថាគាត់រស់នៅឯណា ធ្វើអី បាទ។ ហើយទើបតែឃើញគាត់ក្នុងមន្ទីរ ក-១ នេះនៅឆ្នាំ៧៨។ ប្រហែលជាពាក់កណ្តាលឆ្នាំ៧៨ ហើយក៏គាត់នេះមានតួនាទី ទន្ទឹមនឹងគាត់មានតួនាទីជាអង្គរក្សតាម តាឡន ជា ហូរហែ ជូនអ៊ំៗទៅតាមតំបន់ភូមិភាគនានាទូទាំងប្រទេសក៏ដោយ ក៏គាត់នៅមានតួនាទីចាត់ចែងជាមួយនឹង តាន នៅមន្ទីរ ក-១ រហូតដល់រត់វៀតណាមៗឆ្នាំ៧៩។ អ៊ីចឹងគាត់នៅ តែទទួលខុសត្រូវជាអនុប្រធានតាមខ្ញុំយល់ ព្រោះគាត់ជាអ្នកចាត់ចែងបន្ទាប់ពី តាន ដែល តាន មិននៅ ក្នុងចន្លោះពេលហ្នឹង បានពួកខ្ញុំទាំងអស់គ្នាសន្និដ្ឋានគាត់ថាជាអនុប្រធានមិនមែនជាប្រធានទេ។ ហើយគាត់ ទទួលការខុសត្រូវហ្នឹងរយៈពេលជិត១ឆ្នាំពេញ។ អ៊ីចឹងគាត់មិនអាចប្រកែកបានតែចន្លោះពីមុនដូចខ្ញុំបញ្ជាក់ជូនលោកអ៊ីចឹងគឺពី៧៥, ៧៦, ៧៧ នេះមិនដឹងជាគាត់រស់នៅកន្លែងណាធ្វើអីទេ។ តែចម្លើយ របស់គាត់បានប្រាប់ចៅក្រមស៊ើបអង្កេតជាហូរហែមកហ្នឹងជារឿងពិតជាក់ស្តែង ឬមិនពិតជាក់ស្តែង ខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់តែបញ្ជាក់ចន្លោះពេលប៉ុណ្ណឹងថាគាត់ទទួលខុសត្រូវបន្ទាប់ពី តាន នៅក-១ បាទសូម។

**ស៖** បាទសូមអរគុណលោកសាក្សីខ្លាំងណាស់ ដោយសារតែអ៊ីចឹងហើយបានខ្ញុំឲ្យលោកផ្តល់យោបល់ចំពោះចម្លើយខុសគ្នារវាងអ្វីដែលលោកឆ្លើយហើយនិងអ្វីដែលលោកសុត បានឆ្លើយនោះ។ ដូច្នេះលោកបញ្ជាក់ច្បាស់ហើយថាតាមអ្វីដែលលោកដឹង និងតាមការកត់សម្គាល់របស់លោកនោះ គឺចាប់ពីឆ្នាំ៧៧ មកតាសុត គាត់មានទីតាំងនៅភ្នំពេញ គាត់ធ្វើការនៅភ្នំពេញ គាត់មិនធ្វើការនៅព្រំដែនវៀតណាមដឹកនាំកងទ័ពនៅព្រំដែនវៀតណាមនោះទេ។ អ៊ីចឹងមែនទេ?

[០៩:២២:០០]

**ឆ៖** បាទខ្ញុំឃើញគាត់នៅឆ្នាំ៧៨ ទេ មិនមែនឆ្នាំ៧៧ទេ តែចម្លើយរបស់គាត់ អម្បាញ់មិញដូចឮថា ៧៧ តែខ្ញុំឃើញគាត់នៅចាត់ចែងជំនួសលោក តាន ម្តងៗនៅឆ្នាំ៧៨។

**ស៖** បាទសូមអរគុណលោកសាក្សី។ នៅក្នុងសក្ខីកម្មរបស់លោកនៅឆ្នាំ ២០០៥ ដែលលោកបាននិយាយអំពី តាន និង សុត នៅពេលដែលលោកលើកឡើងអំពីអំណាចរបស់ថ្នាក់លើរបស់លោកនោះ គឺលោកសំដៅដល់អ្នកទាំងពីរហ្នឹងគឺ តាន និង សុត។ ហើយនៅពេលមួយនោះ លោកបាននិយាយអំពីការស្លាប់ -- សុំទោសការចាប់ខ្លួន ប៉ង់។ លោកឆ្លើយទៅអ្នកស៊ើបអង្កេតតុលាការនៅថ្ងៃនោះថាតាមរយៈ តាន និង សុត នោះ លោកដឹងថាគេចាប់ខ្លួន ប៉ង់ ហើយគេចោទ ប៉ង់ ថាក្បត់។ តើលោកចាំថាលោក បានឆ្លើយចម្លើយបែបនេះជូនអ្នកស៊ើបអង្កេតតុលាការទេ? ហើយលោកនៅរក្សាចម្លើយនេះទេ?

**ផ៖** បាទ ខ្ញុំអត់ចោទថា តាន ឬ សុត ទៅចាប់ ប៉ង់ ទេ។ ខ្ញុំនៅចាំចម្លើយខ្ញុំបាន។ បាទអត់មានចោទថាពួកគាត់ទាំងពីរអ្នកនេះអ្នកទៅចាប់ ប៉ង់ ចោទថាក្បត់ទេ ខ្ញុំនិយាយថា--

[០៩:២៣:៣៥]

**សៈ** បាទ ខ្ញុំសុំឱ្យលោកឈប់សិន ខ្ញុំមិនមែនសួរលោកបែបនេះទេ ប្រហែលជាមានបញ្ហាបកប្រែសំណួររបស់ខ្ញុំ។ ខ្ញុំបានឆ្លើយថាលោក-- ខ្ញុំបានសួរលោកថា លោកបានឆ្លើយថាលោកដឹងពី តាន ហើយនិង សុត គឺមានន័យថាអ្នកទាំងពីរហ្នឹងបានប្រាប់លោកថា ប៉ង់ ត្រូវបានចាប់ខ្លួនហើយចោទថាជាជនក្បត់។ ខ្ញុំមិនបាននិយាយថា តាន និងសុត ហ្នឹងជាអ្នកចោទ ជាអ្នកចាប់ ប៉ង់ ទេ គឺថាលោកដឹងតាមរយៈ ប៉ង់ -- តាមរយៈ តាន ហើយនិង សុត ថាប៉ង់ ត្រូវបានគេចាប់ខ្លួន។ នេះគឺជាសំណួររបស់ខ្ញុំ តើលោក នៅរក្សាចម្លើយបែបនេះទេ?

**ផ៖** បាទ ខ្ញុំនៅរក្សាចម្លើយបែបនេះគឺតាន បាននិយាយប្រាប់តែមិនមែនប្រជុំប្រកាសថា ប៉ង់ ក្បត់នោះទេ តែជាហូរហែគាត់ធ្លាប់និយាយខ្ញុំឮថាប៉ង់ក្បត់ហើយ។ បាទអាហ្នឹងក្រោយដែលគេចាប់គាត់បាត់ពីរបីខែមកហើយនោះ ដែលគាត់និយាយជាហូរហែរួមទាំង សុត រួមទាំង តាន និងយុទ្ធជនឯទៀតនោះនិយាយតគ្នាពេញអ៊ីចឹង។ ហាក់ដូចថាប្រកាសដែលព្រោះនិយាយមិនជាក្របខ័ណ្ឌជួបជុំអីទេ គ្រាន់តែនិយាយតៗ អ៊ីចឹងថា ប៉ង់ ក្បត់។ បាទ អាហ្នឹង ខ្ញុំនៅរក្សាចម្លើយហ្នឹង ព្រោះគាត់ធ្លាប់និយាយប្រាប់យើងខ្ញុំទាំងអស់គ្នា បាទ។

**សៈ** ដូច្នេះ ដោយសារតែ សុត ហើយនិង តាន នោះ គាត់បានដឹង ដូច្នេះ គាត់ក៏បាននិយាយអំពីការចាប់ខ្លួន ប៉ង់ ដែលគេចោទ ប៉ង់ នោះ ថាក្បត់។ អ៊ីចឹងមែនទេ ចម្លើយរបស់លោកនោះ?

**ផ៖** បាទ ចម្លើយរបស់ខ្ញុំអ៊ីចឹងមែន ព្រោះគាត់មកនិយាយមែន ក្នុងអង្គភាពទាំងមូល គាត់និយាយថា “ប៉ង់ ក្បត់ ត្រូវគេចាប់ខ្លួន” បាទ។

[០៩:២៥:៥៣]

**សៈ** ឥឡូវនេះ ខ្ញុំចង់បានចម្លើយរបស់លោក ដោយអាននូវចម្លើយរបស់ ថា សុត ដែលគេបានស្តាប់ចម្លើយនៅឆ្នាំ២០០៨ ពាក់ព័ន្ធទៅនឹងបញ្ហានេះ។ គឺឯកសារ E3/164 ERN ជាភាសាបារាំង 00503947, ERN ជាភាសាខ្មែរ 00204741, ភាសាអង់គ្លេស 00226109។ ខ្ញុំសូមដកស្រង់ “ថ្ងៃមួយ អ្នកបើកបររបស់ ប៉ង់ បានប្រាប់ខ្ញុំថា ប៉ង់ ស្លាប់ហើយ ដែលត្រូវបានគេសម្លាប់ បាញ់សម្លាប់នៅពេលដែលគាត់ទៅយកទំនិញ ហើយនៅពេលនោះ គឺកំពង់ផែកំពង់សោម។ គាត់ស្លាប់គឺថានៅចន្លោះ

ស្រែអំបិល ហើយនិងវាលរេញ"។ បាទ ដូច្នេះលោកឆ្លើយ -- លោកមានយោបល់យ៉ាងអំពីការ ពីចម្លើយរបស់ តាសុត ដែលគាត់ថា "ប៉ង់ នោះ ត្រូវស្លាប់ដោយសារចោរព្រៃបាញ់ នៅពេលដែលទៅទទួលទំនិញនោះ"?

**ឆ៖** បាទ ខ្ញុំអត់ប៉ានឆ្លើយ ហើយក៏អត់ប៉ានសន្និដ្ឋានដែរ រឿងនេះ ពីព្រោះខ្ញុំអត់បានជ្រាបអីទាល់តែសោះ ពីបញ្ហារឿងនេះ កាលខ្ញុំអង្គរក្សនៅ ក-១ នេះ អត់បានជ្រាបពី ដូចលោកបានមានសំណួរសួរខ្ញុំអំមិញទេ អត់ដឹងទាល់តែសោះ អត់ដឹងទេ។ ការស្លាប់ ប៉ង់ មូលហេតុអីស្លាប់ គឺខ្ញុំអត់យល់ អត់ជ្រាប ទើបតែឮអម្បាញ់មិញនេះ ទើបតែលោកសួរអំមិញហ្នឹង បានខ្ញុំដឹងថា មានករណីហ្នឹង កើត។ កាលពីមុន ខ្ញុំអត់ដឹងទេលោក អត់ដឹងទាល់តែសោះ។

[០៩:២៨:២៤]

**ស៖** បើខ្ញុំមិនសួរជជីកអ្វីច្រើនអំពីបញ្ហា ប៉ង់ នេះទេ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីចំណុចមួយ ដែលកាលពីម្សិលមិញនេះ គេបានសួរលោកពាក់ព័ន្ធទៅនឹងឡានដែលលោក ខៀវ សំផន ប្រើប្រាស់ ហើយគាត់ -- ហើយលោកឆ្លើយថា "ជាឡានធម្មតា ដូចដែលមេដឹកនាំផ្សេងៗទៀតប្រើប្រាស់ដែរ"។ ដូច្នេះ ខ្ញុំចង់សួរលោកអំពីសុវត្ថិភាព -- អំពីសន្តិសុខរបស់គាត់នោះ។ លោកឆ្លើយពីម្សិលមិញថា "លោក ខៀវ សំផន ធ្វើដំណើរទៅណាមកណា នៅក្នុងទីក្រុងភ្នំពេញនោះ គឺមានអ្នកបើកឡានរបស់គាត់" ហើយចុះមេដឹកនាំផ្សេងទៀត តើមានអង្គរក្សជុំវិញខ្លួនដែរឬទេ? តើមានភាពខុសគ្នាដែរឬទេ រវាងលោក ខៀវ សំផន ហើយនិងមេដឹកនាំផ្សេងទៀតនោះ ពេលអ្នកផ្សេងទៀតទៅណា មកណានោះ មានអង្គរក្សហែហមអីទេ?

[០៩:២៩:៣៦]

**ឆ៖** បាទ បញ្ហាឡានលោក ខៀវ សំផន គឺខ្ញុំបាននិយាយម្សិលមិញ ដែលខ្ញុំក៏នឹកឃើញដែរ គឺឡានឡាំប្រីតា ដែលគាត់ជិះជាប្រចាំនៅទីក្រុងភ្នំពេញ ចេញចូលមក ក-១ ជាប់។ ឃើញជិះឡានឡាំប្រីតាហ្នឹងមែន ពិតជាក់ស្តែង។ ឯអ្នកតាមនោះ គ្មានអ្នកតាមការពារ គាត់អត់ដែល មានតែតៃកុងឡានទេ។ នេះខ្ញុំឃើញជាក់ស្តែងគឺអ៊ីចឹង ចេញចូលនៅ ក-១ ដែលខ្ញុំប្រទះឃើញ ក្នុងពេលដែលខ្ញុំផ្លាស់គេទៅយាមម្តងៗខ្ញុំឃើញគាត់ គាត់ជិះឡានហ្នឹង។ ហើយចេញចូលហ្នឹងតែពីរនាក់តៃកុងឡានហ្នឹងជាអង្គរក្សហើយ ការពារផង បើកឡានផង។ បញ្ហាពីរ បើប្រៀបធៀបទៅនឹងអ្នកដឹកនាំផ្សេងទៀត ដូចជា អ៊ំ នួន ជា, អ៊ំ អៀង សារី និង ប៉ុល ពត គឺយ៉ាងហោចណាស់បើមិនមានឡានមុខក្រោយក៏ក្នុង

ឡានហ្នឹងក៏មានពីរនាក់ បីនាក់នឹងតែកុងដែរ។ នេះតាមខ្ញុំឃើញ។ អ៊ីចឹងភាពខុសគ្នានៅត្រង់ហ្នឹង។

**ស៖** ខ្ញុំចង់ឲ្យលោកឆ្លើយឲ្យបានលម្អិតបន្តិចពីរបៀបដែលគាត់ទៅ ក-១។ នៅពេលគេសួរលោកនៅឆ្នាំ២០០៥នោះ លោកបានរៀបរាប់អំពីស្ថានភាពនៅ ក-១ នោះថាមានបីជាន់។ ជាន់នៅ -- នៅបរិវេណនោះគឺថា មានចម្ងាយពីរគីឡូម៉ែត្រពីអគារនោះ ហើយលោកថា មានអ្នកយាមជាច្រើនប្រហែលជាជាង១០០នាក់។ ហើយបន្ទាប់មកនៅជាន់ទី២ ជាជាន់ដែលលោកធ្វើការនោះ គឺថាមានបរិវេណមួយ ហើយនៅក្នុងជាន់ហ្នឹងគឺថាមានអ្នកយាមប្រហែលជា៥០, ៦០នាក់។ បន្ទាប់មកមានជាន់មួយទៀត ដែលស្ថិតនៅក្នុងបរិវេណដែលលោកយាមនោះ មានអ្នកទទួលខុសត្រូវប្រហែលជា១០នាក់ជាងខាងសន្តិសុខផ្ទាល់នោះ។ តើលោកនៅរក្សាចម្លើយ ដូចដែលអ្វីដែលខ្ញុំបានរៀបរាប់អម្បាញ់មិញនេះទេ?

[០៩:៣២:៣៥]

**ឆ៖** បាទ ខ្ញុំនៅរក្សាចម្លើយហ្នឹង។ ជាន់ទី៣ តាមពិតខ្ញុំប៉ាន់ខុស ប៉ុន្តែចម្ងាយពី ក-១ ទៅប្រហែលជាមួយគីឡូ ទៅពីរគីឡូ អស់ច្រើន។ ប៉ុន្តែខ្ញុំវៃស្មានអង្កាល់ចៅក្រមទៅសួរខ្ញុំហ្នឹង គឺពីរទៅបីគីឡូ តែវាមិនខុសគ្នាទេ ក្នុងស្ថិតតែពីរ ឬបី មួយឬពីរតែប៉ុណ្ណឹង។ ហ្នឹងបញ្ហាមួយ។ ហើយពីរទៀតក្រុមនោះ តាមការស្មានទេ គឺមានគ្នាប្រហែលមួយវរសេនាតូច ព្រោះឃើញទ្រង់ទ្រាយដែលក្រុមនោះយាមកាមមានទ្រង់ទ្រាយធំ គ្រប់ច្រកល្ហកផ្លូវតូចផ្លូវធំ។ ហើយហ្នឹងបញ្ហាមួយ។ បញ្ហាពីរទៀតចំពោះជាន់ទី២ ខ្ញុំមិនបាននៅជាន់ទី១ទេ ខ្ញុំនៅជាន់ទី២។ ជាន់ទី២ ប្រហែលមានគ្នា៥០, ៦០នាក់ រួមទាំងអ្នកការពារយាមកាមយប់ព្រលប់ ទាំងអ្នករស់នៅក្នុងមន្ទីរ ក-១ ហ្នឹងប្រហែលមានគ្នាប៉ុណ្ណឹងមែនខាងជាន់ទី២ហ្នឹងគឺ៥០, ៦០នាក់។ នេះខ្ញុំទទួលស្គាល់ នៅរក្សាចម្លើយរបស់ខ្ញុំ។ ហើយបញ្ហាជាន់ទី១ មានគ្នាពី១០ទៅ១០នាក់ជាង ក៏តាមការប៉ាន់ស្មានដែរ ខ្ញុំមិនមែនរាប់ទុក កត់ត្រាទេ គឺការប៉ាន់ស្មានប្រហែលចន្លោះហ្នឹង ខ្ញុំសន្និដ្ឋានថាត្រូវ ទោះបីដល់២០ក៏ដោយ។ អ៊ីចឹងខ្ញុំនៅតែកំណត់ថា គឺការចងចាំរបស់ខ្ញុំហ្នឹងគឺក៏ជាការត្រឹមត្រូវដែរ។

[០៩:៣៤:៣២]

**ស៖** បាទសូមអរគុណ។ នៅពេលដែលមាននរណាម្នាក់ចង់ចូលទៅ ក-១ តើគេៗត្រួតពិនិត្យអ្នកនុំងនៅជាន់ណា ពេលទៅដល់នុំង ជាន់ណាដែលគេសុំអត្តសញ្ញាណ គេត្រួតពិនិត្យ គេឆែកឡាន ឬក៏គេសួរថា ទៅកន្លែងណា ចូលទៅ ក-១ ចង់ទៅណាទៅណើអីអ៊ីចឹង? អ៊ីចឹងគឺនៅពេលដែលមានអ្នកណា

ចង់ចូល តើគេត្រួតពិនិត្យគាត់នៅចំណុចណាមួយ?

**ឆ៖** នៅជាន់ទី៣ ខ្ញុំអត់ដឹងថាគេបានត្រួតពិនិត្យឡាន ឬការចេញចូលដែលអ្នកចង់ទៅចូលនៅ ក-១ នោះទេ។ ខ្ញុំអត់ដឹង តែមកដល់ជាន់ទី២ គឺអត់បានត្រួតពិនិត្យទេ។ បាទ អត់មានបានត្រួតពិនិត្យទេ គឺចូលតែម្តង។ បាទ ចូលតែម្តង។

**ស៖** ហើយដើម្បីឆ្លងកាត់បរិវេណរបស់លោកនោះ តើមានត្រូវបើកទ្វារ គេមានបើកទ្វារ បិទទ្វារ ឬក៏ឡានអាចចេញចូលទៅសេរីតែម្តង?

**ឆ៖** បាទ បើក និងបិទជាប្រចាំ អត់មានចេញចូលតាមសេរីទេ។

[០៩:៣៦:៣២]

**ស៖** ហើយនៅពេលដែលលោកបិទបើកទ្វារ លោកមានសួរអ្នកចូលទៅ ក-១ ហ្នឹងទេថាចង់ចូលទៅណា? ចង់ទៅកន្លែងណា? ហើយទៅជួបអ្នកណាអីអ្នកណា? មានលោកមានសួរទេ តើការ -- ភារកិច្ចហ្នឹងជាភារកិច្ចរបស់លោកទេ?

**ឆ៖** ក្រៅពីអ្នកសំខាន់ៗ គឺអត់មាននរណាចេញចូលទេ ទីកន្លែងនោះ។ អ៊ីចឹងអ្នកដែលសំខាន់ទាំងនោះ យើងអត់ប៉ានសួរទេ។ បាទ អត់ប៉ានសួរទេ។

**ស៖** សូមអរគុណ។ លោកបានរៀបរាប់អំពីអគារនៅ ក-១ នោះគឺមានប្រហែលប្រាំប្រាំមួយជាន់ តើលោកអាចប្រាប់បានទេ គឺថាតើនៅក្នុង ក-១ ហ្នឹងមានចំនួនការិយាល័យ ឬក៏មន្ទីរប៉ុន្មាន? ហើយមានមនុស្សប៉ុន្មាននាក់ដែរ ដែលធ្វើការនៅក្នុងមន្ទីរទាំងអស់នុ៎ងនៅជាប្រចាំថ្ងៃនោះ នៅក្នុងមន្ទីរ ក-១ នោះ? ថាតើប្រហែលជាមានមនុស្សប៉ុន្មានដែរ ដែលមានធ្វើការនៅមន្ទីរក-១ ដែលមានប្រាំប្រាំមួយជាន់នុ៎ង?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបខាងដើមជាហូរហែមក ក្នុងមន្ទីរ ក-១ យើងរាប់ថាមន្ទីរ ក-១ នេះគឺមានតែជាន់ទី១ ហើយនិងទី២ ទេ។ អ៊ីចឹងមនុស្សធ្វើការនៅជាន់ទី១នោះ មានប្រហែល១០នាក់ជាងហ្នឹងគឺមានគ្រប់ផ្នែកទាំងអស់ មានទាំងអ្នកដាំបាយនៅទីហ្នឹង មានទាំងអ្នកនាំបន្លែ ក៏ចូលក្នុងហ្នឹង មានទាំងអ្នកសម្អាតបោសច្រាស កាត់ស្មៅ បាញ់ស្មៅ ថែដើមឈើក៏នៅក្នុងហ្នឹង មានអ្នកការពារក៏នៅក្នុងហ្នឹង។ ប៉ុន្តែសរុបទៅអ្នកអស់ហ្នឹងគឺសុទ្ធតែអ្នកការពារទាំងអស់ ទោះបីការងារថ្ងៃគាត់មានការងាររៀងៗខ្លួនក៏ដោយក៏ក្នុងឋានៈការពារអ្នក១០នាក់ជាង ទៅ២០នាក់ហ្នឹង។

[០៩:៣៩:០០]

បញ្ហាពីរ នៅជាន់ទី២ ក៏របៀបហ្នឹងដែរ។ បាទ មានទាំងអ្នកដាំបាយ មានទាំងអ្នកបង្កបង្កើនផល ចិញ្ចឹមជ្រូក ចិញ្ចឹមគោ មានទាំងអ្នកការពារ ៥០-៦០នាក់ហ្នឹង។ អ៊ីចឹងសរុបទៅអ្នកទាំងអស់គ្នាក៏ជាអង្គរក្ស ជាទាហានអង្គរក្ស។ អ៊ីចឹង ខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង។

**ស៖** ដូច្នេះមានន័យថា លោកមិនអាចរាប់ពីចំនួនមនុស្សដែលធ្វើការនៅកន្លែងនុ៎ងបានទេ ខ្ញុំដូចជាមិនយល់ពីចម្លើយរបស់លោកនោះ។ ខ្ញុំអត់ឮលោកនិយាយអំពីចំនួន លោកអាចប៉ាន់ស្មានបានទេ ប្រហែលជាមានមនុស្សប៉ុន្មាននាក់ធ្វើការនៅកន្លែងនុ៎ង? លោកមិនចាំបាច់ឆ្លើយទេ ប្រសិនបើលោកមិនដឹង បើលោកមិនដឹង លោកឆ្លើយថាមិនដឹងទៅ មិនមានការចាប់បង្ខំឲ្យលោកឆ្លើយអ្វីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៥០:២៦]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់។ សាក្សីមិនបានផ្តល់តួលេខនេះទេ ប៉ុន្តែមេធាវីការពារក្តីគឺថាកំពុងតែធ្វើការជជីកសួរទៅលើសាក្សីត្រង់ចំណុចនេះ។ ខ្ញុំសូមជំទាស់ត្រង់ចំណុចនេះ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ប្រហែលជាគាត់យល់មិន -- ស្តាប់មិនបានទូវសំណួររបស់ខ្ញុំបានជាគាត់ជំទាស់នោះ។ ពីព្រោះថាខ្ញុំគ្រាន់តែសួរបញ្ជាក់ ព្រោះថាចម្លើយរបស់សាក្សីគាត់មិនសូវច្បាស់ ខ្ញុំសួររបៀបអព្យាក្រឹតទេ ខ្ញុំមិនបានបង្ខំឲ្យគាត់ឆ្លើយទេ គាត់អាចឆ្លើយយ៉ាងម៉េចក៏បាន។ គាត់ដឹង គាត់ឆ្លើយថាគាត់មិនដឹង គឺសំណួរខ្ញុំគឺបើកទូលាយតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្តី!

**លោក ស រិះ**

**ឆ៖** បាទ អម្បាញ់មិញគាត់សួរខ្ញុំ ពីបញ្ហាមនុស្សដែលរស់នៅក្នុងមន្ទីរ ក-១ បាទ តើធ្វើអីខ្លះ? អ៊ីចឹងខ្ញុំបានរៀបរាប់ជូន ឆ្លើយតបនឹងសំណួរវិញអ៊ីចឹងថា វាមាន ដូចនៅជាន់ទី១ វាមានអ្នកដាំបន្លែ -- វាមានអ្នកដាំបាយ មានអ្នកកាប់ស្មៅ--

**ប្រធានអង្គជំនុំ៖**

សំណួរហ្នឹងឆ្លើយរួចហើយ។ តើមានចំនួនប្រហែលប៉ុន្មាននាក់? លោកអាចប៉ាន់ស្មានដឹងទេ?

**លោក ស វិ៖**

**ឆ៖** បាទ ចំនួននៅខាងក្នុងមន្ទីរក្នុងជាន់ទី១ ហ្នឹងគឺមានប្រហែល១០នាក់ជាង តាមការប៉ាន់ស្មានបាទ ហើយនៅជាន់ទី២ គឺមានពី៥០-៦០នាក់តែប៉ុណ្ណឹង។ ខ្ញុំបានឆ្លើយជាហូរហែបន្តបន្ទាប់ គឺនៅចាំសំណួរខ្ញុំ នៅចាំចម្លើយខ្ញុំតែប៉ុណ្ណឹង។

[០៩:៤២:៣៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបន្តសំណួរថ្មីទៀត ប្រសិនបើនៅមាន។

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកបាននិយាយពីជាន់ទី១ ជាន់ទី២ ហើយចុះនៅខាងជាន់លើៗទៀតនោះ តើមានមនុស្សធ្វើការប្រហែលប៉ុន្មាននាក់ដែរ?

**លោក ស វិ៖**

**ឆ៖** បាទ ខ្ញុំអត់យល់ ជាន់លើៗ ចង់និយាយថាជាន់ទី៣អ៊ីចឹងទៅ ខ្ញុំស្រួលឆ្លើយ។ ជាន់ទី៣ មានប្រហែលមួយវរសេនាតូច គិតមនុស្សប្រហែលជា១០០នាក់ តាមការប៉ាន់ស្មាន។

[០៩:៤៣:១៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាច -- សួរយូរហើយបញ្ហាហ្នឹង ប្រហែលជាទំនងអាចភ័ន្តច្រឡំរវាងជាន់ទី១, ជាន់ទី២ ទៅជាន់ទី៣។ ហើយមួយទៀតគឺនែ៎ រង្វង់នេះ អារង្វង់ចំណុចនេះ គឺចំណុចដែលត្រូវការពារការពារអាជាន់ទី៣នេះ នែ៎ជាន់ទី២នេះ ហើយជាន់ទី១គឺផ្ទាល់ ការពារក្នុងរង្វង់នៃការិយាល័យ ក-១។ សួរយូរហើយបញ្ហានេះហ្នឹង ដូចជាអាចយល់ច្រឡំគ្នារវាងជាន់ទៅលើ ឬក៏ជាន់នៅជុំវិញនៃបរិវេណដែលត្រូវការពារ។ ជាន់ផ្ទាល់, ជាន់ទី១, ជាន់ទី២បន្ទាប់ ហើយជាន់ទី៣ គឺចម្ងាយប្រហែល១គីឡូ។

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំយល់ហើយចំពោះការពន្យល់របស់លោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី គឺថាលោកអាចឆ្លើយក៏បាន លោកមិនឆ្លើយក៏បាន បើលោកមិនដឹងលោកឆ្លើយថាមិនដឹងទៅ។ ខ្ញុំគ្រាន់តែព្យាយាមចង់ដឹងថា បើយើងដកមនុស្សដែលធ្វើការខាងសន្តិសុខចេញ យើងមិនគិតពីអង្គរក្ស មិនគិតពីអ្នកដែលយាមកាមនៅជាន់៣ -- បីតង់ហ្នឹងទេ។ ខ្ញុំចង់ដឹងថា នៅក្នុងមន្ទីរ ក-១ តែម្តង នៅអគារដែលធ្វើការនោះ ថាតើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅក្នុងអគារ ក-១ នុ៎ង? ខ្ញុំមិននិយាយអំពីជាន់ៗខាងក្រៅដែលយើងយាមនោះទេ យើងអត់គិតពីភ្នាក់ -- ពីក្រុមសន្តិសុខដែលធ្វើការនោះទេ ចង់សំដៅដល់អ្នកដែលធ្វើការនៅក្នុងការិយាល័យ គឺថានៅក្នុងមន្ទីរ ក តែម្តង ក-១ ហ្នឹង តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំទើបតែយល់អំមិញ។ គឺខ្ញុំអត់ដឹងទេ រឿងហ្នឹង។

[០៩:៤៥:៣១]

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីចំណុចលម្អិតមួយ ដែលខ្ញុំមានការចាត់អារម្មណ៍ គឺខ្ញុំនិយាយអំពីចំនួននៃការជួប គឺថាលោកបានជួបជាមួយអ្នកស៊ើបអង្កេតនុ៎ង -- តុលាការហ្នឹងប៉ុន្មានដង? ខ្ញុំចង់ដឹងឱ្យបានច្បាស់។ យើងមានកំណត់ហេតុដែលចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧។ កាលម្សិលមិញនៅពេលដែលលោកចាប់ផ្តើមឆ្លើយនោះ លោកប្រធានសួរថា លោកបានជួបអ្នកស៊ើបអង្កេតប៉ុន្មានដង? លោកឆ្លើយថា លោកបានជួបតែម្តងទេ។ ខ្ញុំចង់ប្រាប់ឱ្យលោកដឹងថា នៅពេលដែលអ្នកស៊ើបអង្កេតតុលាការបានសួរលោកនោះ លោកមានការពិភាក្សានោះ ហើយមានការថតជាសំឡេង។ តើលោកមាននៅចាំទេថា ពេលដែលគេសួរលោកនោះ ហើយលោកឆ្លើយនោះ គេបានថតសំឡេងលោក?

**ឆ៖** បាទ បញ្ហាដែលចៅក្រមទៅជួបខ្ញុំសម្ភាស។ គាត់ថតជាសំឡេង គាត់ប្រាប់ខ្ញុំថា ថតជាសំឡេង បាទថតជាសំឡេង។ ខ្ញុំអត់ដឹងទេ គាត់ប្រាប់អ៊ីចឹង។

[០៩:៤៧:១៩]

**ស៖** បាទ សូមអរគុណ។ ហើយការសម្ភាសនោះធ្វើឡើងតែមួយថ្ងៃទេ ឬក៏ធ្វើឡើងក្នុងរយៈពេលច្រើនថ្ងៃ?

**ឆ៖** អត់សូវឮ ឮរាងរអាក់រអួល។ អត់ឮសំណួរទេ។

**ស៖** ខ្ញុំសួរសំណួរនេះឡើងវិញ។ កិច្ចសម្ភាសន៍ដែលលោកបានចុះហត្ថលេខានោះ គឺនៅថ្ងៃទី ០៥ធ្នូ ឆ្នាំ២០០៧ គឺបើមើលទៅគឺតែមួយថ្ងៃទេ តើលោកមាននៅចាំទេថា លោកបានជួបអ្នកស៊ើបអង្កេតតុលាការមុនថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ដែរឬទេ? ឧទាហរណ៍មុនហ្នឹងមួយថ្ងៃនោះ លោកមានបានជួបពួកគេទេ?

**ឆ៖** បាទ ខ្ញុំឃើញថា មានជាហូរហែ ប៉ុន្តែមិនដឹងផ្នែកអីៗ ខ្ញុំអត់បានចាំទេ។ គេទៅរកខ្ញុំជាហូរហែ មិនដឹងថាជាអ្នកស៊ើបអង្កេតតុលាការក្តីហ្នឹងទេគេទៅរកខ្ញុំនោះ គឺគេទៅរកជាហូរហែមកហើយ។ ខ្ញុំអត់ចាំ។ តែថ្ងៃទី០៥ ខែធ្នូ ២០០៧ហ្នឹង មានមួយក្រុមគឺគាត់ខាងស៊ើបអង្កេតសាលាក្តីហ្នឹងគាត់ទៅសម្ភាសខ្ញុំ បាទសម្ភាសតែមួយថ្ងៃទេ។ បាទ សូមបញ្ជាក់។

[០៩:៤៩:០៧]

**ស៖** បាទសូមអរគុណ។ ខ្ញុំគិតថា លោកនឹងយល់ហេតុអីបានខ្ញុំសួរសំណួរបែបនេះ។ ពីព្រោះថាខ្ញុំបានស្តាប់ខ្សែអាត់ស្តាប់សំឡេង -- ខ្សែអាត់សំឡេងដែលលោកបានឆ្លើយជាមួយនឹងលោក ចាយ ច័ន្ទតារាវណ្ណ ហើយនិងលោក ស្ទីវហ្វិន ហេដឌ័រ ដែលជាអ្នកស៊ើបអង្កេតរបស់តុលាការ ដែលទទួលបន្ទុកក្នុងការសួរសំណួរលោកនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧នោះ។ ហើយខ្ញុំបានស្នើសុំឲ្យមានការបកប្រែផ្នែកនោះជាភាសាបារាំង ដែលយើងមានលេខកូដ D91/9.1 ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំង 00876649-50, ជាភាសាខ្មែរ 00875837-38, ជាភាសាអង់គ្លេស 00876646-48 នៅពេលដែលយើងអាននៅក្នុងខ្សែអាត់នោះគឺថាមិនមាននៅក្នុង កំណត់ហេតុទេ ហើយនៅពេលនោះ គឺថាលោកស្តេហ្វិននោះគឺថាបាននិយាយដូចតទៅនេះ បាទ ខ្ញុំសូម ដកស្រង់ “ហើយចុះឈ្មោះ ចន ដែលយើងនិយាយកាលពីម្សិលមិញនេះ -- បាទសុំទោសគឺឈ្មោះ ធួន គាត់សួរថា ចុះធួនដែលយើងសួរកាល -- ដែលយើងនិយាយពីម្សិលមិញនេះ ដូច្នេះខ្ញុំចង់ដឹងថា អ៊ីចឹងមុនថ្ងៃទី០៥ហ្នឹង លោកមានបានជួបលោកស្តេហ្វិន ហេដ័រ ហ្នឹងទេ? តើលោកចាំទេ ថាមានបានជួបពួកគាត់នៅមុនថ្ងៃទី០៥នោះ ហើយបានពិភាក្សាគ្នា បាននិយាយអំពីឈ្មោះ ទន ហើយនិង ឈ្មោះធួន នេះតើលោកចាំទេ?

**ឆ៖** បាទខ្ញុំភ្លេចៗ មុនថ្ងៃទី០៥ ហ្នឹងវាមានគេទៅជាហូរហែតែខ្ញុំភ្លេចមិនដឹងជាឈ្មោះគាត់ឈ្មោះអីៗភ្លេចទៅស្រាប់តែដល់ថ្ងៃទី០៧ គេចាប់ផ្តើមសម្ភាសខ្ញុំតែម្តង តែខ្ញុំជឿថាប្រហែលជាពួកគាត់ហ្នឹងហើយ តែខ្ញុំវាភ្លេចទៅកន្លែងហ្នឹង។

[០៩:៥២:០០]

**ស៖** ឥឡូវយើងកុំនិយាយអំពីថ្ងៃ។ លោកបាននិយាយថា បានជួបពីរដង ហើយនៅជួបលើកទីមួយ ឬក៏លើកទីពីរដែលលោកចុះហត្ថលេខាលើកំណត់ហេតុនោះ?

**ឆ៖** បាទមុនថ្ងៃចុះហត្ថលេខាលើកំណត់ហេតុហ្នឹងគឺខ្ញុំដឹងថា ជួបជាហូរហែមិនដឹងជាប៉ុន្មានលើកព្រោះគេទៅច្រើនសាណាស់ទៅផ្ទះខ្ញុំតែមុនថ្ងៃទី០៥ៗ ហ្នឹងវាមានមក តែខ្ញុំមិនចាំថ្ងៃហើយក៏មិនចាំមុខពួកគាត់ដែរ ចាំឈ្មោះពួកគាត់ដែរ តែខ្ញុំដឹងថា គឺក្រុមគាត់ហ្នឹងហើយដែលអ្នកត្រូវមកមុនថ្ងៃទី ៥ មកសម្ភាសខ្ញុំនោះ តែមិនដឹងថាប៉ុន្មានលើកៗទេលោកប្រធាន ខ្ញុំភ្លេចទៅកន្លែងហ្នឹង។

**ស៖** បាទ សូមអរគុណ។ ហើយនៅក្នុងពេលជួបមុននោះតើលោកមានបានពិភាក្សាគ្នាអំពីអង្គហេតុ ឬក៏រឿងហេតុដែលកើតមានឡើងនៅចន្លោះឆ្នាំ៧៥, ៧៩ ដែរឬទេ មុនពេលដែលលោកចុះហត្ថលេខានោះ គឺថា មុនពេលថ្ងៃទី០៥ នោះលោកមានបានជួបហើយបាននិយាយគ្នាអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ដែរឬទេ?

**ឆ៖** មុនថ្ងៃទី៥នោះ ដូចអត់មានបានពិភាក្សាគ្នា ឬក៏ខ្ញុំភ្លេចនិយាយអំពីចន្លោះពី៧៥ មកហ្នឹងដូចអត់បាន ឬក៏ខ្ញុំបាននិយាយខ្លះក៏មិនដឹង ខ្ញុំអត់ចាំ លោកប្រធានអត់ចាំ ចាំតែថ្ងៃទី០៥ ធ្នូ ២០០៧ គាត់សម្ភាស គឺចាំប៉ុណ្ណឹង។

**ស៖** បាទសូមអរគុណ។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីប្រធានបទមួយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ គឺនិយាយពាក់ព័ន្ធនឹងការរត់គេចចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។ សហព្រះរាជអាជ្ញាបានសួរលោក ពាក់ព័ន្ធទៅនឹងករណីដែលលោក ខៀវ សំផន បានរត់ទៅនៅជួរភ្នំក្រវាញជាមួយនឹងខ្មែរក្រហម។ ខ្ញុំចង់ដឹងថា ចុះលោក នៅពេលដែលវៀតណាមចូលនៅឆ្នាំ៧៩ លោកមានបានរត់ទៅនៅជួរភ្នំក្រវាញជាមួយខ្មែរក្រហមទេ?

**ឆ៖** បាទ ខ្ញុំបានទៅរស់នៅជាមួយពួកគាត់រហូត បាទ។

**ស៖** ហើយហេតុអ្វីបានជាលោកនៅជាមួយពួកខ្មែរក្រហមហ្នឹង? ហេតុអីក៏លោកមិនធ្វើអ្វីផ្សេងពីហ្នឹង តើមូលហេតុអ្វីដែល -- មានមូលហេតុអ្វីដែលនាំឲ្យលោកស្ថិតនៅជាមួយខ្មែរក្រហមហ្នឹងដល់ឆ្នាំ១៩៩០ នោះ?

[០៩:៥៦:១០]

**ឆ៖** បាទ ខ្ញុំមិនមានអ្វីជម្រើសទេ ព្រោះខ្ញុំធ្លាប់បានរស់នៅជាអង្គរក្សតាំងពីជំនាន់៣ឆ្នាំ។ អ៊ីចឹងនៅពេលដែលវៀតណាមចូលភ្នំពេញ ខ្ញុំត្រូវតែតាមពួកគាត់ ការពារគាត់រហូតទៅដល់ឆ្នាំ១៩៩០ គឺខ្ញុំអត់

មានគំនិតអីដែលថា រត់ចេញ ឬក៏គេចវេះអីចេញពីពួកគាត់ទេ គឺអត់មានជម្រើសទេ។ ខ្ញុំនៅតែរក្សាការងាររបស់ខ្ញុំពីភ្នំពេញទៅយ៉ាងម៉េច ដល់ព្រៃនោះយ៉ាងម៉េច គឺខ្ញុំនៅរក្សាអ៊ីចឹងបាទ។

**ស៖** ឥឡូវខ្ញុំចូលដល់ប្រធានបទចុងក្រោយ។ នៅពេលដែលលោកចុះហត្ថលេខានៅខែធ្នូ ឆ្នាំ២០០៥ លោកបានឆ្លើយថា "លើកទី១ ដែលលោកបានឮគេនិយាយអំពីទុរភិក្សដែលកើតមានឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺលោកស្តាប់ឮតាមវិទ្យុដែលផ្សាយចេញពីក្រុងភ្នំពេញ ឬក៏ពីសហរដ្ឋអាមេរិក" ហើយលោកបានប្រាប់ "លោកឮព័ត៌មាននេះ ប្រហែលជាក្នុងចន្លោះឆ្នាំ៨០ ទៅ៨២" តើលោកនៅរក្សាចម្លើយរបស់លោកនេះ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅរក្សាចម្លើយនេះ។

**ស៖** បាទ ដូច្នេះ បានន័យថា ពីមុនមកនោះ លោកមិនដែលដឹងអំពីស្ថានភាពនេះទេ គឺថាមុនឆ្នាំ១៩៨១ ដល់១៩៨២ ហ្នឹង លោកអត់ដែលដឹងអំពីការអត់ឃ្លានដែលកើតមានឡើងនៅក្រោមរបបខ្មែរក្រហមនេះទេ តើអ៊ីចឹងមែនទេ?

[០៩:៥៩:០៣]

**ឆ៖** បាទ អ៊ីចឹងមែន អត់ដឹងមែន។

**លោក អាកទ្បូវ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន ហើយលោកសាក្សី ខ្ញុំសូមអរគុណលោកជាច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលសាក្សី ស វិ។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្តីតំណាងអយ្យការ សហភាតាហើយក៏សួស្តីលោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះ ទោះនៅក្នុងបន្ទប់ក្តី នៅក្រៅបន្ទប់ក្តី។

[០៩:៥៩:៥០]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សួស្តីលោក ស វិ។ ខ្ញុំអាង ឧត្តម ជាសហមេធាវីការពារក្តីលោក អៀង សារី។ ពេលនេះ

ខ្ញុំមិនមានសំណួរសួរលោកច្រើនទេ ប្រហែលជាមិនច្រើនទេ គឺប៉ុន្មានសំណួរបីបួនសំណួរប៉ុណ្ណឹង ប្រហែលៗ។ ហើយក៏ជុំវិញតែបញ្ហាព្រឹត្តិការណ៍កើតឡើងនៅ -- ដែលលោកបានដឹងនៅមន្ទីរ ក-១ តែប៉ុណ្ណឹង។ អំមិញលោកប្រធានបានបញ្ជាក់ហើយថា កុំឲ្យជៀសវាងការច្រឡំគ្នា ព្រោះម្សិលមិញ និងថ្ងៃនេះមានការច្រឡំពាក្យថា "ជាន់" លោកបានមានប្រសាសន៍អំមិញថា អគារ ក-១ ហ្នឹង មានតែពីរជាន់ទេ។ បើគេនិយាយឥឡូវ ជាន់ ហ្នឹងគឺ ជាន់លើ ជាន់ក្រោម ជាន់ខ្ពស់ៗទៅលើទៅ ហើយតាមគំនិតលោកគឺមិនអ៊ីចឹងទេ គឺជាន់ហ្នឹង គឺខ្សែក្រវាត់ការពារទេ។ ខ្សែក្រវាត់ទី១អ៊ីចឹងទៅ វាកៀកហ្នឹងអគារហ្នឹងបន្តិចទៅ។ ខ្សែក្រវាត់ការពារទី២វាឆ្ងាយបន្តិចអ៊ីចឹងទៅ។ ខ្សែក្រវាត់ការពារទី៣ វាឆ្ងាយជាងអាទី២ ហ្នឹងទៀតទៅ។ អាហ្នឹងតើលោកយល់ស្របតាមខ្ញុំអ៊ីចឹងទេ?

**លោក ស វិះ**

**ឆ៖** បាទ យល់ស្របតាមលោក។

**ស៖** សូមអរគុណ។ អ្នកការពារនៅខ្សែក្រវាត់ទី១ហ្នឹង មានចម្ងាយប៉ុន្មានពី -- នៅក្នុងបរិវេណអគារ ក-១ ហ្នឹងតែម្តង ឬមួយនៅព័ទ្ធនៅក្រៅរបងអគារ ក-១?

[១០:០១:៤៣]

**ឆ៖** បាទអ្នកការពារជាន់ទី១ គឺនៅវង្វង់ក្នុងរបង ខាងក្នុងហ្នឹងតែម្តង។ អត់ក្នុងអគារទេ គឺក្នុងរបងខាងក្នុង ដែលមានរបងព័ទ្ធជុំវិញ។ គេនៅខាងក្នុងហ្នឹងតែម្តង ហៅថាជាន់ទី១ នៅក្នុងរបង។

**ស៖** បាទ សូមអរគុណ។ ហើយលោកអះអាងថា លោកនៅការពារនៅជាន់ ឬខ្សែក្រវាត់ទី២។ ពីខ្សែក្រវាត់ទី១ មកខ្សែក្រវាត់ការពារទី២ ឬជាន់ទី២ហ្នឹងមានចម្ងាយប្រហែលប៉ុន្មាន?

**ឆ៖** បាទ ជាន់ទី២ គឺជាប់នឹងរបងតែម្តង គិតទៅចម្ងាយប្រហែលគ្រាន់តែឆ្លងផុតរបងមក មកដល់ជាន់ទី២ហ្នឹងតែម្តងបាទ ប្រហែលពីរបីម៉ែត្រ។ បើកទ្វារចេញពីក្នុងមក ចូលមក -- ចេញក្រៅគឺដល់ជាន់ទី២ បាទ។

**ស៖** បាទ សូមអរគុណ។ លោកបានមានប្រសាសន៍ពីម្សិលមិញថា ពីជាន់ទី២ទៅ ដែលលោកនៅប្រចាំការយាមនៅទីនោះ មិនអាចមើលឃើញផ្ទុះចូលទៅជាន់ទី១បានទេ ដោយហេតុថា មានរបងបិទជិតខ្ពស់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ មើលអត់ឃើញទេ អ៊ីចឹងមែន។

[១០:០៣:៣៣]

**ស៖** សូមអរគុណ។ នៅខាងក្រោមលោកមិនអាចមើលឃើញទៅក្នុងអគារទេ ប៉ុន្តែបើយើង -- បើលោកមើលសម្លឹងទៅអគារ ក-១ នោះតែម្តង គឺនៅជាន់ទី២អីអ៊ីចឹងទៅ លោកអាចមើលឃើញទៅអគារជាន់ទី២ហ្នឹងទេ?

**ឆ៖** បាទ ត្រឹមជាន់ទី៣ទៅ យើងអាចសម្លឹងឃើញ បើសិនជាយើងនៅកៀករបង។ តែបើយើងទៅឆ្ងាយពីរបងប្រហែលជា៥០០ម៉ែត្រ ៧០០ម៉ែត្រទៅ យើងអាចមើលឃើញដល់ជាន់ទី២ ជៀសវាងតែជាន់ទី១ យើងមើលមិនឃើញ ទោះបីយើងថយឆ្ងាយប៉ុនណា ក៏មើលមិនឃើញដែរជាន់ទី១។

**ស៖** សូមអរគុណ។ លោកមានប្រសាសន៍ផ្តល់សក្ខីកម្មពីម្សិលមិញថា សឹងតែរាល់ថ្ងៃលោកបានឃើញមេដឹកនាំកំពូលៗ ក្នុងហ្នឹង លោករាយរាប់មានលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន ចូលទៅអគារមន្ទីរ ក-១ ហ្នឹង។ លោកដឹងថាពួកអស់លោកទាំងហ្នឹងចូលទៅអគារ ក-១ ហ្នឹង ក្នុងគោលបំណងអី?

**ឆ៖** បាទ ខ្ញុំអត់ដឹងគោលបំណងរបស់គាត់ទេ។

**ស៖** សូមអរគុណ។ លោកដែលធ្លាប់បានឮពីកន្លែងលោកឈរចាំយាមនៅជាន់ទី២ហ្នឹងទៅបានឮពីថាមានប្រជុំអីនៅក្នុងអគារ ក-១ ហ្នឹងទេ?

[១០:០៥:៥៧]

**ឆ៖** សូមទោសស្តាប់អត់សូវបានសូមប្រធានបញ្ជាក់ម្តងទៀត សំណួរនេះ។

**ស៖** បាទ សូមទោស ដោយសារសំណួរខ្ញុំមិនច្បាស់សម្រាប់លោក ខ្ញុំសូមសួរលោកម្តងទៀត។ ពីកន្លែងលោកឈរយាមនៅជាន់ទី២ ឬខ្សែក្រវាត់ទី២ហ្នឹង លោកដែលធ្លាប់ឮ ឮពីខាងក្នុងអគារមកវិញនោះ ពីកិច្ចប្រជុំណាមួយទេ? ឮសំឡេង បាទ ឮស្តាប់នឹងត្រចៀករបស់លោក?

**ឆ៖** បាទ អត់ឮៗទេ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលអស់លោកថ្នាក់ដឹកនាំកំពូលៗហ្នឹងចេញមកវិញក្រោយមក និងបន្ទាប់ពីហ្នឹងមក តើមានអ្នកណារួមទាំងមេរបស់លោកផ្ទាល់មានលោក តាន និងលោក សុត ឬអ្នកផ្សេងទៀត ធ្លាប់បានប្រាប់លោកថា មានកិច្ចប្រជុំណាមួយនៅក្នុងអគារមន្ទីរ ក-១ ហ្នឹងទេ?

**ឆ៖** បាទ គាត់អត់បានប្រាប់យើងទេ ក្នុងករណីនេះ។

**ស៖** ក្រៅពីហ្នឹងលោកក៏បានអះអាងថា ធ្លាប់ឃើញមានកម្មាភិបាលជាន់ខ្ពស់មកពីភូមិភាគ

តំបន់ ឬស្រុកនានានៅទូទាំងប្រទេសមកមន្ទីរ ក-១ ហ្នឹងដែរ។ សំណួរខ្ញុំដដែលដូចសំណួរពីមុនដែរទេ តើលោកដឹងថាកម្មាភិបាលជាន់ខ្ពស់ដែលមកពីឆ្ងាយ មកពីភូមិភាគ តំបន់ ស្រុកទាំងអស់ហ្នឹងមកមន្ទីរ ក-១ ក្នុងគោលបំណងអីដែរ?

**ឆ៖** បាទ មកដល់មន្ទីរ ក-១ នេះសុទ្ធតែមកធ្វើការ តាមខ្ញុំយល់មកធ្វើការ។

**ស៖** ពាក្យថា "ធ្វើការ" ជំនាន់ហ្នឹងគេចង់សំដៅថាម៉េច ថា សូមលោកបញ្ជាក់ឲ្យច្បាស់មើល៍?

**ឆ៖** មកប្រជុំៗ។

[១០:០៩:៣៤]

**ស៖** បាទ សូមអរគុណ។ ដដែលទេ ពីកន្លែងលោកយាមកាមនៅខ្សែក្រវាត់ទី២ទៅ លោកមិនអាចឃើញ និងមិនអាចឮខ្លឹមសារនៃកិច្ចប្រជុំរបស់កម្មាភិបាលជាន់ខ្ពស់ហ្នឹងទេ ខ្ញុំសង្ខេបអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** ប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំ។ អ៊ីចឹងក្រោយពីកម្មាភិបាលជាន់ខ្ពស់មកពីឆ្ងាយៗទាំងអស់នុំងចេញទៅវិញ តើលោកបានដឹង ទោះតាមរយៈណាក្តី ថាគេបានជុំគ្នា និងសម្រេចគ្នាពីកិច្ចការអី ពីកិច្ចការណាមួយដែរទេ?

[១០:១០:៤៨]

**ឆ៖** បាទរឿងទាំងអស់នេះ គឺខ្ញុំមិនជ្រាបទេនូវកិច្ចការឯកភាពគ្នាលើគោលការណ៍អីមួយ នៅពេលដែលគាត់ត្រឡប់ទៅវិញ គឺខ្ញុំអត់ដឹង។

**លោក អាង ឧត្តម៖**

សូមអរគុណលោក ស រិ។ ខ្ញុំអស់សំណួរសួរលោកហើយ។ តាងនាមលោក អៀង សារី ខ្ញុំសូមជូនពរលោកឲ្យបានទទួលជោគជ័យសិរីសួស្តីដរាបចាប់ពីលោកត្រឡប់ទៅវិញទៅ។ ហើយក៏សូមអរគុណលោកប្រធាន ដោយសារខ្ញុំបាទអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី។

លោក ស រិ ការស្តាប់សក្ខីកម្មរបស់លោកក្នុងនាមជាសាក្សីរហូតដល់ពេលនេះបានចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់

លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។

[១០:១១:៥៧]

អង្គជំនុំជម្រះសូមអរគុណចំពោះលោក ស វិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល១ថ្ងៃ និងមួយព្រឹកកន្លងមកនេះ ប្រកបដោយភាពអត់ធ្មត់ ហើយនិងខិតខំអស់ពីសមត្ថភាព លទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដី។ សូមលោក ស វិ ជួបតែសំណាងល្អ មានសុខភាពល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅបានហើយ។

[១០:១២:៤១]

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយយើងនឹងចាប់ផ្ដើមដោយស្ដាប់សក្ខីកម្មសាក្សីមួយរូបទៀត ដែលបម្រុងទុកគឺសាក្សី 450 -- 754 បាទ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម TCW-754 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៣៦:០៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ខ្ញុំឈ្មោះ អ៊ុង វ៉ែន។

**ស៖** អ៊ុង វ៉ែន ឬក៏ អ៊ុង វ៉ែម? ប្រកបនឹង “ម” ឬក៏ប្រកបនឹង “ន”?

**ឆ៖** អ៊ុង វ៉ែន។ “ន”!

**ស៖** អរគុណលោក អ៊ុង វ៉ែន។ ក្រៅពីឈ្មោះ អ៊ុង វ៉ែន តើលោកមានដែលប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** ក្រៅពីឈ្មោះ អ៊ុង វ៉ែន នេះគ្មានប្រើប្រាស់ឈ្មោះអីផ្សេងក្រៅពីនេះ។

**ស៖** បាទ អរគុណលោក អ៊ុង វ៉ែន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

[១០:៣៧:២១]

**ឆ៖** ខ្ញុំមិនបានចាំ ប៉ុន្តែតែគ្រាន់តែដឹងថាឆ្នាំ១៩៥០។

**ស៖** បាទអរគុណ លោកមានកើតនៅឆ្នាំ១៩៥០។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតនៅភូមិតាំងពោធិ៍ ឃុំប្រាំបីមុំ ស្រុកថ្ពង។

**ស៖** ខេត្តកំពង់ស្ពឺមែនទេ?

**ឆ៖** បាទ កំពង់ស្ពឺ។

**ស៖** អរគុណលោក អ៊ុង វ៉ែន។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅសព្វថ្ងៃនៅភូមិផ្អៀកជ្រុំ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

[១០:៣៨:៣៥]

**ស៖** បាទអរគុណ។ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** ប្រកបរបបរកស៊ី ធ្វើស្រែ និងចម្ការ ហើយនិងធ្វើការងារក្រុមប្រឹក្សាស្រុក។

**ស៖** បាទអរគុណ។ តើលោកអាចប្រាប់ដល់អង្គសវនាការអំពីឈ្មោះឪពុករបស់លោក និងម្ដាយរបស់លោកបានដែរឬទេ? តើគាត់ឈ្មោះអី?

**ឆ៖** ប្រាប់បាន គឺឪពុកខ្ញុំឈ្មោះ ខាត់។ ម្ដាយឈ្មោះ ស៊ឹម។ ស្លាប់ទាំងពីរ។

**ស៖** លោកអាចប្រាប់ទាំងនាមត្រកូលបានទេ ស្ដី ខាត់ ទៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សុំឆ្លើយទាំងត្រកូលណ៎ះ ទាំងឪពុក ទាំងម្ដាយ?

**ឆ៖** ឪពុកគឺ -- ត្រកូលគឺ អ៊ុង។ អ៊ុង ខាត់។

**ស៖** ចុះម្ដាយរបស់លោក ត្រកូលគាត់ឈ្មោះអី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ម្ដងទៀត មិនទាន់-- ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។ លោកចាំមើល បង្អង់បន្តិចឲ្យក្បាលមីក្រូប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហម សឹមលោកចាប់ផ្ដើមនិយាយ។ ម្ដងទៀត ម្ដាយរបស់លោកគាត់ឈ្មោះអី ត្រកូល នាមត្រកូលនិងនាមខ្លួនគាត់?

**ឆ៖** ម្ដាយ ឪពុកគាត់ឈ្មោះ ហង់។ ខ្លួនគាត់ឈ្មោះ ស៊ឹម។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ កឿក រ័ត្ន។ កូនបួននាក់។

**ស៖** អរគុណលោក រ៉េន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដី០០២ នេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

[១០:៤១:៣១]

**ឆ៖** បាទ ជាការពិត។

**ស៖** បាទ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការព្រឹកមិញដដែលនេះថា លោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងរួចហើយ មុនដែលលោកចូលខ្លួនមកកាន់កន្លែងផ្ដល់ សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ តើពិតមែនដែរទេ?

**ឆ៖** ពិតមែន។

**ស៖** បាទ ជាបន្តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចចំពោះលោក ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ។ លោក វ៉ែន ក្នុងនាមលោកជាសាក្សីនៅកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងរបស់លោកនោះនាំឱ្យលោកនឹងត្រូវទទួលរង ការចោទប្រកាន់។

[១០:៤២:៣៦]

អំពីករណីយកិច្ច លោក វ៉ែន ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះបានសួរចំពោះលោក លើកលែងតែករណីដែលលោកប្រើសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ លោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមអង្គជំនុំជម្រះបានសួរលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ ក្នុងនាមជាសាក្សី?

**ឆ៖** បាទ ខ្ញុំយល់។

**ស៖** បាទ អរគុណលោក វ៉ែន។ តើលោកមានដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមកនេះ? ហើយប្រសិនបើមានតើការធ្វើសម្ភាសនេះប្រព្រឹត្តទៅប៉ុន្មានលើក? នៅទីកន្លែងណា? នៅពេលណា?

**ឆ៖** បញ្ហាសម្ភាសគឺនៅផ្ទះខ្ញុំតែម្តង ភូមិផ្អៀកជ្រុំ ឃុំផ្គាវ។ ហើយតាមខ្ញុំចាំ គឺបីដង។

[១០:៤៤:១៨]

**ស៖** អរគុណ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោក វ៉ែន បានពិនិត្យមើល ឬក៏បានអាន ឬក៏បានស្តាប់ការអាន របស់អ្នកណាម្នាក់នូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតចំនួនបីដងដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានពិនិត្យហើយ ប៉ុន្តែវាមិនបានចាំគ្រប់បញ្ហាទាំងអស់ទេ។

**ស៖** បាទអរគុណ ហើយបើសមត្ថភាពដែលលោកអាចដឹង និងចងចាំតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានមើល ឬក៏បានអានដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវឬក៏ស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយ ដែលលោកធ្លាប់បានធ្វើការសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីលើកមុននោះដែរឬទេ?

**ឆ៖** បាទគឺខ្ញុំបានអាននិងពិនិត្យអំពីបញ្ហាដែលខាងអស់លោកទៅសម្ភាសនៅផ្ទះខ្ញុំគឺបញ្ហាទី១ គឺចង់និយាយថា បញ្ហាដែលដំបូងគឺនិយាយអំពីបញ្ហាវៃចូលភ្នំពេញនេះ ខ្ញុំក៏បានរបួសទៅដេកពេទ្យនៅវត្តតាំងកសាង។

**ស៖** មិនមែនអ៊ីចឹងទេ សំណួរសួរថា ក្រោយពីលោកអាន កាលពីលោកបានផ្តល់សក្ខីកម្មចំពោះអ្នកស៊ើបអង្កេតចំនួនបីលើក ហើយមុនពេលផ្តល់ ចូលមកផ្តល់សក្ខីកម្មនេះ គឺលោកបានអាន បានពិនិត្យមើលនូវកំណត់ហេតុដែលបានកត់ត្រានូវចម្លើយរបស់លោក ដែលលោកបានផ្តល់សក្ខីកម្មកាលពីបីលើកកន្លងទៅនេះ។ សំណួរសួរថា អ្វីដែលលោកបានពិនិត្យមើលនេះ ធៀបជាមួយនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មចំនួនបីលើក កាលដែលលោកធ្វើនៅនឹងផ្ទះរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតពីប៉ុន្មានឆ្នាំកន្លងមកនេះ តើវាសមស្របជាមួយគ្នាទេ ឬក៏វាមានខ្លឹមសារខុសគ្នា? និយាយជាទូទៅបានហើយ មិនមែននិយាយដោយឡែកលម្អិតទេ។ ចំណែកឯលម្អិតហ្នឹងគេសួរលោកនៅពេលក្រោយ។

**ឆ៖** បាទ ខ្ញុំបានពិនិត្យពិចារណាលើបញ្ហាដែលសួរហើយនិងឆ្លើយនូវបញ្ហាទាំងអស់ដែលបានទៅសម្ភាសខ្ញុំនោះ។

[១០:៤៧:០១]

**ស៖** ឃើញសមស្របទៅនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មទេ?

**ឆ៖** សមស្រប។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អង្គជំនុំជម្រះសូមជម្រាបដល់តំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកា ជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សូមអញ្ជើញ!

[១០:៤៧:៣៣]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ និងសាធារណជន។ សួស្ដីផងដែរ លោក អ៊ុង វ៉ែន ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញា។ ថ្ងៃនេះខ្ញុំជាមួយសហភាតាអន្តរជាតិរបស់ខ្ញុំគឺ លោក ឌេល លីសាក់ មានសំណួរមួយចំនួនចង់សាកសួរលោក។ ប៉ុន្តែមុននឹងចាប់ផ្តើមសួរសំណួរលោក ខ្ញុំក៏សូមការអនុញ្ញាតពីលោកប្រធានផងដែរ ដើម្បីប្រគល់នូវកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីរូប នេះ ដែលមានលេខឯកសារ E3/402 , ឯកសារ E3/84 និងឯកសារ D369/11 ហើយឯកសារមួយ ទៀត គឺD232/36 ដើម្បីផ្តល់ជូនទៅសាក្សីរូបនេះ បន្ទាប់ពីនឹងមានការសួរឲ្យសាក្សីបញ្ជាក់ទៅនឹង ចម្លើយ ដែលគាត់បានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត។ សូមលោកប្រធានអនុញ្ញាត។

[១០:៤៨:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះ រាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោក អ៊ុង វ៉ែន ឯកសារដែលមាននៅក្នុងដៃរបស់លោកនេះជាកំណត់ហេតុស្ដាប់ចម្លើយ ដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានសួរ ហើយលោកបានឆ្លើយពាក់ព័ន្ធ ទៅនឹងចម្លើយដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោក -- នៅក្នុងចម្លើយរបស់លោកត្រង់ឯកសារ D369/11 ត្រង់ចម្លើយលេខបី លោកបានប្រាប់ អ្នកស៊ើបអង្កេតថា មុនឆ្នាំ៧៥ គឺលោកនៅក្នុងកងវរសេនាតូច មកពីភូមិភាគពិសេស។ អ៊ីចឹង ខ្ញុំចង់ សួរលោកបញ្ជាក់ថា តើនៅពេលណាលោកចូលធ្វើបដិវត្តន៍កងទ័ព? ហើយពេលចូលដំបូងហ្នឹង តើ លោកឈរជើងនៅទីតាំងនៅត្រង់កន្លែងណា?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ដំបូងគឺ ខ្ញុំធ្វើការនៅចុងឆ្នាំ១៩៧៩ (ស៊ីក)។ ដល់ឆ្នាំ៧០ អាហ្នឹង ធ្វើនៅភូមិតាំងពោធិ៍ហ្នឹង

ឯង ដល់ឆ្នាំ៧០ ខ្ញុំមកនៅខាងលិចត្នោតពងក្នុងត្រពាំងល្វានេះ។ ហើយមានកម្លាំងមួយចំនួននៅនោះ គឺគេរៀបចំថា វរសេនាតូចលេខ៣។

[១០:៥១:០១]

**ស៖** ចាស នៅពេលដែលលោកចូលធ្វើបដិវត្តន៍កងទ័ពនោះ តើនរណាជាអ្នកណែនាំឲ្យលោកចូលធ្វើបដិវត្តន៍ លោកចាំបានទេ?

**ឆ៖** ខ្ញុំចាំបានថា មានឈ្មោះ ចេង អន។

**ស៖** តើឈ្មោះ ចេង អន ហ្នឹង ជាអ្នកណា? មានតួនាទី ឬឋានៈអី? ហើយតើពេលនេះ គាត់នៅទីណា លោកដឹងទេ?

**ឆ៖** តាមពេលនោះ គឺគាត់គឺ តាមខ្ញុំស្គាល់ គឺគាត់ទទួលខាងស្រុកផង ហើយនិងទទួលខាងគណៈតំបន់ផង ទទួលខាងកងទ័ពផង។

**ស៖** ចាស សូមអរគុណ។ តើលោកអាចជម្រាបប្រាប់អង្គសវនាការបានទេថា តើភូមិភាគពិសេសហ្នឹង មានតួនាទីអ្វីខ្លះ?

**ឆ៖** ភូមិភាគពិសេស គឺមានតួនាទីភារកិច្ច គឺធ្វើការងារប្រជាជនតាមម្តុំអង្គស្នួល ម្តុំត្នោតពង ហើយមានភារកិច្ចទៅធ្វើការងារចូលភ្នំពេញ។

[១០:៥២:៤១]

**ស៖** សូមលោកជួយបញ្ជាក់ពន្យល់បន្តិចថា តើធ្វើការងារប្រជាជនហ្នឹង មានន័យយ៉ាងដូចម្តេចធ្វើការងារប្រជាជនហ្នឹង?

**ឆ៖** ធ្វើការងារប្រជាជនហ្នឹង គឺចង់និយាយថា ខំប្រមូលកម្លាំងដើម្បីរួបរួមគ្នា ឲ្យមានកម្លាំងច្រើន។

**ស៖** ចាស សូមអរគុណ។ ចុះអ្នកណាជាមេបញ្ជាការភូមិភាគពិសេសនៅពេលនោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូម--

**លោក អ៊ុង វ៉ែន៖**

**ឆ៖** មិនបានមើលភ្លើង។ ពេលនោះ ដែលខ្ញុំមកឈរជើងនៅកន្លែងនោះ គឺមិនមាន រៀបចំជា

កងភូមិភាគពិសេសទេ គ្រាន់តែជាកងឯករាជ្យធ្វើការនៅម្តុំហ្នឹង មាន ចេង អន គឺអ្នកទទួលខុសត្រូវ។

**ស៖** អ៊ីចឹង តើខ្ញុំយល់ជាការត្រឹមត្រូវទេ? ពេលហ្នឹង អត់ទាន់មានភូមិភាគពិសេស អ៊ីចឹង នៅពេលដែលលោកត្រូវរាយការណ៍ តើលោកត្រូវរាយការណ៍ឲ្យតែ ចេង អន ឬក៏ថ្នាក់លើផ្សេងទៀត ដែលលោកត្រូវរាយការណ៍ឲ្យ?

[១០:៥៤:២០]

**ឆ៖** ខ្ញុំរាយការណ៍ឲ្យតែ ចេង អន ហ្នឹងឯង អត់មានរាយការណ៍ពីណាទៀតទេ ព្រោះស្គាល់តែម្នាក់ហ្នឹងឯង។

**ស៖** ចាស សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល លោកបានប្រាប់អ្នកស៊ើបអង្កេតថា "កងពលរបស់លោកមកពីភូមិភាគពិសេស និងកងពលមួយមកភូមិភាគឧត្តរ ក្រោមការបញ្ជាដោយ តាសាន បានបញ្ចូលគ្នា និងបញ្ចូលគ្នាក្លាយជាកងវរសេនាធំមួយ ដើម្បីរៀបចំ និងសហការគ្នា រំដោះទីក្រុងភ្នំពេញ"។ ខ្ញុំចង់ឲ្យលោកឆ្លើយបញ្ជាក់លើចំណុចនេះ តើនៅពេលដែលកងទ័ពមកពីអង្គភាពរបស់លោក គឺមកពីកងឯករាជ្យ បានបញ្ចូលគ្នាជាមួយនឹងអង្គភាពមួយផ្សេងទៀតហ្នឹង តើនៅពេលណា លោកចាំបានទេ?

**ឆ៖** ខ្ញុំចាំបានថា ប្រហែលជាឆ្នាំ១៩៧២ ខាងលិចភ្នំពេញ។

**ស៖** តើនៅពេលនោះ នរណាគាត់មានសិទ្ធិ ឬក៏អំណាចក្នុងការបញ្ជាឲ្យមានការបញ្ចូលគ្នារវាងកងវរសេនាធំ ជាមួយនឹងកង ឬក៏អង្គភាពផ្សេងទៀតហ្នឹង?

**ឆ៖** ហ្នឹងឯងដែលជាគណៈចាត់ចែងរៀបចំបញ្ចូលគ្នា។

**ស៖** សូមទោសលោក សូមលោកជួយបញ្ជាក់ម្តងទៀតថា តើនរណា? គាត់មានឈ្មោះអី ហើយមានតួនាទី និងឋានៈអី?

**ឆ៖** តាមពិតគឺ ចេង អន ហ្នឹងគឺគាត់ទទួលខាងគណៈតំបន់ផង ហើយគណៈមេបញ្ជាការភូមិភាគហ្នឹងផង នៅកន្លែងហ្នឹងផង។

[១០:៥៦:៤៦]

**ស៖** តើខ្ញុំយល់ជាការត្រឹមត្រូវទេថា មានបញ្ជាពី ចេង អន ដើម្បីឲ្យមានការដាក់បញ្ចូលគ្នារវាងអង្គភាព និងអង្គភាព?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ ប៉ុន្តែគ្រាន់ថា មានតែតា ចេង អន ហ្នឹងម្នាក់ឯង ដែលគាត់អ្នករៀបចំបញ្ជា

នេះបញ្ចូលគ្នា។

**ស៖** ចាស សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតដដែល លោកបាននិយាយដល់កងពលតូចលេខ១៤។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមថា តើកងពលតូចលេខ១៤ ហ្នឹងមានតួនាទីអ្វី?

**ឆ៖** ខ្ញុំសូមអនុញ្ញាតមានមតិថា ចំពោះកង -- នៅមុននឹងរៀបចំកងពលតូចលេខ១៤ នេះគឺមានតាំងពីខាងត្បូងផ្លូវជាតិលេខ៤ មួយវរៈមកពីខាងត្រពាំងល្ហា មួយវរៈ មកពីខាងឧត្តរមក បានរៀបចំជាកងពលតូចលេខ១៤។ ភារកិច្ចគឺធ្វើការខាងជើងផ្លូវជាតិលេខ៤ ចូលមកភ្នំពេញ។

**ស៖** តើការងារអ្វីខ្លះដែលកងវរសេនាតូចលេខ១៤ហ្នឹង -- កងពលតូចលេខ១៤ហ្នឹងគាត់ធ្វើ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

[១០:៥៨:៥១]

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ក្នុងកងពលលេខ១៤ហ្នឹង ភារកិច្ចដូចខ្ញុំបានបញ្ជាក់ពីខាងដើម គឺទី១ គឺខំរៀបចំកម្លាំងប្រមូលកម្លាំងឲ្យបានច្រើន ដើម្បីទិសដៅគឺរុលមកមុខ។ ឯទី២ គឺរៀនសូត្រហាត់ខាងផ្នែកបច្ចេកទេសប្រយុទ្ធ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តើពេលហ្នឹងមេបញ្ជាការរបស់កងពលតូចលេខ១៤ហ្នឹង គាត់មានឈ្មោះអីដែរ? ហើយមានលេខកូដទេពេលហ្នឹង?

**ឆ៖** ពេលហ្នឹងមេបញ្ជាការកងពលលេខ១៤ គឺមាន ស៊ូ សារឿន ហៅ០៥ ហើយនិង សាន ខ្ញុំមិនចាំលេខកូដ -- សាន នោះគឺហៅ០៦។

**ស៖** ចុះពេលហ្នឹងតើលោកមានមុខតំណែង ឬតួនាទីអ្វីនៅក្នុងកងពលតូចលេខ១៤ហ្នឹង នៅក្នុងអំឡុងឆ្នាំហ្នឹង?

**ឆ៖** ក្នុងការរៀបចំហើយ គឺផ្ទាល់ខ្លួនខ្ញុំមានភារកិច្ចគឺទទួលខុសត្រូវវរសេនាធំ។

**ស៖** តើលោកចាំបានទេថា នៅក្នុងកងពលតូខលេខ១៤ហ្នឹង មានទាហានប៉ុន្មាននាក់ ក្រោយពីមានការដាក់បញ្ចូលគ្នារវាងអង្គភាពនិងអង្គភាពមក?

[១១:០០:៥៣]

**ឆ៖** ខ្ញុំក្តាប់ក្នុងកងពលមិនបានទេ តែក្នុងអង្គភាពខ្ញុំមានប្រហែល៥០០នាក់។

**ស៖** ចុះនៅក្នុងអង្គភាពរបស់លោក តើលោកមានដែលស្គាល់ទាហានម្នាក់ កាំង មុត ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានស្គាល់ កាំង មុត ទេ។

**ស៖** ចុះអនុប្រធានរបស់លោកឈ្មោះអីនៅពេលនោះ?

**ឆ៖** អនុប្រធានរបស់ខ្ញុំគឺ សឿន ត្រកូលខ្ញុំមិនចាំ។

**ស៖** ពាក់ព័ន្ធទៅនឹងកងពលតូចលេខ១៤នេះដែរ តើកងពលតូចលេខ១៤នេះបានចូលរួមក្នុងសមរភូមិណាមួយ ឬក៏ប្រយុទ្ធតទល់ជាមួយនឹងទាហាន លន់ នល់ ទេនៅក្នុងមុនឆ្នាំ៧៥?

**ឆ៖** ក្នុងកងពលលេខ១៤ មានតែវ៉ៃទាហាន លន់ នល់ ទេ អត់មានវ៉ៃអីទេ។

**ស៖** តើការចាប់ផ្តើមវ៉ៃទាហាន លន់ នល់ ហ្នឹងពីឆ្នាំ៧៣ និង៧៤ ឬក៏មានមុនហ្នឹង?

[១១:០២:៤៨]

**ឆ៖** កាលពីវ៉ៃទាហាន លន់ នល់ ហ្នឹងគឺតាមតាំងពីមុន៧៤។

**ស៖** ពាក់ព័ន្ធនឹងការវ៉ៃទាហាន លន់ នល់ នេះដែរ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទីតាំង ដោយរៀបរាប់កន្លែងទីតាំងដែលកងពលរបស់លោកវ៉ៃទាហាន លន់ នល់ តើនៅតំបន់ណាបានវ៉ៃ? ហើយតំបន់ណាដែលជាសមរភូមិក្តៅ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាសមរភូមិនៅក្នុងអង្គភាពវរសេនាធំខ្ញុំ ខ្ញុំនិយាយតែវរសេនាធំខ្ញុំទេ គឺវ៉ាត្រពាំងត្នោត គ្រប់អង្គភាពខ្ញុំវ៉ៃបាត់ដឹង ហើយនិងភ្នំប្រសិទ្ធិ៍ ហើយនិងពូនភ្នំ។ ហ្នឹងវ៉ៃនៅជំហានទី១។

**ស៖** ចុះកងវរសេនាធំរបស់លោកហ្នឹងមានវ៉ៃនៅម្តុំ អូរប្រម៉ាត ហើយនិងនៅថ្នល់ទទឹងទេ?

**ឆ៖** ខាងជើងផ្លូវ១៤ គឺថាកងពល១៤ -- ផ្លូវជាតិលេខ៤ នេះគឺមានកងពលកម្លាំងកងពល១៤ដែរ ប៉ុន្តែវរសេនាធំផ្សេង ដែលគេធ្វើការនៅខាងជើងផ្លូវ១៤។

[១១:០៤:៤៩]

**ស៖** សូមលោកជួយជម្រាបប្រាប់អង្គសវនាការពាក់ព័ន្ធទៅនឹងពេលវ៉ៃទាហាន លន់ នល់ ហ្នឹងតើមានបញ្ហា ឬរឿងអ្វីកើតឡើងនៅពេលដែលទាហាន លន់ នល់ ត្រូវកងទ័ពបដិវត្តន៍កម្ពុជាចាប់ខ្លួន?

**ឆ៖** បញ្ហានេះគឺខ្ញុំបញ្ជាក់ថា គឺខ្លួនខ្ញុំ គឺដឹងថា ពេលដែលធ្វើសកម្មភាពកន្លងមកគឺដោយតាមតែមេរបស់ខ្ញុំណែនាំឲ្យវ៉ៃទាហាន លន់ នល់ៗ ក៏ចេះតែវ៉ៃតែម្តង។ មិនទាន់ដឹងថា យ៉ាងណា យ៉ាងណីទេ

គឺជាសត្រូវ។

**ស៖** ចាស ទាក់ទងទៅនឹងបញ្ហានេះ ប្រសិនបើ ដូចដែលលោកបានប្រាប់ហើយថា លោកទទួលបញ្ហាពីមេ ហើយឱ្យវ៉ៃ ហើយចាត់ទុកថាទាហាន លន់ នល់ ជាសត្រូវ។ ខ្ញុំចង់បញ្ជាក់ថាតើនៅពេលដែលចាប់ខ្លួនបានទាហាន លន់ នល់ នោះ ទាហាន ឬក៏កងទ័ពខ្មែរក្រហមនោះធ្វើយ៉ាងម៉េចចំពោះទាហាន លន់ នល់ ដែលចាប់បានហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបថា ភារកិច្ចរបស់ខ្ញុំគឺនៅតែខាងមុខទេ ឯឈ្លើយសឹកដែលចាប់បាន គឺភាគច្រើនបញ្ជូនទៅក្រោយ ប៉ុន្តែមិនដឹងជាគេយកទៅធ្វើអី ឬកទុកកន្លែងណា អប់រំកន្លែងណា ខ្ញុំមិនដឹង។

**ស៖** ចាស សូមអរគុណ។ តើនៅកងពលតូចលេខ១៤ បានចូលរួមក្នុងសមរភូមិឧដុង្គ ឆ្នាំ១៩៧៤ដែរឬទេ?

**ឆ៖** កងពលលេខ១៤មាន ចូលរួមប្រយុទ្ធនៅសមរភូមិឆ្នាំ៧៤។

**ស៖** ប្រសិនបើមានបានចូលរួម សូមលោកជួយរៀបរាប់ប្រាប់អង្គសវនាការផង ថាតើសមរភូមិនៅឧដុង្គនោះ ជាសមរភូមិយ៉ាងម៉េចដែរ? សមរភូមិក្ដៅ សមរភូមិដែលមានកងទ័ព ឬទាហានស្លាប់ច្រើន ឬក៏យ៉ាងម៉េចដែរ? សូមលោកជួយរៀបរាប់លម្អិតពីបញ្ហាសមរភូមិនៅឧដុង្គនេះ?

[១១:០៧:៣៤]

**ឆ៖** សមរភូមិនៅឧដុង្គ គឺខាងទាហាន លន់ នល់ ក៏ស្លាប់ច្រើន មានទាំងរថពាសដែក មានអីគឺប៉ុន្តែខាងខ្ញុំនៅខាងត្បូងភ្នំអដ្ឋរស្ស ទេ។ ឯវ៉ៃឧដុង្គនេះ គឺខាងនិរតី ខាងកងទ័ពនិរតី។

**ស៖** ចុះតើកងវរសេនាតូចហ្នឹងត្រូវបានចាត់តាំងឱ្យទៅជួយសមរភូមិនៅវត្តវិហារខ្ពស់ដែរឬទេពេលនោះ?

**ឆ៖** អត់មានចាត់តាំងទៅវត្តវិហារខ្ពស់ទេ អង្គភាពខ្ញុំ ក្រែងតែវរសេនាធំផ្សេងទៀតក៏មិនដឹង។

**ស៖** ពាក់ព័ន្ធទៅនឹងផែនការរៀបចំវាយប្រហារ ឬក៏សមរភូមិនៅឧដុង្គហ្នឹង តើលោកដឹងទេថាអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការរៀបចំផែនការវាយប្រហារនៅឧដុង្គ?

**ឆ៖** ចំពោះផែនការរៀបចំសមរភូមិនៅឧដុង្គនេះ គឺខ្ញុំឃើញតែ មេបញ្ជាការកងពលខ្ញុំតែម្នាក់ឯងហ្នឹងឯង ហើយនិង ចេង អន ដែលគាត់ធ្លាប់ដឹកនាំចាស់ពីមុន និងក្រោយ -- មុនពីការចាត់តាំងកងពល។

[១១:០៩:២១]

**ស៖** លោកថា លោកឃើញមានតែមេបញ្ជាការ ហើយនិង ចេង អន។ ខ្ញុំចង់សួរបញ្ជាក់ថាតើមេបញ្ជាការលោកហ្នឹងមានឈ្មោះអ្វី ហើយពេលដែលរៀបចំផែនការហ្នឹងមានការប្រជុំ ឬមានហេតុការណ៍កើតឡើងខ្លះ?

**ឆ៖** ខ្ញុំចង់បញ្ជាក់ថា ការរៀបចំផែនការវ៉ៃឧដុង្គ គឺខ្ញុំឃើញតែមេបញ្ជាការកងពលរបស់ខ្ញុំ ហើយនិង ចេង អន ទេគេអ្នករៀបចំផែនការ។ ហើយក្រៅពីនោះ ខ្ញុំមិនទាន់មានឃើញពីណាប្លែកទេ។

**ស៖** តើលោកបានឃើញមេបញ្ជាការរបស់លោកជាមួយនឹង ចេង អន ហ្នឹងប្រជុំ ហើយផ្សព្វផ្សាយបញ្ជា ឬក៏មានហេតុការណ៍អីកើតឡើងនៅពេលដែលលោកបានទទួល បានដឹងថា មានការរៀបចំផែនការហ្នឹង?

**ឆ៖** ខ្ញុំបានទទួលបញ្ជាពីបញ្ជាការកងពល និងចេង អន ហៅឲ្យខ្ញុំទៅជួបធ្វើការនៅ ហៅថាស្ពឺអំពិលរូងអីចេះមិនដឹង ជាប់ផ្លូវលេខ៦ ភូមិអំពិលរូង។

**ស៖** អ៊ីចឹងបានន័យថា លោកបានទទួលបញ្ជាពីមេបញ្ជាការ និង ចេង អន ហៅទៅជួបដើម្បីរៀបចំផែនការប្រយុទ្ធនៅឧដុង្គ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

[១១:១១:២៦]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចាស អរគុណ។ សូមឲ្យលោកជម្រាបដល់អង្គសវនាការផងដែរថា តើមានរឿងអ្វីកើតឡើងចំពោះប្រជាជននៅក្នុងក្រុងឧដុង្គ បន្ទាប់ពីខ្មែរក្រហមបានគ្រប់គ្រងក្នុងឆ្នាំ១៩៧៤?

**ឆ៖** ដូចដែលខ្ញុំបានជម្រាបហើយ គឺបញ្ជាផ្ទាល់ខ្លួន និងអង្គភាពខ្ញុំ គឺមិនបានទៅវ៉ៃឧដុង្គទេ ប៉ុន្តែគ្រាន់ថា មានផែនការរួមក្នុងកងពល គឺថាខាងនិរតីវ៉ៃចូលឧដុង្គហើយ ដូច្នេះខ្ញុំកម្លាំងយើងអាចទៅការពារខាងត្បូងអង្គរស្ស ក្រែងលោខ្មាំងសត្រូវវាឡើងពីហ្នឹងទៅជួយខាងនិរតី ខាងឧដុង្គ។ ហើយបញ្ជារំដោះហើយប្រជាជនយ៉ាងណាអីខាងខ្ញុំមកសមរភូមិខ្ញុំក៏បាត់ដឹងវិញអស់ហើយ។

[១១:១២:២៣]

**ស៖** ចាស សូមអរគុណ។ តើលោកបានដឹងទេថា តើមានប្រជាជនទីក្រុង ឬប្រជាជននានាដែលកងទ័ពខ្មែរក្រហមគ្រប់គ្រងមុនឆ្នាំ៧៥ ហ្នឹងត្រូវបានជម្លៀសចេញពីផ្ទះរបស់ពួកគេ និងបានផ្លាស់ទីទៅសហករណ៍ ឬទៅកន្លែងផ្សេងទៀតនៅតាមជនបទនោះ?

**ឆ៖** ចំពោះបញ្ហាប្រជាជនជម្លៀសមុន៧៥ គឺខាងខ្ញុំអត់ដឹងទេ ពីព្រោះខាងខ្ញុំនៅតែខាងមុខនេះ

ឯង។ មិនដឹងគេជម្លៀសកន្លែងណា ដល់ណាៗ ហើយធ្វើអីៗ ខ្ញុំមិនដឹង។

**ស៖** តើនៅក្នុងអំឡុងឆ្នាំ៧៥ហ្នឹង នៅពេលដែលលោកឈរជើងនៅម្តុំសមរភូមិនៅឧដុង្គនុំង លោកមានឃើញប្រជាជនមានបំលាស់ទីច្រើន មានការចាកចេញពីផ្ទះ លំនៅដ្ឋានអីច្រើនទេនៅពេលហ្នឹង?

[១១:១៣:៣២]

**ឆ៖** ដូចខ្ញុំជម្រាបហើយ គឺថាខ្ញុំអត់បានទៅនៅសមរភូមិឧដុង្គទេ។ ខ្ញុំនៅម្តុំប្រសិទ្ធិ ម្តុំបាត់ដឹងជាមូលដ្ឋានរបស់ខ្ញុំឯណោះ។ ឯខាងឧដុង្គ ខាងអី គឺខាងនិរតី ប៉ុន្តែការវ៉ៃអី គឺមេបញ្ជាការកងពលខ្ញុំគ្រាន់តែប្រាប់ថា ឥឡូវហ្នឹងគឺប្រយ័ត្នពីខាងត្បូង ខាងជើងគេវ៉ៃឧដុង្គហើយ តែប៉ុណ្ណឹងឯង។

**ស៖** ចាស សូមអរគុណ។ នៅក្នុងអំឡុងមុនខែមេសា ឆ្នាំ៧៥ សូមលោកជួយរៀបរាប់អំពីខ្សែសង្វាក់នៃការបញ្ជាពីថ្នាក់លើមកថ្នាក់ក្រោម តើលោកបានដឹងថាថ្នាក់លើបំផុតជាអ្នកណា ហើយបញ្ជាតាមមធ្យោបាយណាមកថ្នាក់ក្រោម?

**ឆ៖** បញ្ជាក្រោយពីយើងវ៉ៃឧដុង្គហើយៗមក គឺយើងមាន ដូចបានទទួលដំណឹងថាមានខាងលើមកៗទទួលការដឹក -- មកមានដឹកនាំនៅអង្គភាពខាងទិសរបស់ភូមិភាគនិរតីហើយ គឺ -- អ៊ំ! ភូមិភាគពិសេសហើយ ហើយខាងលើហ្នឹងគឺ សុន សេន ដែលហៅ ខៀវ នោះ។

**ស៖** អ៊ីចឹងចង់សួរលោកបញ្ជាក់ថា តើ សុន សេន ហៅ ខៀវ ដែលលោកសំដៅដល់ហ្នឹងគាត់ដាក់បញ្ជា ឬចេញបញ្ជាមកថ្នាក់ក្រោម ឬមកកងពលតូចលេខ ១៤ហ្នឹងយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំចង់ជម្រាបអស់លោកថា ធម្មតាគឺការងារនេះ មិនមែនខាងលើៗហៅអ្នកខាងក្រោមទៅទេ ទាល់តែខាងលើមកហៅកងពលៗ បានហៅវរសេនាធំ ឬវរសេនាតូចទៅជួប។ ដូច្នេះខាងខ្ញុំគឺមានតែ កងពលទេហៅទៅជួប។ ហើយការងារពិសេសបានខាងលើហៅទៅផ្ទាល់តែម្តង។

[១១:១៦:៣០]

**ស៖** ចាស សូមអរគុណ។ តើការងារពិសេសដែលលោកសំដៅដល់ទើបថ្នាក់លើហៅទៅជួបផ្ទាល់ហ្នឹង សូមលោកជួយលើកឧទាហរណ៍មើល៍តើមានការងារពិសេសអីខ្លះដែលអាចទៅជួបផ្ទាល់បាន?

**ឆ៖** ខ្ញុំចង់និយាយថា ឧបមាថាសមរភូមិៗដែលត្រូវវ៉ៃ ដូច្នេះអាហ្នឹងគេហៅថាការងារពិសេសហើយ។ ដូច្នេះខាងលើមិនមែនហៅតែកងពលទៅទេ គឺហៅទាំងវរសេនាធំ ទាំងវរសេនាតូចទៅរៀបចំ

យ៉ាងម៉េចដើម្បីឲ្យដំណើរនេះឲ្យសម្រេច នេះការងារពិសេស។

**ស៖** តើខ្ញុំយល់ ជាការត្រឹមត្រូវទេ មានន័យប្រសិនបើពាក់ព័ន្ធនឹងការងារវ៉ៃ ត្រូវប្រយុទ្ធត្រូវអីថ្នាក់លើហៅទាំងកងពល ទាំងវរសេនាធំ វរសេនាតូចទៅជួបទាំងអស់ ហើយទទួលបញ្ជាផ្ទាល់ពីថ្នាក់លើតែម្តង អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ប៉ុន្តែជាមូលដ្ឋានគឺមិនមែនជាខាងលើហៅ ចេះតែហៅទៅរាល់ថ្ងៃរាល់ពេលទេ ទាល់តែមានអីពិសេស ដូចខ្ញុំថាអ៊ីចឹង។

**ស៖** សូមអរគុណ។ តើមេបញ្ជាការមូលដ្ឋានណាមួយដែលលោកអាចមានទំនាក់ទំនងតាមវិទ្យុបាន?

**ឆ៖** ឯសម្រាប់ខ្ញុំទាក់ទងមានវិទ្យុបាន ទាក់ទងតែត្រឹម ដែលមេកងពលរបស់ខ្ញុំហ្នឹងឯង។

**ស៖** តើលេខកងពលហ្នឹងចង់សំដៅថា មានអ្នកទទួលផ្ទាល់ ហើយអ្នកទទួលហ្នឹងមានឈ្មោះអីដែរអត់ទេ?

**ឆ៖** មានអ្នកទទួលហ្នឹងមានតែអ្នកកាន់តេអូនៅក្នុងកន្លែងកងពលហ្នឹងឯង គឺគេហៅថាលេខ ០៥៧ ហ្នឹងគឺដឹងថាលេខកងពលហើយ។

[១១:១៩:០៩]

**ស៖** ហើយជាក់ស្តែងនៅពេលប្រយុទ្ធ ឬនៅក្នុងសមរភូមិអីហ្នឹង លោកមានដែលបានទទួលបញ្ជាតាមរយៈវិទ្យុទាក់ទងទេថា បញ្ជាតាមវិទ្យុទាក់ទងឲ្យទៅប្រយុទ្ធនៅកន្លែងនេះ ឬកន្លែងនោះ ដូរទិសដៅអីយ៉ាងម៉េច?

**ឆ៖** បាទពេលខ្លះមានដែរ តែពេលខ្លះគឺមុននឹងផ្លាស់ទៅណា គឺមិនរហ័សរហួនពេកក៏ត្រូវតែជួបគ្នាដើម្បីដោះស្រាយអារម្មណ៍នៅក្នុងអង្គភាព ឬក៏នៅក្នុងមេបញ្ជាការដែរ។ បើពេលណាពិសេសគឺហៅភ្លាមគឺទៅភ្លាម។

**ស៖** ចាស សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកលើកទី២ គឺនៅឯកសារ E3/84 នៅត្រង់ខ្មែរ ERN គឺ 00398518, ERN ជាភាសាអង់គ្លេស គឺ 00408400, ERN ជាភាសាបារាំង គឺ 00434427។ ពេលនោះ អ្នកស៊ើបអង្កេតបានសួរសំណួរលោក ហើយលោកបានរំឭកដល់ថ្ងៃទី២៣ ខែតុលា នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ លោកបានរៀបរាប់អំពីកិច្ចប្រជុំមួយនឹង សុន សេន ដែលបានធ្វើឡើង ដកស្រង់ "១៥ថ្ងៃមុនការវាយ

ចូលទីក្រុងភ្នំពេញ នៅឯដំណាក់ស្ដេច នៅជិតឧដុង្គក្នុងខេត្តកំពង់ស្ពឺ"។ សំណួរដែលខ្ញុំចង់សួរលោក នៅពេលនេះ ចង់សួរថា តើកិច្ចប្រជុំនោះ បានពិភាក្សាការងារអ្វីខ្លះ?

[១១:២១:១១]

**ឆ៖** ខ្ញុំឆ្លើយនឹងសំណួរនេះ គឺមុននឹង -- ដែលឆ្លើយនឹងសំណួរនេះ ខ្ញុំបញ្ជាក់ថា មិនមែននេះទេ គឺខាងត្បូងរ៉ាដំណាក់ស្នាច់ ហ្នឹងហើយ មុននឹងវ៉ៃចូលភ្នំពេញនេះ គឺ សុន សេន បានហៅទាំងកងពល ហៅទាំងវរសេនាតូច វរសេនាធំ ខាងបញ្ជានយោបាយ ហៅទៅជួប ហ្នឹងហើយ ហៅទៅជួប នៅខាងត្បូងដំណាក់ស្នាច់។ ផែនការទៅជួប គឺទី១ គឺរៀបចំសតិអារម្មណ៍នយោបាយ ដើម្បីវ៉ៃសម្រុកចូលភ្នំពេញ បាទ។ ទី២ ការរៀបចំចាត់តាំងកម្លាំង មានពួក មានក្រុម។ ហើយទី៤ ការងារនយោបាយសតិអារម្មណ៍នេះឯង។ មានតែប៉ុណ្ណឹង។ ហើយទី៣ទៀត គឺបើសិនណាជា វ៉ៃចេះតែទៅមុខ គឺថាធ្វើម៉េចខំរំដោះឲ្យបាន បាទ ដូចខ្ញុំបានបញ្ជាក់នៅក្នុងសំណួរដែលខ្ញុំឆ្លើយហ្នឹង គឺអត់មានរឿងបញ្ជាជម្លៀសប្រជាជនដូចអត់មាន -- គាត់មិនមាននិយាយទេ ធ្វើម៉េចភារកិច្ចរបស់យើង គឺវ៉ៃទៅមុខរំដោះភ្នំពេញ។ ខ្ញុំឆ្លើយប៉ុណ្ណឹង។

**ស៖** ចាស ចុះនៅពេលហ្នឹង សុន សេន មានតំណែងជាអ្វី? ហើយគាត់មានមន្ទីរ ឬក៏បញ្ជាការដ្ឋានផ្ទាល់នៅឯខាងត្បូងរ៉ាដំណាក់ស្នាច់ហ្នឹងទេ?

**ឆ៖** តាមខ្ញុំទៅជួប គឺថាដូចមកតែមួយថ្ងៃ ឬក៏ពីរថ្ងៃប៉ុណ្ណឹងឯង អត់មានឃើញកន្លែងអី មានផ្ទះមានសម្បែងទេ នៅតាមតែគុម្ពឫស្សីគុម្ពអីហ្នឹង ព្រោះទៅធ្វើទីតាំងឯណា បើកប៉ាល់ហោះវាទម្លាក់ហើយកន្លែងហ្នឹង សុទ្ធតែ១០៥ ពីប្រសិទ្ធីអីទៅដល់។ មកធ្វើការមួយភ្លែតៗ អាច១ថ្ងៃ ឬ២ថ្ងៃ ហ្នឹង គេចបាត់ហើយ។ ហើយគេចហ្នឹង មិនដឹងទៅឯណា បើមិនដែលជួប ទើបតែមកជួបមុនរៀបចំផែនការវ៉ៃហ្នឹង។

[១១:២៣:៥១]

**ស៖** ចុះពេលដែលលោកជួប សុន សេន ពេលហ្នឹង តើលោកដឹងទេ ថាគាត់មានតួនាទី ឬក៏តំណែងអីដែរ?

**ឆ៖** ខ្ញុំជួប សុន សេន ពេលនោះ គឺខ្ញុំមិនបានដឹងអំពីតួនាទីតំណែងរបស់គាត់យ៉ាងណាទេ។ ប៉ុន្តែ ០៦ នេះ ដែលជាកងប្រមូលម្ដុំគ្នា រៀបចំកងពលដែលមកពី ន៉ែ ០៦ ជាប់នឹង០៦ នេះ គឺ០៦ នេះ ជាប់ជាមួយ សុន សេន នេះឯង។ គាត់ គេហៅតែ តាវ៉ែនតាៗ ទេ។ ដូច្នេះ ភារកិច្ច ឬនាទីអី ក៏ខ្ញុំអត់ដឹង

ហើយគេក៏មិនប្រាប់ គ្រាន់គេថា តាវ៉ៃនតា នេះមិនបានទេ មានតែប៉ុណ្ណឹង។ តែនាទីអីគាត់ ខ្ញុំមិនយល់ ខ្ញុំមិនដឹង។

**ស៖** ចាស សូមអរគុណ។ ពាក់ព័ន្ធទៅនឹង សុន សេន នេះដែរ លោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅត្រង់ឯកសារ E3/84 ERN ជាភាសាខ្មែរ គឺ 00398518 ដល់19, ជាភាសាអង់គ្លេសគឺ 00408400, ជាភាសាបារាំងគឺ 00434427។ លោកបានប្រាប់អ្នកស៊ើបអង្កេតថា "នៅក្នុងពេលប្រជុំ សុន សេន បានបង្រៀនថា ធ្វើយ៉ាងម៉េចវ៉ៃឲ្យភ្នំពេញដាច់ឆាប់ និងថាគាត់បានចង្អុលផែនទីបង្ហាញផ្លូវ ដើម្បីវាយប្រហារចូលទីក្រុងភ្នំពេញ"។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើកងពលតូចលេខ១៤ មានបានរៀបចំទីតាំងជាក់លាក់ដែលត្រូវវាយប្រហារនិងចូលទីក្រុងភ្នំពេញទេ នៅពេលប្រជុំជាមួយ សុន សេន ពេលនោះ?

**ឆ៖** ក្នុងកងពល១៤ ដែលរៀបចំផែនការជួបជាមួយសុន សេន ហើយ តាមពិតគឺ ពេលនោះគឺគ្មានទីតាំងអីទេ គឺនៅតាមជាដុបៗ ហើយទៅវ៉ៃ គឺទៅវ៉ៃបណ្តោយ អត់មានទីតាំង មានកន្លែងណាអីនៅជាក្រឹត្យក្រមទេ។ នៅជាពួក ជាក្រុមៗ ការពារកប៉ាល់ហោះដែរហ្នឹង។

[១១:២៦:៣៣]

**ស៖** អ៊ីចឹងចង់សួរថា តើកងពលតូចលេខ១៤ហ្នឹង វាយចូលភ្នំពេញតាមច្រកណា? មានន័យថាចាប់ផ្តើមពីច្រកណា ហើយវាយចូលដល់ភ្នំពេញតែម្តងចូលទីតាំងកន្លែងមួយណា?

**ឆ៖** គឺកងពលលេខ១៤ គឺវ៉ៃចូលភ្នំពេញតាមប្រឡោះពូនភ្នំ ហើយប្រឡោះវត្តតាំងកសាងនេះ។

**ស៖** ចុះពេលចូលទៅដល់ភ្នំពេញ ចូលដល់កន្លែងណាមុន?

**ឆ៖** ហើយវ៉ៃចូលទីតាំងដែលវ៉ៃចូលភ្នំពេញនេះគឺ ខ្ញុំនិយាយពីអង្គភាពខ្ញុំ គឺខ្ញុំវ៉ៃម្តុំពោធិ៍ចិនតុងនេះឯង ហើយតទៅក្រោយវ៉ៃតាមផ្លូវលេខ៤ អាហ្នឹងខាងភូមិភាគនិរតី ហើយខាងត្បូងផ្លូវមកចូលភ្នំពេញដែរ ខាងត្បូងផ្លូវ ខាងនិរតីទេ។ ដូច្នេះ គឺតាមការវ៉ៃចូលភ្នំពេញ គឺខាងខ្ញុំវ៉ៃចូលត្រឹមពោធិ៍ចិនតុងដល់វត្ត -- ដល់ត្រឹមពោធិ៍ចិនតុងក៏ត្រូវរបួស ខ្ញុំក៏ទៅឲ្យពេទ្យធ្វើនៅវត្តតាំងកសាងនេះឯង។ ហើយប៉ុន្តែគេចេះតែបន្តវ៉ៃតទៅទៀត។ ហើយខ្ញុំទៅនៅវត្តតាំងកសាងទៅ -- អូ៎នៅវត្ត អត់ទេនៅវត្តហ្នឹងឯង។ វត្តជាប់នឹងពោធិ៍ចិនតុងខាងលិច ជាប់ផ្លូវរទេះភ្លើង។

**ស៖** នៅពេលដែលលោកវាយពីវត្តតាំងកសាង ហើយចូលមកតាមច្រកពោធិ៍ចិនតុងនេះ មុនពេលដែលលោកត្រូវរបួស ចង់សួរថា តើអំឡុងពេលវាយចូលភ្នំពេញនេះ មានរឿងអ្វីខ្លះកើតឡើងចំពោះ

ទាហាន លន់ នល់ ដែលត្រូវចាប់ខ្លួន ឬដែលចុះចាញ់?

**ឆ៖** ដូចខ្ញុំបានជម្រាបពីខាងដើមមកហើយ គឺចំពោះបញ្ហាមុននឹងវៃចូលដល់ភ្នំពេញនេះ ហើយជម្លៀសទាហានដែលឈ្លើយសឹក ចង់និយាយអ៊ីចឹងចុះ គឺនៅតាមសមរភូមិដែលចាប់បាន គឺដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាបញ្ជូនទៅក្រោយ។ ខ្ញុំយល់ថាបញ្ជូនទៅក្រោយ ប៉ុន្តែមិនដឹងទៅខាងណាបើខ្ញុំមិនដែលទៅក្រោយសោះ នៅខាងមុខ មិនដឹងយកទៅធ្វើអី មិនដឹងការងារអី សុខទុក្ខអីយ៉ាងម៉េចក៏ខ្ញុំមិនដឹង។

[១១:២៩:២០]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងការជម្លៀសលើកទី១ លោកបាននិយាយប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរនៅត្រង់ឯកសារ E3/84 គឺនៅERN ជាភាសាខ្មែរ 00398519, ERN ជាភាសាអង់គ្លេស គឺ00408400 និងERN ជាភាសាបារាំងគឺ 00439428។ នៅពេលនោះលោកបានប្រាប់ថា លោកត្រូវរបួសក្នុងពេលវាយចូលទីក្រុង ភ្នំពេញ ក្នុងពេលដែលលោកបានចូលពោធិ៍ចិនតុង ក៏ប៉ុន្តែលោកបានឃើញប្រជាជនកំពុងចាកចេញពីទីក្រុងភ្នំពេញ ហើយបានប្រាប់ថា ពួកគេបានត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹង សំណួរដែលខ្ញុំចង់សួរ លោកពេលនេះ ចង់សួរថាតើស្ថានភាព ឬសកម្មភាពប្រជាជនដែលលោកបានឃើញចាកចេញពីទីក្រុងភ្នំពេញ ឬត្រូវគេជម្លៀសចេញពីទីក្រុងភ្នំពេញហ្នឹង មានសកម្មភាព ឬស្ថានភាពបែបណាដែរពេលនោះ?

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយគឺថា ខ្ញុំវៃតែចូលដល់ត្រឹមជិតពោធិ៍ចិនតុង ហើយកម្លាំងខ្ញុំចូលក្នុងផ្ទះថ្ម ផ្ទះអីហើយ ប៉ុន្តែខ្ញុំដល់ខាងលូខាងលិចពោធិ៍ចិនតុងបន្តិចហ្នឹង ក៏ត្រូវរបួសទៅដេកវត្តតាំងកសាងហ្នឹងហើយ។ ត្រូវរបួសត្រូវអីហ្នឹងហើយ ហើយដល់អ៊ីចឹងមួយស្របក់ក្រោយមក គឺថា ចូលដល់ត្រង់នេះ ត្រង់នោះ ចេះទៅមុខហើយ ហើយខ្ញុំសួរថា “ខាងណាចូលបានមុន គេថា អ្ហ៎! ពីខាងត្បូង ហើយពីខាងនិរតីនេះទៅ ហើយយើងម៉េចអ៊ីចុះ! ថាយើងជាប់តែគ្នាទាំងអស់ហ្នឹងឯង”។ ហើយដល់អ៊ីចឹង ១ម៉ោង ២ម៉ោងក្រោយមក ក៏ឃើញប្រជាជនចេញ។ ដល់សួរប្រជាជនចេញ ខ្ញុំក៏សួរថា “ចុះប្រជាជនទៅខាងណានេះ? ថាមិនដឹង ឮតែគេដេញពីភ្នំពេញថា ឲ្យទៅៗ ប៉ុណ្ណឹងឯង”។ ដូចខ្ញុំបានបញ្ជាក់ហើយការសុខទុក្ខអីយ៉ាងម៉េច គឺខ្ញុំមិនដឹងទេ មិនដឹងគេយកទៅដាក់ឯណា ឬមានហេតុការណ៍អីក៏ គេភ្លាប់សភាពការណ៍អី ខ្លាំង អ៎! សត្រូវមកទម្លាក់អី ខ្លាចស្លាប់ប្រជាជនយ៉ាងម៉េចក៏មិនដឹង។

[១១:៣១:៥៥]

**ស៖** ចាស សូមអរគុណ។ ចុះនៅពេលដែលលោកបានឃើញប្រជាជនចាកចេញពីទីក្រុង

ភ្នំពេញហ្នឹង តើលោកឃើញប្រជាជនដើរដោយថ្មើរជើង ឬក៏ប្រជាជនទាំងអស់ហ្នឹងត្រូវបានគេដឹកជញ្ជូនចេញ ឬក៏មានការបង្ខំឱ្យចាកចេញដែរ?

**ឆ៖** បាទ តាមពិតខ្ញុំដឹងថា ប្រជាជនគ្មានទេ គ្មានរឿងដឹកជញ្ជូនទេ មានតែថ្មើរជើងហ្នឹងកង់ហ្នឹង រទេះរុញអីនាយអាយប៉ុណ្ណោះឯង។ ឱ្យមានឡាន ឱ្យមានអ្នកដឹកជញ្ជូនអត់មានទេ ព្រោះខ្ញុំចេញ ពីវត្តតាំង-- អ៎! មើលពីវត្តតាំងកសាងឃើញមនុស្សព្រាត តាមផ្លូវក៏មាន តាមវាលស្រែក៏មាន។ ចុះមនុស្សពេញតែផ្លូវទៅហើយ ដើរតាមផ្លូវមិនបាន មានតែកាត់វាលស្រែ កាត់ព្រៃអីចឹងទៅ។ ខ្ញុំមើលឃើញអីចឹង អត់មានឃើញ ដឹកម្តង ១០ឡាន ឬក៏២០ឡានអី ជូនទៅនេះ ទៅនោះ អត់ទេ។

**ស៖** ចុះពេលដែលលោកឃើញប្រជាជនដើរដោយថ្មើរជើង ឬអ្នកខ្លះរុញរទេះ មានរទេះអីចាកចេញហ្នឹង មានឃើញទាហានខ្មែរក្រហមនៅពីខាងក្រោយដើម្បីស្តកដំណើរពួកគាត់ទៅ ឬក៏ប្រជាជនដើរស្រេចតែចិត្តបានពេលនោះ?

[១១:៣៣:២២]

**ឆ៖** ខ្ញុំអត់បានដឹងថាមានខ្មែរក្រហមអី ទាហានខ្មែរក្រហមអី រុញពីក្រោយអី ប្រជាជនអីក៏មិនបានឃើញទេ ប៉ុន្តែគ្រាន់ថា ប្រជាជនចេះតែទៅអីចេះឯង។ ហើយតាមពិតទាល់តែមានកម្លាំង ថាទៅៗឱ្យលឿនៗ បានទៅបាន។ បើមិនអីចឹងទេ មិនទៅទេ។ ព្រោះស្រុក ផ្ទះគាត់ ភូមិគាត់ ស្រុកគាត់ ដូច្នេះគាត់ចង់ទៅធ្វើអីគាត់។ ដូច្នេះ ទាល់តែបង្ខំ ទាល់គំរាមកំហែង បានគាត់ទៅ។

**ស៖** តើខ្ញុំយល់ជាការត្រឹមត្រូវទេ មានន័យថាប្រជាជន មិនបានស្ម័គ្រចេញទេ គឺមានការគំរាមកំហែង ឬក៏បង្ខំឱ្យចាកចេញ ទើបពួកមានការចាកចេញឱ្យឆាប់រហ័ស?

**ឆ៖** ត្រឹមត្រូវហើយទាល់តែមានការបង្ខំបានប្រជាជនចេញ បើឱ្យស្ម័គ្រចិត្តចេញ អត់ចេញទេ ព្រោះធម្មតាប្រជាជន ភូមិណាក៏ដូចជាកន្លែងណាដែរ ធម្មតាបើលំបាកវេទនាយ៉ាងម៉េច ប៉ុន្តែជាទឹកដីជាស្រុករបស់គាត់ គាត់ចង់ទៅធ្វើអីកន្លែងផ្សេង កន្លែងដែលលំបាក។ ដូចនៅកន្លែងគាត់ដែលលំបាកហើយក៏គាត់ចង់កន្លែងលំបាកហ្នឹងឯង។ ចង់និយាយអីចឹង។

**ស៖** ចាស សូមអរគុណ។ លោកថានៅពេលដែលលោកវាយប្រយុទ្ធមកពីវត្តតាំងកសាងចូលមកតាមច្រកពោធិ៍ចិនតុងហ្នឹងគឺកងពលរបស់លោកហ្នឹងគឺវាយសម្រុកមកមុខរហូត។ តើនៅពេលដែលលោកវាយ សម្រុកមកមុខរហូតហ្នឹង លោកមានដែលឃើញប្រជាជនដែលទៅហើយត្រឡប់មកវិញទេ ឬក៏មានតែអ្នកដែលចាកចេញពីភ្នំពេញតែម្តង អត់មានអ្នកត្រឡប់មកវិញទេ?

**ឆ៖** បាទ ឃើញតែប្រជាជនចេញទេ ឯចូលក៏មានដែរ ប៉ុន្តែមិនដឹងជាទាហាន មិនដឹងជាស៊ីវិល -- ស៊ីវិលទេ ព្រោះជួនកាលប្រជាជនពីខាងដីរំដោះក៏ចង់មកភ្នំពេញដែរ។ ដូច្នេះច្របូកច្របល់គ្នា មិនដឹងណាថ្មីអាណាចាស់អីទេ។ ខ្ញុំមើលឃើញអ៊ីចឹងឯង។

[១១:៣៥:៤១]

**ស៖** ចុះតាមការសង្កេតរបស់លោកផ្ទាល់ហ្នឹង លោកមានដែលឃើញមានកន្លែងត្រួតពិនិត្យ ឬក៏កុងត្រូលពិនិត្យនៅតាមបរិវេណច្រកភ្នំពេញហ្នឹង ដើម្បីត្រួតពិនិត្យថា ប្រជាជនហ្នឹងប្រសិនបើចង់ត្រឡប់មកវិញ គឺត្រូវឆ្លងកាត់ ឬក៏អត់អនុញ្ញាតឲ្យចូលមកវិញទេ។ មានឃើញដែលមានឃើញប៉ុស្តិ៍ត្រួតពិនិត្យ ឬក៏កន្លែងត្រួតពិនិត្យអ៊ីចឹងទេ នៅពេលដែលវ៉ៃសម្រុកចូលមកនោះ?

**ឆ៖** មិនមានឃើញកន្លែងត្រួតពិនិត្យទេ។

**ស៖** ពាក់ព័ន្ធទៅនឹងទាហានលន់ នល់ ឬក៏ប្រជាពលរដ្ឋដែលជាប់ពាក់ព័ន្ធនឹងរបប លន់ នល់ តើលោកមានបានដឹងទេថា មានការព្យាយាមកំណត់ ឬក៏បែងចែកអត្តសញ្ញាណប្រជាជនដែលមានជាប់ពាក់ពន្ធនឹងរបប លន់ នល់ នៅក្នុងអំឡុងពេលជម្លៀស ក៏ដូចជាក្រោយពេលជម្លៀសហ្នឹង?

**ឆ៖** ខ្ញុំឃើញថា បើទាហានគឺបែងចែក គ្រាន់តែថានេះជាទាហានរបស់ លន់ នល់។ បែងចែងអ៊ីចឹងឯង។ នេះបើប្រជាជនវិញ គឺអត់មានឮថាបែងចែកប្រជាជនអីខាងណេះប្រជាជនណោះអីទេ។

[១១:៣៧:០៨]

**ស៖** ចុះពេលហ្នឹង តើកងពលតូចលេខ១៤ ត្រូវបានរៀបចំឲ្យយាមកាមនៅស្តាតអូឡាំពិក បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបានដែរឬទេ? មានការរៀបចំអ៊ីចឹងទេ?

**ឆ៖** បាទ រៀបចំអ៊ីចឹងមែន គឺតាមពិតគឺកងពលលេខ១៤ គឺរៀបចំពីពេទ្យលោកសង្ឃមកទាល់នឹងពហុកីឡាដ្ឋានជាតិអូឡាពិក។

**ស៖** តើនៅពេលដែលលោកស្នាក់នៅមន្ទីរពេទ្យរយៈពេលប៉ុន្មាន បន្ទាប់ពីលោកត្រូវរបួសក្នុងការវាយយកទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** ខ្ញុំសម្រាកពេទ្យប្រហែលជាប្រាំពីរប្រាំបីដណ្តប់ថ្ងៃប៉ុណ្ណោះឯង នៅខាងលិចវត្តតាំងកសាងទេ។ ពេលដែលធ្វើរបួសនៅវត្តតាំងកសាង ប៉ុន្តែទៅសម្រាកនៅវត្តពូនភ្នំ ព្រោះកន្លែងនោះបើសិនណាជានៅបានយូរ គឺត្រូវ -- គឺថាត្រូវរៀបចំធ្វើដាំនេះដាំនោះអី ចិញ្ចឹមកងទ័ព ព្រោះឮរហិចរហៀងថាកងទ័ពទៅវ៉ៃហើយឲ្យទៅនៅតាមជាយៗក្រុងដាំ។ ដូច្នេះមានទិសដៅ គឺកម្លាំងទៅនៅខាងវត្តពូនភ្នំ ម្ដុំស្ទឹ

ហ្នឹងមួយចំនួនហើយ។

[១១:៣៨:៥៦]

**ស៖** ចុះបន្ទាប់ពីលោកត្រូវរបួស សម្រាកព្យាបាលអស់ជាង១០ថ្ងៃហ្នឹង ប្រាំពីរប្រាំបីដណ្ដប់ថ្ងៃហ្នឹង លោកមានបានត្រឡប់ចូលរួមជាមួយនឹងកងពលតូចវិញទេ? ហើយប្រសិនបើចាប់ផ្ដើមត្រឡប់ចូលវិញហ្នឹង តើលោកចូលរួមនៅពេលណា? ហើយពេលហ្នឹងកងពលរបស់លោកហ្នឹងមានទីតាំងឈរជើងនៅកន្លែងណា?

**ឆ៖** ខ្ញុំក្រោយពីដេកពេទ្យកន្លងមកនេះគឺ ខ្ញុំមិនទាន់បានទៅជួបកងពលតូចនៅភ្នំពេញទេ។ ប៉ុន្តែអ្នកដែលបន្ទាប់ពីខ្ញុំគឺនៅជាប់នឹងអង្គភាព ដែលនៅខាងក្នុងភ្នំពេញហ្នឹងហើយគឺ សឿន។ ឯងខ្ញុំនៅខាងណោះ គឺរៀបចំនៅខាងក្រោយ បាទ។ គ្រាន់តែប្រាប់ថាកងយើងនៅម្ដុំតាមពេទ្យលោកសង្ឃ ហើយនិងខាងលិចពហុកីឡាដ្ឋានតែប៉ុណ្ណឹងឯង។ ហើយសល់ប៉ុន្មាន គឺនៅម្ដុំ ដូចខ្ញុំបានមានមតិពីខាងដើម គឺព័ទ្ធពូនភ្នំ អាចន្លោះវត្តពូនភ្នំហ្នឹង នៅទំនប់ទឹកហ្នឹង។

**ស៖** ចុះពេលដែលលោកត្រឡប់ចូលមកសាជាថ្មីជាមួយនឹងពួកគេហ្នឹង តើពេលហ្នឹងលោកធ្វើការងារអ្វីខ្លះនៅទីនោះ?

**ឆ៖** គឺនៅពូនភ្នំមួយរយៈ គឺមេបញ្ជាកងពលហៅខ្ញុំមកហ្នឹង គឺថាសរសេរជាសំបុត្រទេ អញ្ជើញមកធ្វើការស្អែក ហ្នឹងហើយ។ មកធ្វើការហ្នឹង ខ្ញុំក៏មក ជិះម៉ូតូមក មកដល់ក៏ជួបហើយ គាត់ថាឥឡូវស្អែកខាងលើហៅជួប។ និយាយតែប៉ុណ្ណឹង ហើយក៏ម៉េចទៅយើងគិតរៀបរយយ៉ាងម៉េច កម្លាំងយ៉ាងម៉េចនៅកន្លែងអ្នកឯង កន្លែងណា? ខ្ញុំថាកម្លាំង ខ្ញុំរើកន្លែងណានៅកន្លែងហ្នឹង មិនមែនមកច្របូកច្របល់អីភ្នំពេញអីទេ ខ្ញុំថាអ៊ីចេះ។ មួយចំនួននៅការពារនៅហ្នឹងទៅ ប៉ុន្តែមួយចំនួននៅឯនោះ។ ហើយប៉ុណ្ណឹង ហើយគាត់ថា អើអ៊ីចឹងស្អែកចាំជួបគ្នា។ តែប៉ុណ្ណោះឯង។

[១១:៤១:២១]

**ស៖** ចុះនៅពេលដែលលោកត្រឡប់មកវិញ ហើយមេបញ្ជាការកងពលហៅទៅជួបហ្នឹងតើលោកបានទទួលតំណែង ឬតួនាទីអីដែរពេលហ្នឹង?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ពីខាងដើមអ៊ីចឹង គឺក្រោយពីរៀបចំកងពល មុនចូលភ្នំពេញនេះ គឺខ្ញុំជាវរសេនាធំហើយបាទ ដែលរើចូលនេះ។ ហើយគ្រាន់តែថាកងពលដែលចូលភ្នំពេញហើយ រើចូលភ្នំពេញហើយ គាត់ទៅនៅភ្នំពេញនេះ ខ្ញុំ ហៅខ្ញុំពីពូនភ្នំ ទៅជួប ថាស្អែកខាងលើហៅទៅជួបធ្វើការតែប៉ុណ្ណឹង។

**ស៖** ចាស សូមអរគុណ។ ចុះនៅក្នុងអំឡុងក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើលោកបានធ្វើការនៅខាងលិចបុរីកីឡា ហើយបានស្នាក់នៅក្នុងអតីតផ្ទះឈ្មោះ សក្តិសិទ្ធ សុខាន់ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំមិនបានដែលបាននៅផ្ទះកន្លែងហ្នឹងទេ ប៉ុន្តែខ្ញុំនៅខាងលិចផ្ទះហ្នឹង នៅនោះគឺ សឿនឈ្មោះ សឿន បញ្ញាការឈ្មោះ សឿន។

[១១:៤៣:០៦]

**ស៖** តើទីតាំងដែលលោកស្នាក់នៅហ្នឹង នៅខាងលិចបុរីកីឡាហ្នឹង អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយបាទ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ខ្ញុំនៅផ្ទះខាងលិចពហុកីឡដ្ឋាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចុះនៅពេលហ្នឹង តើលោកមានបានទទួលការងារដែលត្រូវធ្វើនៅបុរីកីឡាហ្នឹងទេ?

**ឆ៖** អត់មានបានទទួលការងារធ្វើនៅនឹងបុរីកីឡាហ្នឹងទេ។ នៅតាមផ្ទះណា គឺនៅតាមផ្ទះហ្នឹងអត់មានយាម អត់មានកាមអីទេ។

**ស៖** ចុះនៅពេលដែលលោកស្នាក់នៅផ្ទះនៅខាងលិចបុរីកីឡាហ្នឹង តើលោកមានបានដឹងទេថាតើបុរីកីឡាហ្នឹង គេប្រើប្រាស់ដើម្បីធ្វើអ្វីនៅពេលនោះ?

**ឆ៖** ខ្ញុំនៅខាងលិច បុរីកីឡាហ្នឹង គឺក្នុងបុរីកីឡាហ្នឹងទៀត ក៏ខ្ញុំមិនដឹងថា គេធ្វើអីដែរ។ ហើយពីមុនក៏មិនស្គាល់បុរីកីឡាហ្នឹងដែរ ឮតែគេនិយាយ។ ហើយគ្រាន់ថា យើង -- បើផ្ទះបងឯង ហៅគេអ៊ីចឹង ផ្ទះបងឯង ហៅខ្ញុំទៅធ្វើការហ្នឹង គឺផ្ទះបងឯងនៅខាងលិចបុរីកីឡាហើយ។ តែប៉ុណ្ណឹងឯង។ហើយការងារអីក្រៅពីហ្នឹង ខ្ញុំអត់ដឹងទេ។

[១១:៤៥:០៤]

**ស៖** ចាស ទាក់ទងទៅនឹង -- បន្ទាប់ពីថ្ងៃ១៧ មេសា ៧៥ ក្រោយមកលោកត្រូវបានផ្លាស់ទីឲ្យទៅឈរនៅទីតាំងនៅក្នុងភូមិភាគពិសេស ភូមិភាគឧត្តរ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនទេ។

**ស៖** អ៊ីចឹងចង់សួរលោកថា នៅក្នុងអំឡុងពេលពី ១៧មេសា ៧៥ រហូតដល់លោកត្រូវបានផ្លាស់ទីឲ្យទៅឈរនៅទីតាំងផ្សេង តើពេលហ្នឹងកងពលរបស់លោកហ្នឹងទទួលភារកិច្ច ឬក៏ការងារអ្វីខ្លះនៅក្នុងចន្លោះអំឡុងពេលហ្នឹង?

**ឆ៖** មុននឹងអង្គភាពផ្លាស់ទៅកន្លែងផ្សេងនៅក្នុង ១៩៧៥ គឺអង្គភាពដែលនៅភ្នំពេញនេះ តាមខ្ញុំមើលដូចអត់មានធ្វើការងារអីទេ។ គ្រាន់តែបោសច្រាសអីនាយអាយកំប៉ិកកំប៉ុកប៉ុណ្ណឹង ឲ្យស្អឹៗអត់ទេ។ មិនឃើញមានធ្វើអីទេ។

[១១:៤៦:២៨]

**ស៖** តើពេលហ្នឹងមានបានទទួលបញ្ជាត្រូវយាមកាម ត្រូវចែកវេនគ្នាឈរជើងនៅកន្លែងណាដើម្បីយាមកាមដែរឬទេពេលនោះ?

**ឆ៖** ពេលនោះ នៅដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាខាងខ្ញុំអត់មានបានចាត់ចែងកម្លាំងយាមកាមអីទេ។ ព្រោះថា ដូចតែនៅតែខាងក្នុងគេ។ មានគេខាងៗ ដូចខាងពោធិ៍ចិនតុងក៏គេនៅ ខាងស្ទឹងមានជ័យគេនៅ ខាងខ្ញុំនៅនេះគ្រាន់តែ អើល្បាតអីនាយអាយកំប៉ិកកំប៉ុកប៉ុណ្ណឹងទៅ។

**ស៖** ចាស អរគុណលោកសាក្សី។ បន្ទាប់មកទៀតនេះ ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធក្នុងកងទ័ពបដិវត្តន៍កម្ពុជា និងព័ត៌មានពាក់ព័ន្ធទៅនឹងកងពល៨០១ ក្នុងអំឡុងបន្ទាប់ពីថ្ងៃ ១៧ មេសា ឆ្នាំ៧៥។ អ៊ីចឹងសំណួរទី១ ដែលខ្ញុំចង់សួរលោក គឺពាក់ព័ន្ធទៅនឹងកិច្ចប្រជុំធំមួយ ឬការជួបជុំគ្នាធំមួយដែលបានធ្វើឡើងនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៧៥ ដែលព័ត៌មាន ឬកិច្ចការប្រជុំទាំងអស់នោះ ក៏មានចុះផ្សាយផងដែរ នៅក្នុងទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ដែលមុននឹងខ្ញុំអានព័ត៌មាន ហើយនិងសួរលោក ខ្ញុំចង់ផ្តល់លេខ ឯកសារ និងលេខ ERN ហើយសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារ និងបង្ហាញឯកសារនៅលើអេក្រង់។

[១១:៤៨:១៣]

លេខឯកសារ គឺ E3/5 លេខ ERN ជាភាសាខ្មែរគឺ 00063324, លេខ ERN ជាភាសាអង់គ្លេសគឺ 00411488, លេខ ERN ជាភាសាបារាំងគឺ 00538963។

**កញ្ញា សុង ឆវ័ន្ត៖**

សូមការអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ឯកសារ និងដាក់បង្ហាញឯកសារនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

[១១:៤៩:១៨]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំភ្ញាក់ផ្អើលដែលសហភាតារបស់ខ្ញុំមិនផ្តល់លេខERN ជាមុនអ៊ីចឹងយើងមិនអាចដឹងថា ឯកសារដែលសាក្សីកុំតែអានហ្នឹងជាឯកសារអីនោះទេ។ ថាយើងអាចដឹងបានទាល់តែថា យើងចូលទៅក្នុង អ៊ីនធឺណេត ឬហ្វាយឡេប ហ្នឹងមើល ចុះបើអត់ឲ្យយើងជាមុនអ៊ីចឹងយើងម៉េចដឹងថា ខ្លឹមសារជាក់លាក់ឯកសារហ្នឹងយ៉ាងម៉េចទៅ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមឆ្លើយតបជាមួយនឹងសហភាតា មុននេះខ្ញុំបានអានលេខឯកសាររួចហើយ ហើយខ្ញុំរីករាយនឹងអានម្តងទៀត ជូនដល់សហភាតា គឺលេខ ឯកសារE3/5 ERN ជាភាសាខ្មែរគឺ 00063324, ERN ជាភាសាអង់គ្លេសគឺ 00401488, និង ERN ជាភាសាបារាំង 00538963 ។ ហើយសំណួរដែលខ្ញុំ -- មុននឹងសួរសំណួរខ្ញុំចង់ ជម្រាបលោកថា ព័ត៌មាននេះ គឺនៅក្នុងទង់បដិវត្តកម្ពុជាចុះផ្សាយ ខែសីហា ឆ្នាំ១៩៧៥ ដែលនិយាយ អំពីកិច្ចប្រជុំមួយថ្ងៃទី២២ ខែកក្កដា ឆ្នាំ៧៥។ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សាក្សីពិនិត្យឯកសារហ្នឹងមើល ហើយឯកសារហ្នឹងលោកសាក្សីធ្លាប់បានស្គាល់ និងធ្លាប់បានឃើញឯកសារហ្នឹងពីមុនដែរឬទេ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ខ្ញុំពិនិត្យហើយ ខ្ញុំមិនដែលបានឃើញឯកសារនេះទេ។

[១១:៥១:២៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារពីសាក្សីវិញ ហើយមិនអនុញ្ញាតឱ្យដាក់បង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រទេ។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ខ្ញុំក៏សូមជំទាស់ទៅនឹងទម្រង់នៃការតាំងសំណួរនេះដែរ ដោយសារថាហាក់ដូចជាសហព្រះរាជអាជ្ញាផ្ដល់ព័ត៌មានទៅសាក្សីជាដំបូងសិនហើយ ឧទាហរណ៍។ គាត់បានប្រាប់សាក្សីមានកិច្ចប្រជុំនៅថ្ងៃនេះៗ វាជាជាង ការដែលគាត់តាំងសំណួរថាតើលោកបានចូលរួមនៅក្នុងប្រជុំថ្ងៃនេះៗឬយ៉ាងនេះទៅវិញ។ មានន័យម៉្យាងទៀតថា សហព្រះរាជអាជ្ញាកំពុងតែនាំមុខសាក្សីហើយ។ ដូច្នេះ ខ្ញុំគឺគិតថាគួរតែដូរបែបបទទម្រង់ នៃការសួរជាជាងការជជីកយកព័ត៌មានពីសាក្សីនេះ។

[១១:៥២:២៩]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស ខ្ញុំនឹងរៀបចំតាំងសំណួរជាថ្មី។ ហើយសំណួរទីមួយដែលខ្ញុំចង់សួរសាក្សី។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តើលោកមានដែលធ្លាប់ឮ ឬក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ៧៥ ដែលជាកម្មវិធីចាត់តាំងរបស់កងទ័ពបដិវត្តន៍មជ្ឈិមដែលមាន ពេលនោះមានសមាជិកចូលរួមប្រហែលជាបីពាន់នាក់ តើលោកចាំបានទេ ថាលោកមានបានធ្លាប់ចូលរួម ធ្លាប់ដឹងពីបញ្ហានេះទេ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** ខ្ញុំមិនធ្លាប់បានចូលរួមមនុស្សច្រើនកុះករ កងទ័ពច្រើនដូច្នេះទេ។

**ស៖** ចាស សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៅត្រង់ឯកសារ E3/84 ERN ជាភាសាខ្មែរគឺ 00398517, ជាភាសាអង់គ្លេសគឺ 00408399 និង ERN ជាភាសាបារាំងគឺ 00434426 ។ លោកបានប្រាប់អ្នកស៊ើបអង្កេតថាការតែងតាំង កងពល៨០១ គឺបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមួយនៅស្ដាតអូឡាំពិក ដែលមានថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ចូលរួម គឺមានប៉ុល ពត, នួន ជា, អៀង សារី, និង សុន សេន។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើការ តែងតាំងកងពល៨០១ គឺជាផ្នែក ឬក៏ជាកម្មវិធីមួយដែលបង្កើតឡើង ឬក៏ដាក់ចូលនៅក្នុងកម្មវិធីដែល មានកងទ័ពច្រើន

ចូលរួម មុននឹងដែលខ្ញុំរំឭកដល់តើអ៊ីចឹងមែនទេ ឬក៏វាជាកម្មវិធីមួយដាច់ដោយឡែកផ្សេង?

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ ចំពោះបញ្ហាការដែលបានសួរសំណួរអំមិញ គឺបញ្ជាក់ថាបានទៅជួប សុន សេន និងប្រមូលផ្តុំកងទ័ពអីទៅជួបនោះគឺ បញ្ហានោះ គឺ មិនមែនជាមីទ្ទិងអីទេ គឺជាការរៀបចំចាត់តាំងកងពល១៤ ទៅជាកងពល៨០១ ទៅបំពេញភារកិច្ច ទៅបោះទីតាំងនៅរតនគិរី។ បាទ ហើយក្នុងនោះ មានមេដឹកនាំដែលចូលរួមនោះ គឺមាន ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន។ ហ្នឹងរៀបចំហ្នឹង ដែលខ្ញុំចាំបាន គឺតែប៉ុន្នានឯង អត់មានទី១ ទី២ ទៀតទេ មានប្រជុំ២.០០០នាក់ ៣.០០០នាក់អី អត់ដែលបានចូលរួមទេ។

**ស៖** ចុះពេលប្រកាសរៀបចំតែងតាំងហ្នឹង គេធ្វើឡើងនៅកន្លែងណា លោកចាំបានទេ?

[១១:៥៥:៥៩]

**ឆ៖** បាទ នៅស្តាត។

**ស៖** ជុំវិញបញ្ហានេះដដែល គឺនៅត្រង់ឯកសារដដែលហ្នឹង លោកក៏បានប្រាប់អ្នកស៊ើបអង្កេតថា “មេដឹកនាំដែលបានចូលរួមកិច្ចប្រជុំនោះមានដូចជា ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន ហើយពួកគាត់បានយកលិខិតតែងតាំង ដើម្បីយកមកប្រកាសនៅក្នុងអង្គប្រជុំ”។ តើលោកអាចរៀបរាប់បានទេ ឲ្យលម្អិតថា តើមានបញ្ហា ឬក៏ប្រធានបទអ្វីខ្លះ ដែលគេបានលើកឡើងពាក់ព័ន្ធនឹងការតែងតាំងកងពល៨០១ នៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ថា រៀបចំកម្មវិធីកងពលរំលាយទៅជាកងពល៨០១ វិញនោះ គឺរៀបចំចាត់តាំង គឺមានអ្នកដឹកនាំបីរូបនេះឯង អ៎! បួនរូបនេះឯង ប៉ុល ពត, នួន ជា ហើយនិង អៀង សារី ហើយនិង សុន សេន។ ប៉ុន្តែការប្រកាសដំបូង គឺក្រដាសដែលកាន់កម្មវិធីគឺ មានអ្នកកាន់កម្មវិធីផ្សេង។ ក្រោយមកបានកងពល -- បាន ប៉ុល ពត គាត់ប្រកាសរៀបចំ។

**ស៖** ចាស ចុះនៅក្នុងការប្រកាសតែងតាំងពេលនោះ តើមានអ្នកកាន់កម្មវិធី ឬក៏មេដឹកនាំជាន់ខ្ពស់បានប្រាប់ពីតួនាទី និងការទទួលខុសត្រូវរបស់កងពលទេ?

[១១:៥៨:០២]

**ឆ៖** បាទ ការប្រជុំប្រមូលផ្តុំរៀបចំជាកម្លាំងចាត់តាំង គឺមានកម្មវិធីច្បាស់លាស់ គឺមានអ្នកកាន់កម្មវិធី មានប្រកាសហេតុអីសព្វគ្រប់ហើយ បានគណៈចាត់តាំងប្រគល់ភារកិច្ចនេះជូនទៅលោក ប៉ុល ពត ពេលនោះ គេហៅថា លោក ប៉ុល ពត។ គាត់ដំណើរការចាត់តាំងឈ្មោះអីៗអ៊ីចឹង។

**ស៖** ចុះនៅពេលហ្នឹង លោក ប៉ុល ពត ឬក៏មានអ្នកផ្សេងបានឡើងមកថ្លែងសុន្ទរកថា ឬក៏ប្រាប់ទៅថា កងពល៨០១ហ្នឹង គាត់មានតួនាទីទទួលខុសត្រូវពីកន្លែងណា ដល់កន្លែងណា? ឬភារកិច្ចអីច្បាស់លាស់ទេ ពេលហ្នឹង?

**ឆ៖** បាទ គឺក្រោយពីប្រកាសចាត់តាំងពីកងពល៨០១ហើយ គឺប៉ុល ពត ផ្ទាល់ខ្លួនឯងហ្នឹង គឺគាត់ជាអ្នករៀបចំ គាត់ជាអ្នកប្រកាស ហើយគាត់ជាអ្នកប្រគល់ភារកិច្ចឲ្យកង ឲ្យវរសេនាធំមួយៗ ទទួលខុសត្រូវកន្លែងណាៗអី ហើយធ្វើការងារអីខ្លះ។ អត់មានអ្នកផ្សេង ឧទ្ទេសនាមភារកិច្ចទេ។

[១១:៥៩:៤១]

**ស៖** ចុះពេលដែលលោក ប៉ុល ពត ឧទ្ទេសនាមអំពីភារកិច្ច និងការទទួលខុសត្រូវរបស់កងពល តើពេលនោះ ប៉ុល ពត ដដែល គាត់ជាអ្នកប្រាប់ថា កងពល៨០១ នឹងត្រូវបញ្ជូនទៅរតនគិរី ឬក៏អ្នកផ្សេងជាអ្នកប្រកាសប្រាប់?

**ឆ៖** មិនមានអ្នកផ្សេងទេ គឺប៉ុល ពត គាត់អ្នកប្រកាសថាកងពល៨០១ អង្គភាពណាទៅនៅកន្លែងណាៗ គឺឧទ្ទេសនាមច្បាស់លាស់ហើយ ភារកិច្ចធ្វើអីៗ ច្បាស់លាស់អត់មានឃើញពីណាក្រៅពីហ្នឹងទេ។

**ស៖** ចុះបន្ទាប់ពីពេលប្រកាសតែងតាំងហ្នឹងតើរយៈពេលប៉ុន្មានទើបកងពល៨០១ត្រូវផ្លាស់ប្តូរទៅខេត្តរតនគិរី?

**ឆ៖** ខ្ញុំមិនចេះនេះទេ ខែទេ ប៉ុន្តែគ្រាន់តែថា តាមខ្ញុំពិនិត្យទៅដូចជានៅភ្នំពេញហ្នឹងមិនដល់បានតែពីរខែអីៗផងទេ គឺទៅហើយ ខែប្រាំបួនរៀបចំចេញដំណើរទៅតែម្តង ដើរផង ខ្លះក៏ជិះកង់ជិះអីទៅដល់ណោះខែដប់មួយ ដល់ស្ទឹងត្រែង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ បាទឥឡូវនេះដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី អ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយសាមសិប

នាទី។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅវេលារសៀល ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការនីតិវិធីសវនាការ ហើយនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរសាជាថ្មីលោកសាក្សី។ មុនពេលសម្រាកពិសាអាហារថ្ងៃត្រង់ ពួកយើងបានពិភាក្សាដល់ចំណុចដែលមានថ្នាក់ដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យមួយចំនួន បានចូលរួមនៅក្នុងពិធីប្រកាសតែងតាំង ឬក៏បង្កើតកងពល៨០១។ ហើយនៅត្រង់ ERN ក្នុងចម្លើយដែលបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតដដែលនេះ លោកបានរំឭកដល់ម្នាក់ឈ្មោះ សោម។ លោកបានប្រាប់អ្នកស៊ើបអង្កេតថា មានមនុស្សម្នាក់ឈ្មោះ សោម បានណែនាំ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន ហើយបានទទួលលិខិតតែងតាំងពីមេដឹកនាំទាំងនោះ។ អ៊ីចឹងខ្ញុំចង់សួរឲ្យលោកបញ្ជាក់ថា តើ សោម ហ្នឹងគាត់ជាអ្នកណា? ហើយគាត់មានតួនាទីអ្វី?

**លោក អ៊ុង រ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ សោម ហ្នឹងតាមពិតគឺជាសេនាធិការនៅភ្នំពេញនេះឯង។ គឺទទួលការ

ប្រកាសចាត់តាំងកងពលហ្នឹងគឺ សោម ហ្នឹងគឺគាត់ជាអ្នកកាន់កម្មវិធីប្រកាសនៅពេលនោះឯង ហើយបាន ប៉ុល ពត ប្រកាសបន្ថែម ពីលើទៀត។ ប៉ុន្តែ ប៉ុល -- ដូច្នេះ សោម ហ្នឹងគ្រាន់តែកាន់កម្មវិធី ប៉ុន្តែក៏និយាយទៅមុខទៀតបាន ដូចខ្ញុំបញ្ជាក់ខាងមុន។

[១៣:៣៤:៥៣]

**ស៖** ចាស សូមអរគុណ។ ពាក់ព័ន្ធទៅនឹងកងពល៨០១ លោកថាបន្ទាប់ពី ១៧មេសា ៧៥ ប្រហែលជាប៉ុន្មានខែប៉ុណ្ណឹងឯង គេបានបញ្ជូនកងពលរបស់លោកហ្នឹងមករតនគិរី ហើយមានការប្រកាសតែងតាំងអ៊ីចឹង។ ចង់សួរបញ្ជាក់លោកថា លោកដឹងទេថាមុនពេលដែលលោកមកដល់រតនគិរីហ្នឹង តើលេខាភូមិភាគនៅរតនគិរី នៅព្រៃសានហ្នឹង គាត់ៗមានឈ្មោះអីដែរ? លោកនៅដឹងទេ? ចាំបានទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយនឹងសំណួរនេះ គឺបញ្ហាគឺទៅ -- តាមពិតប្រកាសចាត់តាំងកងពលគឺត្រៀមដើម្បីទៅរតនគិរី។ ហើយមុននឹងទៅរតនគិរី ដឹកនាំកម្លាំងទៅ គឺក្នុងវរសេនាធំមួយៗត្រូវទៅមុន ដើម្បីរៀបចំកម្លាំងដើម្បីដាក់កម្លាំងរស់នៅរបៀបណាៗ។ ហ្នឹងខ្ញុំបញ្ជាក់អ៊ីចឹង តែៗទី២ ក្រោយពីត្រឡប់ទៅមើលសមរភូមិដាក់ទ័ពរៀបចំអីហើយ គឺបានត្រឡប់មកវិញ គឺបាននាំកម្លាំងទៅតែម្តង។

**ស៖** លោកបានរៀបរាប់អំពីការងារទៅសិក្សា ទៅស្វែងយល់អំពីទីតាំងដែលត្រូវផ្លាស់ទៅ ប៉ុន្តែនៅពេលដែលលោកទៅដល់ទីតាំងហ្នឹងមុនពេលដែលកងពលលោកទៅហ្នឹង តើលោកដឹងទេតើអ្នកណាជាលេខាភូមិភាគនៅភាគព្រៃសានហ្នឹង?

**ឆ៖** បាទ តាមពិតខ្ញុំមិនក្តាប់បានទេ រឿងកង -- រឿងភូមិភាគនៅព្រៃសាននេះ មិនដឹងជាលោកណាៗទេ ប៉ុន្តែគ្រាន់តែដឹងថាវរសេនាធំខ្ញុំដែលរៀបចំពីនេះទៅ គឺបោះនៅកន្លែងណាៗតែប៉ុណ្ណឹង។

[១៣:៣៧:០១]

**ស៖** មុននេះដែរលោកបានរៀបរាប់ថានៅក្នុងពិធីប្រកាសតែងតាំងហ្នឹងមានមេដឹកនាំមួយចំនួនមាន ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន។ ហើយដូចលោកបានរៀបរាប់ពីខាងដើមថា សុន សេន ហ្នឹងគឺទទួលខុសត្រូវខាងផ្នែកយោធា ខាងកងទ័ព។ ចុះលោកដឹងទេថា មូលហេតុអ្វីបានជាលោក អៀង សារី មានវត្តមានដែរនៅពេលនោះ?

**ឆ៖** បញ្ហានេះគឺខ្ញុំមិនយល់ដែរ ប៉ុន្តែគ្រាន់ថា ពេលដែលប្រកាសចាត់តាំងគឺមានបីបួនរូបនេះឯង។ ប្រហែលជាទំនោររបស់ខ្ញុំថា អ្នកទាំងបួនរូបនេះជាអ្នកដឹកនាំ។

**ស៖** មុននឹងចូលដល់រចនាសម្ព័ន្ធ ខ្ញុំចង់សួរបញ្ជាក់លោកថានៅពេលដែលកងពល៨០១ បានតែងតាំងហើយ បានបញ្ជូនទៅដល់រតនគិរី។ អ៊ីចឹងពេលដែលទទួលបញ្ជាហ្នឹង តើស្ថិតនៅក្រោមភូមិភាគ ឬក៏ទទួលបញ្ជាផ្ទាល់ពីសេនាធិការនៅមជ្ឈិមតែម្តង?

[១៣:៣៨:២១]

**ឆ៖** សម្រាប់ផ្ទាល់ខ្លួនខ្ញុំពេលនោះគឺខ្ញុំទទួលការដឹកនាំ ការណែនាំពីកងពល៨០១ពី ស៊ូ សារឿន។ ឯទទួលពីណាទៀត ខ្ញុំក្តាប់មិនបានទេ អត់ដឹង។

**ស៖** ចាស សូមអរគុណ។ ពាក់ព័ន្ធទៅនឹងចំនួនទាហាន ចង់ដឹងថា តើទាហានប៉ុន្មាននាក់ដែលត្រូវចាត់តាំងឲ្យនៅក្នុងកងពល៨០១ បន្ទាប់ពីមានការប្រកាសតែងតាំងជាផ្លូវការហ្នឹង?

**ឆ៖** សរុបទាហានដែលទៅប្រកាសកងពល៨០១ ជាង ៥០០០នាក់។

**ស៖** ពាក់ព័ន្ធទៅនឹងឋានានុក្រមនៃកងពលមួយហ្នឹង សូមលោកជួយរៀបរាប់មើល៍ ថាតើរាប់ពីកងពលមកនៅក្រោមកងពលមានអីគេ? ហើយក្រោមកងពល ឧទាហរណ៍ថា កងពល កងវរសេនាធំ ហើយចុះពីហ្នឹងមកមានអីគេខ្លះទៀត សូមលោកជួយរៀបរាប់ជូនអង្គសវនាការផង។

**ឆ៖** ខ្ញុំសូមជម្រាបដែរថា ក្រោមពីកងពលមកគឺមានវរសេនាធំ។ ក្នុងវរសេនាធំហ្នឹងមានបីរូប មាននយោបាយ មានយោធា មានភ័ស្តុភារ។ ហើយក្នុងវរ -- ក្រោមវរសេនាធំមកទៀត មានវរសេនាតូច មានបីនាក់ដូចវរសេនាធំដែរ។ ហើយតមកបានវរ -- ដែលបានកងតូច កងតូចក៏មានបីនាក់ដែរ។ មានប្រធាន មានអនុប្រធាន មានសមាជិក។ ដូច្នេះក្នុងបីកងវរសេនាធំ ខ្ញុំសូមជម្រាបតែមួយកងក៏អស់លោកយល់ដែរ។

**ស៖** ចុះនៅក្រោមកងតូច ឬកងអនុសេនាតូចហ្នឹងមានអង្គភាព ឬក៏មានអង្គ -- មានក្រុមអីនៅខាងក្រោមហ្នឹងទៀតទេ?

**ឆ៖** បាទ មានកងតូចមាន វាមានបីក្រុមទៀត។ មានបីក្រុមបានគេហៅថា មួយកងតូច។

**ស៖** ចុះធម្មតាមួយកងតូចហ្នឹងមានកងទ័ពប៉ុន្មាន ឬមានទាហានប៉ុន្មាននាក់?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ!

[១៣:៤១:២៣]

**លោក អ៊ុង រ៉ែន៖**

**ឆ៖** ក្នុងកងតូចហ្នឹងវាមាន ៣៥នាក់ ទៅ ៣៦ ជាក់ស្ដែងតាមកម្លាំង។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចុះជាក់ស្ដែងបន្ទាប់ពីមានការប្រកាសតែងតាំងឲ្យមានកងពល៨០១ បន្ទាប់ពីមានការតែងតាំងហ្នឹង តើនរណាជាមេបញ្ជាការកងពល៨០១?

**ឆ៖** បញ្ជាការកងពល៨០១ មាន ស៊ូ សារឿន ហើយនិង សាន។

**ស៖** តើលោកទទួលនាទី ឬឋានៈអ្វីដែរនៅក្នុងកងពល៨០១ នេះ?

**ឆ៖** ខ្ញុំទទួលជាវរសេនាធំ។

[១៣:៤២:៣៣]

**ស៖** សូមលោកជួយសរុបចំនួនកងពល ឬកងទ័ពដែលនៅក្នុងមួយវរសេនាធំរបស់លោក។ ជាសរុបមានប៉ុន្មាននាក់?

**ឆ៖** ៤៣០។

**ស៖** ចាស សូមអរគុណ។ ឥឡូវ ខ្ញុំចូលដល់ប្រធានបទថ្មីមួយទៀតទាក់ទងទៅនឹងទំនាក់ទំនង ឬការប្រាស្រ័យទាក់ទងគ្នារវាងកងពលនិងមជ្ឈិម។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅត្រង់ឯកសារ E3/402 ដែលមាន ERN ជាភាសាខ្មែរគឺ 00379445 ដល់46, ERN ជាភាសាអង់គ្លេសគឺ 00381032 ដល់ 33 និង ERN ជាភាសាបារាំងគឺ 00424046។ លោកបានប្រាប់អ្នកស៊ើបអង្កេតថា លោកត្រូវបានមេកងពលឈ្មោះ សារឿន ឲ្យទៅរតនគិរី ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយនៅពេលដែលលោកទៅដល់ភូមិភាគព្រំដែនទីបញ្ជាការរបស់លោកមានទីតាំងនៅស្រុកសៀមប៉ោ ខេត្តស្ទឹងត្រែង នៅជាប់ព្រំដែនឡាវ។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោកថា តើក្នុងនាមលោកជាប្រធានវរសេនាធំ តើលោកត្រូវរាយការណ៍ឲ្យមេបញ្ជាការកងពលតែម្នាក់ឈ្មោះ សារឿន ឬក៏លោកត្រូវរាយការណ៍ជូនទៅមេរបស់លោកផ្សេងទៀតដែរ?

[១៣:៤៤:៣៦]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា ពេលទៅនៅ –មិនមែនសៀមប៉ោទេ គឺសៀមប៉ាង– ស្រុកក្នុងខេត្តស្ទឹងត្រែង ជាប់នឹងព្រំដែលលាវ។ ដូច្នេះការប្រាស្រ័យទាក់ទង គឺថាគ្មានក្រៅពីណាហួសពីកន្លែង

កងពលទេ។ អត់មានមេណាទៀតក្រៅពីហ្នឹង។

**សៈ** អ៊ីចឹងចុះរបបរាយការណ៍ដែលលោកត្រូវរាយការណ៍ឲ្យមេរបស់លោកហ្នឹង តើលោកធ្វើជាប្រចាំរាល់ថ្ងៃ? ហើយធ្វើដោយផ្ទាល់មាត់? ដោយលាយលក្ខណ៍អក្សរឬក៏យ៉ាងម៉េចដែរ? សូមលោកជួយបញ្ជាក់?

**ឆៈ** តាមពិតសភាពជាក់ស្តែងនៅពេលនោះ គឺមិនមែនថាមានរបស់ទំនើបដូចបច្ចុប្បន្នទេ ជួនកាលក៏ថ្មើរជើង ដើរបួនប្រាំថ្ងៃបានដល់កន្លែងកងពលក៏មាន។ ដូច្នេះពេលខ្លះក៏មានទូរលេខមានមកក៏តាមទូរលេខទៅ។

**សៈ** អ៊ីចឹងចង់សួរថា ប្រសិនបើធម្មតាអាចទំនាក់ទំនងតាមទូរលេខដែរ បើទូរលេខមានថ្ម? ចុះបើសិនអត់មានថ្ម តើត្រូវតែធ្វើ ដើរថ្មើរជើងទៅ ឬក៏មាននីរសារជិះសេះជិះអី យកព័ត៌មាន យករបាយការណ៍ទៅឲ្យថ្នាក់លើរបស់លោកដែរ?

**ឆៈ** បាទ អត់មានសេះទេ មានតែថ្មើរជើងហ្នឹងឯង។ ដើរបីបួនថ្ងៃទៅ បានបីបួនថ្ងៃត្រឡប់មកវិញមក។

[១៣:៤៦:៣៧]

**សៈ** ចុះរយៈពេលនៃការរាយការណ៍ហ្នឹងប៉ុន្មានដងក្នុង១ថ្ងៃ? ប៉ុន្មានដងក្នុង១សប្តាហ៍? ឬក៏ជាទៀងទាត់ត្រូវរាយការណ៍ប៉ុន្មានដងដែរ?

**ឆៈ** នៅពេលនោះ គឺដាច់ស្រយាលពីគ្នា ប្រាស្រ័យការទាក់ទងរវាងពីអង្គភាពមួយទៅកន្លែងកងពលគឺមានការលំបាក។ ដូច្នេះមានសភាពការណ៍អីចាំបាច់បានរាយការណ៍។ ជួនកាលគឺអត់មានការអីមួយខែទៅបានរាយការណ៍ម្តង។

**សៈ** ចុះពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរវាងវរសេនាធំជាមួយនិងកងពល តើមាន ដែលមានកម្មវិធីប្រជុំធ្វើឡើងជាទៀងទាត់ ឬក៏ពេលណាមួយដែរទេ?

**ឆៈ** បាទ ជួនកាលគឺ ១ខែប្រជុំគ្នាម្តង ហើយជួនកាល១ខែហ្នឹងក៏គាត់ប្រាប់វិញថា អត់បានប្រជុំទេ រវល់ ឬក៏ឆ្ងាយពីគ្នាអ៊ីចឹង។

**សៈ** ចុះប្រសិនបើត្រូវមានកិច្ចប្រជុំកងពលជាមួយកងវរសេនាធំ តើកិច្ចប្រជុំហ្នឹងគេធ្វើឡើងនៅកន្លែងណា? ហើយអ្នកណាខ្លះត្រូវចូលរួម?

[១៣:៤៨:០៥]

**ឆ៖** បើមានការប្រជុំនៅកន្លែងកងពល ៗចង់អញ្ជើញវរសេនាធំ គឺវរសេនាធំ ត្រូវទៅជួបកន្លែងកងពលនៅវ៉ឺនសៃហ្នឹងហើយ។ ហើយបើកងពលមានបញ្ហាអីដោះស្រាយនូវបញ្ហាវរសេនាតូច--វរសេនាធំនៅកន្លែងណា កងពលចុះទៅធ្វើការនៅកន្លែងនោះ។

**ស៖** ពាក់ព័ន្ធទៅនឹងរបាយការណ៍ ឬរបបនៃការរាយការណ៍ឲ្យថ្នាក់លើរបស់កងពលទៀតនោះ តើលោកដឹងទេថាកងពលគាត់ មេបញ្ជាការកងពលគាត់រាយការណ៍ឲ្យទៅថ្នាក់លើរបស់គាត់ ជាអ្នកណា? ហើយរាយការណ៍ញឹកញាប់ទេ?

**ឆ៖** បាទអានេះ គឺជាភារកិច្ចរបស់មេបញ្ជាការកងពល គឺខ្ញុំក្តាប់មិនបានទេ មិនដឹងជារាយ-ការណ៍ប្រចាំថ្ងៃ ឬក៏ប្រចាំខែយ៉ាងម៉េច ក៏ខ្ញុំក្តាប់មិនបាន។ តែសម្រាប់ខ្ញុំ គឺដូចខ្ញុំបានជម្រាបខាងដើម ។

**ស៖** លោកថា លោកក្តាប់អត់បានទេ ពីរឿងរាយការណ៍ហ្នឹង ថាតើប្រចាំថ្ងៃ ឬក៏ប្រចាំខែ។ អ៊ីចឹងប្រសិនបើលោកអត់ដឹងរយៈពេល អ៊ីចឹងតើលោកដឹងទេប្រសិនបើពេលត្រូវរាយការណ៍ តើមេបញ្ជាការកងពលគាត់រាយការណ៍ឲ្យទៅថ្នាក់លើរបស់គាត់ហ្នឹងដោយមធ្យោបាយណា?

**ឆ៖** បាទតាមពិតកន្លែងកងពលគាត់មានមធ្យោបាយគាត់របស់គាត់ជាទូរលេខ ជាតេអូអីរបស់គាត់។ តែគ្រាន់តែគាត់រាយការណ៍មកលើតាមរបៀបណា ថ្ងៃណា គឺប្រចាំជាប់ ឬក៏មិនជាប់អី អាហ្នឹងក៏ខ្ញុំក្តាប់មិនបានត្រង់ហ្នឹងហើយ។

[១៣:៤៩:៥៤]

**ស៖** ខ្ញុំនៅមានចំណុចចុងក្រោយមួយទៀតចង់សួរបញ្ជាក់លោក ពាក់ព័ន្ធទៅនឹងចម្លើយដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដដែល លោកបានប្រាប់អ្នកស៊ើបអង្កេតថា "នៅពេលដែលលោកនៅវ៉ឺនសៃ លោកបានឃើញមេបញ្ជាការឈ្មោះ សារឿនតែងតែឡើងមកប្រជុំនៅភ្នំពេញ"។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកឃើញមេបញ្ជាការឈ្មោះ សារឿន ហ្នឹង ទៅប្រជុំនៅភ្នំពេញញឹកញាប់ទេ?

**ឆ៖** បាទ ខ្ញុំឃើញថា គាត់ជួនកាលក៏១ខែ ជួនកាលក៏២ខែបានឡើងមកម្តង។ មិនសូវជាញឹកញាប់ទេ ពីព្រោះវាឆ្ងាយ។

**ស៖** ចុះក្នុងនាមលោកផ្ទាល់ តើលោកមានដែលបានឡើងទៅប្រជុំនៅទីក្រុងភ្នំពេញទេ? ហើយប្រសិនបើធ្លាប់ តើឡើងទៅប្រជុំនៅកន្លែងណា?

[១៣:៥១:១០]

**ឆ៖** តាមពិត គឺតាំងពីខ្ញុំទៅនៅសៀមប៉ាងនេះគឺ ហើយនៅវ៉ឺនសៃនេះ ខ្ញុំមិនដែលមកបានប្រជុំមកភ្នំពេញទេ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណ លោក អ៊ុង វ៉ែន។ នាងខ្ញុំអស់សំណួរ ហើយសហការីអន្តរជាតិរបស់ខ្ញុំនៅមានសំណួរមួយចំនួនទៀត ដើម្បីសាកសួរលោក។ សូមអរគុណលោកផងដែរ។

លោកប្រធាន សូមអនុញ្ញាតឲ្យសហភាគាអន្តរជាតិបន្ត។

**លោក ឌេល លីសាក់៖**

សូមអរគុណលោក លោកស្រីចៅក្រម លោកប្រធាន។ លោកសាក្សី ខ្ញុំបាទឈ្មោះ ឌេល លីសាក់ ជាសហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោកនៅល្ងាចនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមសំណួរបន្ត ដែលសហសេរិក សហព្រះរាជអាជ្ញាជាតិបានសួរលោក ដែលបានសួរលោកអំពីការដឹងឮ ថាតើកងពល ដែលថាលេខាកងពលនោះ បានបញ្ជូនសារទូរលេខទៅមជ្ឈិម។ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកនៅទីបញ្ជាការកងពល តើលោកបានឃើញលេខាកងពល សារឿន នោះ ប្រើសារទូរលេខក្នុងការបញ្ជូនព័ត៌មានអ្វីទៅភ្នំពេញ ឬក៏ទទួលអ្វីពីភ្នំពេញដែរឬទេ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ តាមពិត គឺខ្ញុំនៅសៀមប៉ាងទេ ហើយនិងមកនៅវ៉ឺនសៃនេះ ខ្ញុំមិនដែលឃើញថា គាត់ផ្ញើសារទូរលេខតាមរយៈទូរលេខ ឬក៏ស្អីក៏ខ្ញុំមិនដែលដឹងទេ។ ពីព្រោះតាមពិត ខ្ញុំមកនៅវ៉ឺនសៃ ដូចខ្ញុំបានដាក់ក្នុងសង្កេត ដូចខាងអស់លោកសង្កេតការណ៍អីចឹង គឺខ្ញុំមកបានប៉ុន្មានថ្ងៃ ហើយក៏មិនស្គាល់បក មិនស្គាល់អ្នកវៃទូរលេខហ្នឹងផង។ ដូច្នេះ គឺគាត់រាយការណ៍មកកន្លែងណាៗ ត្រង់របៀបណា ខ្ញុំអត់ដឹង។

[១៣:៥៣:៥០]

**ស៖** ខ្ញុំសូមពិនិត្យមើលចម្លើយរបស់លោក ដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនៅក្នុងការសម្ភាសឯកសារ E3/402 គឺជាកាសម្ភាសទី១ ដែលលោកបានផ្តល់ទៅគេនោះ។ ខ្មែរ ERN គឺទំព័រ 00379448, អង់គ្លេស ERN 00381035 ហើយនិងបារាំង ERN ទំព័រ 00424049។ នៅលើទំព័រនេះលោកបានឆ្លើយដូចតទៅនេះ សូមដកស្រង់ "នៅឯវ៉ឺនសៃនោះ ខ្ញុំបានឃើញ សារឿន ប្រើទូរ

លេខ ដើម្បីប្រាស្រ័យទាក់ទងនោះផង" បញ្ចប់សេចក្ដីដកស្រង់។ តើឃ្លានេះ រំឭកឲ្យលោកចងចាំវិញទេ លោកសាក្សី ថាតើលោកបានឃើញ សារឿន បញ្ជូនសារទូរលេខនោះ កាលពីលោកនៅវ៉ឺនសៃនោះ?

**ឆ៖** ហ្នឹងដូចខ្ញុំបានជម្រាបពីខាងដើមមកហើយ គឺ ខ្ញុំមកដល់វ៉ឺនសៃនេះគឺមិនបានឃើញសារបញ្ជូនអីទេ ប៉ុន្តែគ្រាន់តែឃើញថាមានទូរលេខសម្រាប់ទាក់ទងមកលើ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ ឥឡូវនេះខ្ញុំត្រឡប់ទៅបន្តិច ហើយនិងសួរសំណួរបន្តមួយចំនួនពីព្រឹកនេះ។ លោកបានបញ្ជាក់ថា អ្នកដែលនាំលោកចូលបដិវត្តន៍នោះគឺឈ្មោះថា ចេង អន។ សំណួររបស់ខ្ញុំនោះថាតើគាត់ជាមនុស្សម្នាក់ដែលមាន ដែលថាក្នុងសម័យកម្ពុជាធិបតេយ្យនោះក្លាយទៅជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មដែរឬទេ ឈ្មោះនេះនោះ?

**ឆ៖** បាទ បញ្ហាខ្ញុំដែលភពប្រសព្វជាមួយគាត់ក្នុងបញ្ហាដែលរស់នៅជាមួយគាត់កន្លងមក ខ្ញុំដឹងត្រឹមតែគាត់ធ្វើ គាត់ទទួលខុសត្រូវនៅប៉ែកខាងលិចភ្នំពេញនេះ ពិសេសគេហៅតំបន់ខាងលិចបាត់ដឹងនេះ។ ហើយតាមពិតគឺតួនាទីរបស់គាត់ យ៉ាងណាៗទៀតដូចខ្ញុំបានជម្រាបពីខាងដើម គឺខ្ញុំភ្លាប់មិនបានហើយគ្រាន់ថា កម្លាំងគឺថាមានតែគាត់ទេណែនាំ គាត់ទេអ្នកដឹកនាំបាទ។ តែគាត់មានតួនាទីអីមកភ្នំពេញអី ខ្ញុំជាក់ស្តែងគឺមិនបានជួបគាត់តែម្តង មិនដឹងគាត់ធ្វើអីទៀត។

[១៣:៥៧:១៥]

**ស៖** លោកបាននិយាយអំពីថាបន្ទាប់ពីការវាយប្រហារនៅក្រុងឧដុង្គនោះ សុន សេន ហៅខៀវ បានមកបញ្ជា ដោយមានការរៀបចំពីថ្នាក់លើមក។ តើលោកអាចជម្រាបតុលាការបានទេ ថាតើ សុន សេន មកបញ្ជានោះ តើកងពលតូច១៤ រាយការណ៍ផ្ទាល់ទៅ សុន សេន ឬក៏គាត់បន្តរាយការណ៍តាមរយៈលោក ចេង អន នោះ?

**ឆ៖** តាមពិតគឺក្នុងពេលដែល សុន សេន មកនេះគឺកងពលជាអ្នករាយការណ៍ឲ្យ សុន សេន។ ចេង អន គាត់លែងមានការងារអីកងពលទៅរាយការណ៍ឲ្យគាត់ទៀត។ ដូច្នេះមានរាយការណ៍ឲ្យ សុន សេន តែម្តង។

**ស៖** តើលោកដឹងដែរឬទេ ថាតើទីបញ្ជាការរបស់ សុន សេន នៅកន្លែងណា ឬក៏មូលដ្ឋានរបស់គាត់នៅកន្លែងណាអង្កាល់នោះ?

**ឆ៖** បាទ បញ្ហានេះខ្ញុំសូមជម្រាបថា តាំងពីមកនៅជាមួយ អេង ចន មកហើយនិងរៀបចំវ៉ៃភ្នំពេញ ខ្ញុំឃើញ សុន សេន នៅខាងលិចឧដុង្គ ខាងត្បូងវ៉ាដំណាក់ស្នាច់តែម្តងនោះទេ។ ហើយតាមពិត

មិនមានទីតាំងអីដូចខ្ញុំបានជម្រាបពីព្រឹកអ៊ីចឹង នៅតាមដុបៗព្រៃល្បៀង អ៎! ព្រៃឫស្សីព្រៃអីទេ។ នៅមានទីតាំងនោះ កប៉ាល់ហោះវ៉ែតឡូវឯង។

[១៣:៥៩:៥៤]

**ស៖** សូមអរគុណ។ នៅពេលនេះខ្ញុំសូមសួរអំពីសំណួរពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៅក្នុងកងពលវិញម្តង។ លោកបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះ សាន ហើយលេខកូដរបស់គាត់នោះគឺ ០៦ តើលោកអាចបញ្ជាក់ទេ បុគ្គលដែលមានលេខកូដ០៦ ហ្នឹងមាន គឺមានតួនាទីអ្វីដែល គឺបុគ្គលឈ្មោះ សាន ហ្នឹង?

**ឆ៖** បានមុននឹងរៀបចំបញ្ចូលគ្នាជាកងពល១៤ ខ្ញុំសូមនិយាយពីដើមបន្តិច ដើម្បីឲ្យលោកយល់។ មុនប្រកាសកងពល១៤ហ្នឹង គឺមានពីខាងនិរតីមកមួយវរសេនាតូច ដែលនៅតំបន់១៥ចុះពីដើមដែលហៅថា តំបន់១៥ហ្នឹង មួយវរសេនាតូច ហើយមកពីកន្លែងនៅជាមួយ សុន សេន ហ្នឹងមួយវរសេនាតូចមាន សាន ហ្នឹងមកជាមួយ បាទមាន សាន មកជាមួយ។ ដូច្នេះ ការរៀបចំកងពលហ្នឹងមាន ស៊ូ សារឿន ហ្នឹងមួយ ហើយនិង សាន ហ្នឹងមួយ។

**ស៖** ដើម្បីសួរសំណួរមួយចំនួនទៀត ពាក់ព័ន្ធទៅហ្នឹងប្រព័ន្ធទាក់ទងគ្នា សហសេវិករបស់ខ្ញុំបានអានចម្លើយរបស់លោកត្រង់ផ្នែកមួយចំនួននោះ ដែលនៅក្នុងនោះលោកបាននិយាយឆ្លើយថា “សារឿនបានទៅចូលរួមប្រជុំនៅក្នុងទីក្រុងភ្នំពេញ” ហើយលោកបានបញ្ជាក់ផងដែរថា “សារឿន នេះគឺទៅជារៀងរាល់ខែ ឬក៏២ខែម្តង” តើលោកបានដឹងដែរឬទេ ថាតើ សារឿន នោះ បានចូលចូលរួមប្រជុំជាមួយនឹងខាងលេខាកងពលដែរឬទេ នៅពេលដែលគាត់មកទីក្រុងភ្នំពេញនោះ តើគាត់មានប្រជុំជាមួយលេខាអគ្គសេនាធិការដែរឬទេ នៅពេលដែលគាត់មកទីក្រុងភ្នំពេញ?

[១៤:០២:១៧]

**ឆ៖** បាទ បញ្ហានេះខ្ញុំជម្រាបថា បញ្ហាខាងប្រធានកងពលគឺ មកភ្នំពេញគឺថ្ងៃណា ឬ១ខែម្តង ឬក៏២ខែម្តង អាហ្នឹងស្រេចកងពល ហើយនិងខាងលើទេ។ ឯសម្រាប់ខាងខ្ញុំគ្រាន់ដឹងថា ប្រធានកងពលត្រូវតែមាន ត្រូវតែមកធ្វើការនៅកន្លែងខាងលើ នៅកន្លែងមជ្ឈិម។ ដូច្នេះ គឺកំណត់ពេលវេលាថា ២ខែម្តង ឬក៏១ខែម្តង អាហ្នឹងខ្ញុំមិនចាំទេ វាមិនច្បាស់ផង។ ខ្ញុំហើយនិងកងពលនៅឆ្ងាយពីគ្នា ហើយមធ្យោបាយទាក់ទងក៏មានកម្រិត។

**ស៖** នៅពេលលេខាកងពល សារឿន គាត់ត្រឡប់មកពីទីក្រុងភ្នំពេញវិញ។ តើនៅពេលពួកគាត់មកវិញនោះ គាត់មានកោះប្រជុំ ឲ្យលោកចូលរួមប្រជុំ ឬក៏គាត់មានកោះមេកងវរសនាតូច ឬ

វរសេនាធំ មកចូលរួមប្រជុំដើម្បីទទួលយកការណែនាំពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ពេលដែលគាត់មកធ្វើការនៅទីក្រុងភ្នំពេញ បើការងារចាំបាច់ ក៏គាត់អញ្ជើញវរសេនាធំមួយៗដើម្បីមកចូលរួមប្រជុំនៅកន្លែងកងពល បើការងារត្រឹមតែល្មម ឧទាហរណ៍ថា បញ្ហាបង្កបង្កើនផលអីទេ ជួនកាលគាត់ឲ្យជាសំបុត្រ ជួនកាលគាត់ណែនាំតាមតេអូ។ ប៉ុណ្ណឹង សូមអស់។

**ស៖** ប្រហែលជាសំណួររបស់ខ្ញុំមិនច្បាស់លាស់ ឬក៏មានបញ្ហាពាក់ព័ន្ធទៅនឹងការបកប្រែ។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺថានៅពេលដែល សារឿន មកពីទីក្រុងភ្នំពេញទៅដល់រតនគិរីនោះ តើគាត់មានកោះប្រជុំនៅក្នុងកងពលរបស់គាត់ដែរឬទេ? តើគាត់មានកោះប្រជុំ ថាតើគាត់បានទៅភ្នំពេញនោះ គេមានប្រាប់ណែនាំអ្វីដែរឬទេ? ដូច្នេះ ខ្ញុំចង់សួរថា តើគាត់មានកោះប្រជុំនៅកងៗពលរបស់គាត់ដើម្បីរៀបរាប់អំពីអ្វីដែលគាត់ទទួលបានពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំជម្រាបពីខាងដើម ព្រោះខ្ញុំបានបញ្ជាក់ហើយ គឺបើសភាពការណ៍មិនមានអីធំដុំទេ គឺជួនកាលហ្នឹងក៏ទៅដល់ភ្លាមហ្នឹងអត់ទាន់បានធ្វើការទេ។ តែបើសភាពការណ៍បន្ទាន់អី ក៏ទៅដល់ភ្លាមហ្នឹង ជួនកាលហៅភ្លាម។ ហើយបើសភាពការណ៍ ឧបមាថា មានខ្មាំងឈ្លានពានព្រំដែនអី គឺហៅគ្នាជួបភ្លាម ឬក៏គាត់ទៅជួបភ្លាម។

[១៤:០៦:០៧]

**លោក ឌេល លីសាក់៖**

លោកប្រធាននៅពេលនេះខ្ញុំសូមអនុញ្ញាតបង្ហាញសាក្សីនូវឯកសារមួយគឺឯកសារលេខE3/798។ ឯកសារនេះ គឺកំណត់ហេតុចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ គឺជាការកំណត់ហេតុប្រជុំរបស់លេខា និងអនុលេខាកងពល រួមទាំងខាងអង្គភាពស្វយ័តពិសេសផងដែរ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញនូវឯកសារនេះជូនសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីខ្ញុំមិនចង់ឲ្យលោកអានឯកសារនេះទាំងមូលនោះទេ។ ខ្ញុំគ្រាន់តែចង់ឲ្យលោក

មើលទំព័រទី២ ផ្នែកខាងក្រោម ខ្មែរមានលេខ 00052381 គឺត្រង់ផ្នែកដែលពាក់ព័ន្ធទៅនឹងការរាយ-ការណ៍។ ហើយនៅក្នុងនោះបានលើកឡើងយោបល់របស់សមមិត្ត រឿន ដែលគាត់និយាយអំពីស្ថានភាពបាតុភាពនៅតាមព្រំប្រទល់។ ដូច្នេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលត្រង់ចំណុចហ្នឹង ហើយបញ្ជាក់ជូនយើងខ្ញុំថាតើលោកស្គាល់បុគ្គលឈ្មោះ សមមិត្តរឿន នេះគឺជាមនុស្សមួយរូបដែលលោកនិយាយថា ឈ្មោះ ស៊ូ សារឿន នុំងមែនដែរឬទេ?

**លោក អ៊ឹង រ៉េន៖**

**ឆ៖** បាទ ឈ្មោះ ស៊ូ សារឿន ហ្នឹងគឺជាប្រធានកងពលដែរ។

**ស៖** យោបល់ដែលសរសេរនៅក្នុងឯកសាររបាយការណ៍នេះ គឺសមមិត្ត រឿន បាននិយាយអំពីបាតុភាពនៅតាមព្រំប្រទល់ឡាវ។ តើលោកអាចបញ្ជាក់ ឆ្លើយប្រាប់យើងខ្ញុំដែរឬទេ តើលោកធ្លាប់បានដឹងអំពីបាតុភាពដែល រឿន នេះនិយាយនៅក្នុងរបាយការណ៍នេះដែរឬទេ? ថាតើមានបាតុភាពកើតឡើងនៅក្នុងតំបន់ដែលកងពល៨០១ ទទួលបន្ទុកដែរឬទេ?

[១៤:០៨:៥៣]

**ឆ៖** បាទ ខ្ញុំសូមជម្រាបអំពីបញ្ហានេះគឺ ខ្ញុំគឺទទួលខុសត្រូវនៅម្តុំព្រំដែនឡាវ ហើយជាមូលដ្ឋានគឺកន្លែងគឺខ្ញុំរស់នៅ ហើយតាមព្រំដែនអីគឺមិនមានបញ្ហាអីទេ។ ប៉ុន្តែដោយឡែក នៅតាមសាលាកងវរសេនាធំផង គឺមានរឿង។ ឯនៅម្តុំដីឡាវគឺគ្មានទេកាលខ្ញុំនៅ។

**ស៖** ប្រសិនបើលោកមើលទំព័របន្ទាប់មួយទៀតនៃឯកសារនេះ។ ឯកសារខ្មែរមានលេខ 000 52382 នៅក្នុងនោះគឺមានយោបល់ពាក់ព័ន្ធទៅនឹងមិត្ត បង៨៩ បាទ គឺយោបល់របស់ បង៨៩។ តើលោកស្គាល់ទេ បង៨៩ នេះគឺនរណាដែរ?

**ឆ៖** ខ្ញុំអត់ៗស្គាល់ទេបង៨៩។ ស្គាល់តែ០៥, ០៦ និងឈ្មោះៗអ្នកដែល ដូចជាវរសេនាធំនៅជាមួយគ្នាតែម្តង។

**ស៖** លោកបានបញ្ជាក់ថា សុន សេន បានប្រើឈ្មោះហៅក្រៅ ខៀវ។ តើលោកបានដឹងទេថាគាត់ហ្នឹងក៏មានឈ្មោះមួយទៀតដែរ ដែលប្រើឈ្មោះលេខកូដ ដូចលេខកូដ០៥, ០៦ អ៊ីចឹងដែរ តើលោកដឹងទេថាគាត់ប្រើលេខកូដអ៊ីចឹងដែរ?

**ឆ៖** សំណួរនេះ ខ្ញុំស្តាប់អត់បាន សុំម្តងទៀត។

[១៤:១១:០៣]

**ស៖** លោកបានបញ្ជាក់ថា លោកបានស្គាល់ឈ្មោះហៅក្រៅរបស់ សុន សេន ដែលឈ្មោះ ខៀវ។ តើលោកបានដឹងទេថា សុន សេន នោះក៏មានឈ្មោះគាត់ហ្នឹង ហៅជាលេខដែរ តើលោកដឹងទេ?

**ឆ៖** បាទ កន្លងមកចំពោះបញ្ហានេះគឺ បើខ្ញុំធ្លាប់ឮ ដឹងវិញ គឺមានតែពីរនាក់ហ្នឹងឯង គឺ០៥, ០៦ ឯ សុន សេន គឺដឹងថាអត់មានលេខកូដអីទេ។ អត់មានលេខក្នុងតេអូរី ដែលហៅយ៉ាងម៉េចនោះទេ អត់មានទេ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំមានឯកសារមួយទៀត ដែលខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សី។ ឯកសារនេះ គឺ ឯកសារលេខ E3/1160។ ឯកសារនេះ គឺរបាយការណ៍ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ៧៦ ផ្ញើជូនពីកងពល ៨០១ បញ្ជូនទៅបង៨៩។ ដូច្នេះខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះជូនសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

*(មន្ត្រីរដ្ឋបាលតុលាការយកជូនសាក្សី)*

[១៤:១៣:០៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីឯកសារនេះ គឺជារបាយការណ៍បញ្ជូនពីកងពល៨០១ ទៅបង៨៩ ហើយចុះហត្ថលេខាដោយបុគ្គលមួយរូបឈ្មោះ ធិន។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះដែរឬទេ អ្នកណាគេដែរឈ្មោះ ធិន ហ្នឹង?

**លោក សុន អរុណ៖**

ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ជំទាស់យ៉ាងម៉េចទៅ បង្ហាញហេតុ។

**លោក សុន អរុណ៖**

ខ្ញុំសូមជំទាស់សំណួរនេះ លោកព្រះរាជអាជ្ញាមិនទាន់សួរថា សាក្សីហ្នឹងដែលទទួល -- ឃើញឯកសារនេះឬអត់ផង។ បើសិនជាមិនឃើញទេ មិនដែលឃើញត្រូវដកចេញ។ តាមបទបញ្ជាតុលាការ

មុនៗមកបានធ្វើអ៊ីចឹង។ សូមអរគុណ។

[១៤:១៤:០៥]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងការជំទាស់។ យើងឃើញមានអញ្ញត្រកម្ម ការលើកលែងមួយចំនួននៅករណីបង្ហាញឯកសារទាំងអស់នេះ។ ក្នុងការលើកលែងមួយនោះគឺថា បញ្ហាណាដែលសាក្សីដឹងដោយផ្ទាល់ ហើយដែលសាក្សីអាចផ្តល់ព័ត៌មានជូនតុលាការបាននោះ គឺថាយើងអាចឲ្យគាត់ឆ្លើយបាន។ នេះគឺជារបាយការណ៍របស់ខាងកងពល ហើយគាត់ជាមេបញ្ជាការមួយរូបផងដែរ ដូច្នេះហើយ គឺយើងខ្ញុំគ្រាន់តែសួរបញ្ជាក់ថា តើគាត់ស្គាល់បុគ្គលដែលចុះហត្ថលេខានេះដែរឬទេ? ហើយសាក្សីបានឆ្លើយមករួចមកហើយ គាត់ស្គាល់បុគ្គលឈ្មោះ ០៥, ០៦។ ដូច្នេះហើយទាំងអស់នេះហើយ វាជាទំនាក់ទំនងគ្នានៃការដឹងរបស់សាក្សីជាមួយនឹងឯកសារ។ នៅក្នុងកាលៈទេសៈទាំងអស់នេះ គឺថាយើងខ្ញុំមានសិទ្ធិធ្វើការសួរសាក្សីពាក់ព័ន្ធទៅនឹងឯកសារមួយនេះលោកប្រធាន។

[១៤:១៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:០២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីលោក នួន ជា មិនសមស្របទេ។ ករណីនេះជាករណីដោយឡែក ដោយសារឯកសារនេះមានព័ត៌មានពាក់ព័ន្ធផ្ទាល់ទៅនឹងសកម្មភាពនៃអង្គភាពរបស់គាត់។ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា។

សាក្សីទំនងភ្លេចហើយ សូមលោកតំណាងសហព្រះរាជអាជ្ញា អាចបន្តតាំងសំណួរ ឬក៏សួរសាជាថ្មីឡើងវិញ ដើម្បីឲ្យលោកសាក្សីអាចចងចាំនឹងអាចយល់អំពីខ្លឹមសារនៃសំណួរ នឹងអាចឆ្លើយតបបាន។

[១៤:១៨:០១]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សំណួរដែលខ្ញុំសួរនោះ គឺថាតើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ? បុគ្គលឈ្មោះ ធិន នេះគឺជានរណាដែរ? ដែលគាត់បានចុះហត្ថលេខាក្នុងរបាយការណ៍នេះ? តើធិននេះជានរណា?

**លោក អ៊ឹង វ៉ែន៖**

**ឆ៖** ខ្ញុំសូមជម្រាបថា ធិន នេះ កាលៗពីមុនហ្នឹងគឺគាត់ជាវរសេនាធំនៅក្នុងកងពល៨០១ដែរហៅថា "វរសេនាធំ៨៣"។ ក្នុងនេះខ្ញុំឃើញហើយ ខ្ញុំយល់ហើយ ប៉ុន្តែបើនៅក្នុងភ្លើងនេះអត់ទាន់មានឃើញក្រហម ខ្ញុំអត់ហ៊ាននិយាយ។ វរសេនាធំ៨៣ គឺគាត់រាយការណ៍មក ៨៩នេះ គឺរាយការណ៍មកសុន សេន នេះឯង។ បាទ ព្រោះ សុន សេន លេខគាត់គឺ ៨៩។

[១៤:១៩:១៥]

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេតាមចម្លើយរបស់លោក លោកថា ធិន នេះគឺជាមេកងវរសេនាធំនៃកងពល៨៣ កងវរសេនាធំលេខ៨៣ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ធិន នេះជាកងវរសេនាធំ៨៣ គឺចាត់តាំងពីភ្នំពេញទៅជាមួយគ្នា គ្រាន់តែគាត់អង្គភាពផ្សេង ខ្ញុំអង្គភាពផ្សេង។

**ស៖** ពាក់ព័ន្ធទៅនឹងកងវរសេនាធំនេះ យើងឃើញមានកងវរសេនាធំច្រើន ហើយលោកបានបញ្ជាក់ថា គេចាត់តាំងឲ្យលោកធ្វើជាលេខាកងវរសេនាធំមួយដែរ។ តើលោកកាន់កាប់កងវរសេនាធំមួយណាដែរ? លោកជាលេខាកងវរសេនាធំមួយណាដែរ?

**ឆ៖** ខ្ញុំបានជម្រាបរួចហើយគឺថា ខ្ញុំទទួលខុសត្រូវវរសេនាធំ៨២ នៅព្រំដែនឡាវ គេហៅថាសៀមប៉ាង។

**ស៖** តើបុគ្គលដែលជាលេខាកងវរសេនាធំលេខ៨១ នោះមានឈ្មោះអ្វីដែរ? ហើយតើកងវរសេនាធំលេខ៨១ នេះបង្កើតឡើងក្នុងឆ្នាំណាដែរ?

**ឆ៖** វរសេនាធំ៨១ គឺមានលេខាគឺ ឈ្មោះ មូត កើតដំណាលគ្នាហ្នឹង អង្គភាពខ្ញុំដូច(ឮមិនច្បាស់)ថ្ងៃតែមួយ។

[១៤:២១:៣៧]

**ស៖** ត្រឡប់ទៅមើលឯកសារថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ដែលជារបាយការណ៍ផ្ញើពី ធិន។

ចំណុចប្រាំមួយនៅក្នុងរបាយការណ៍នោះថែងដូចតទៅ។ ខ្ញុំសូមដកស្រង់សម្ដី “សព្វថ្ងៃបង០៥ កំពុងចុះទៅគ្រប់វរសេនាធំអប់រំផ្នែកយុវកក” ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដីត្រឹមនេះ។ បុគ្គលនៅក្នុងនេះហៅថាបង០៥ នេះគឺជាមនុស្សតែមួយដែលលោកទើបតែឆ្លើយអំបាញ់មិញនេះថាឈ្មោះ ស៊ូ សារឿន ដែលហៅថា បង០៥ ហ្នឹងតើជាបុគ្គលតែមួយឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ស៊ូ សារឿន ហើយ០៥ ហ្នឹងជាបុគ្គលតែមួយទេ។

**ស៖** ចុះលេខាកងពល សារឿន នេះ បានចុះទៅកងវរសេនាធំរបស់លោកដើម្បីធ្វើការអប់រំអ៊ីចឹងដែរមែនឬទេ?

**ឆ៖** បាទ តាំងពីខ្ញុំទៅនៅសៀមប៉ាង គឺឃើញកងពលមានការអប់រំ ដូចសំណួរនេះអ៊ីចឹង។ ទៅបានម្ដង។

[១៤:២៣:៣១]

**ស៖** នៅពេល សារឿន ចុះទៅអប់រំផ្នែកនយោបាយនោះវគ្គអប់រំហ្នឹងចំណាយពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ពេលវេលាមានតែ២ថ្ងៃ។

**ស៖** តើលោកចាំទេនៅក្នុងវគ្គអប់រំនោះ គេបាននិយាយអំពីបញ្ហាអ្វីខ្លះ?

**ឆ៖** វគ្គអប់រំនោះគឺបញ្ជាក់អំពីការពង្រឹងកម្លាំងការយកចិត្តទុកដាក់មិនឲ្យវាតពីបក្សប៉ុណ្ណោះឯង ហើយមានលម្អិតជាងនេះទៅទៀត។ ធ្វើម៉េចឲ្យយុវកកហ្នឹង គឺចេះគ្រប់គ្រងខ្លួនឯង ចេះកសាងដោយខ្លួនឯង។

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យមើលចម្លើយរបស់លោកមួយទៀត គឺឯកសារ E3/402 ជាកំណត់ហេតុស្ដាប់ចម្លើយចៅក្រមស៊ើបអង្កេត។ ឯកសារដែលខ្ញុំចង់សួរនោះ គឺ 00379448, អង់គ្លេសមានលេខ 00381035 និងបារាំងមានលេខ 00424049។ នៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយនោះលោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្ដីដែលលោកឆ្លើយ “តើវគ្គអប់រំ នៅពេលនោះ គឺថា សារឿន បានប្រាប់ថា កុំឲ្យវាយឈ្លើយសឹក ហើយត្រូវបញ្ជូនឈ្លើយសឹកទាំងអស់នោះឡើងទៅលើ” បន្ទាប់មកនៅចុងបញ្ចប់នៃឃ្លានោះបានសរសេរថា “សារឿន មិនផ្ដល់ព័ត៌មានថាអ្នកទាំងអស់នោះជាគិញនោះទេ ក៏ប៉ុន្តែនៅពេលដែលយើងចាប់ខ្លួនអ្នកទាំងអស់នោះបាន ត្រូវតែបញ្ជូនឡើងទៅលើ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដីរបស់លោក។ តើលោកអាចបញ្ជាក់បានដែរឬទេ? លោកបានន័យយ៉ាង

ម៉េចដែរ នៅពេលដែលលោកនិយាយថាចំណាប់ខ្មាំងនិងគិញនោះ ដែលត្រូវបញ្ជូនឡើងទៅលើ។ តើលោកមានន័យយ៉ាងម៉េចដែរ ចំពោះពាក្យថា "ចំណាប់ខ្មាំង និង គិញនេះ"?

[១៤:២៦:២៤]

**ឆ៖** ទី១ ចំណាប់ខ្មាំង បានសេចក្ដីថា ខ្មាំងដែលយើងវៃបាត់ទៅ យើងចាប់បានអីហ្នឹង ហៅថាចំណាប់ខ្មាំង។ គិញ គឺគិញ អ្នកមកស៊ើបការណ៍ មកយកការណ៍ គឺហៅថា គិញ។ ពិសេស គឺគាត់បានរៀនសូត្រ ឬក៏ណែនាំអ៊ីចឹង គឺថាចំពោះផ្នែកទាំងពីរនេះ គឺបើសិនណាជា អង្គភាពណាចាប់បាន ឬក៏ធ្វើបាន គឺមិនឲ្យធ្វើអីគេទេ។ គឺបញ្ជូនឲ្យមកកងពល ហើយកងពលបញ្ជូនទៅលើ។ ដល់បញ្ជូនទៅរបៀបណាហ្នឹង ក៏ខ្ញុំក្ដាប់មិនបានដែរ ប៉ុន្តែក្នុងបញ្ហានេះ ខ្ញុំបញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមសួរលោកអំពីអគ្គសេនាធិការម្ដង។ មុនពេលដែលខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងអគ្គសេនាធិការ ខ្ញុំសូមសួរបញ្ជាក់ ថាតើខ្ញុំយល់ត្រឹមត្រូវដែរឬទេ គឺបញ្ហាដែលគេឲ្យលោកផ្លាស់ទីនោះ គឺថាមានបានបញ្ហាទៅកាន់លោក ហើយខ្ញុំនឹងសួរសំណួរជាក់លាក់អំពីរយៈពេលនេះជាក់លាក់នាពេលក្រោយ។ លោកបានឆ្លើយជូនយើងខ្ញុំរួចមកហើយ ថាលោកមកទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ ក្រោយមកលោកបានត្រូវគេផ្លាស់ទៅសៀមប៉ាង នៅក្នុងសៀមប៉ាងនៅស្ទឹងត្រែង។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ថាក្រោយមកលោកក៏បានត្រឡប់មកភ្នំពេញមួយរយៈពេលផងដែរ ហើយធ្វើការនៅអគ្គសេនាធិការ ហើយក្រោយពេលដែលលោកត្រូវបានគេចាត់តាំងឲ្យធ្វើការនៅក្នុងអគ្គសេនាធិការនេះ គេក៏បញ្ជូនលោកបន្តទៅដល់សៀមប៉ាង នៅក្នុងខេត្តរតនគិរី។ អ៊ីចឹងថាតើគេមានបានបញ្ហាឲ្យលោកផ្លាស់ទីអ៊ីចឹងដែរឬទេ នៅក្នុងពេលដែលលោកធ្វើការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាពេលនោះ?

[១៤:២៩:១០]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់លើបញ្ហាសំណួរនេះ។ តាមពិត គឺមក ខ្ញុំមក មុននឹងមកភ្នំពេញនេះ គឺត្រូវកងពលហៅមករ៉ឺនសៃ បាទ មករ៉ឺនសៃហ្នឹង គឺអានេះ ខ្ញុំនិយាយតាមដំណើរដែលខ្ញុំក្ដាប់បាន។ មករ៉ឺនសៃហ្នឹង គឺដើម្បីទទួលការងារដែលនៅក្នុងកងពលនេះគឺ ពីព្រោះឲ្យខ្ញុំមកជំនួស០៦ ហៅ សាន នេះឯង ហើយខ្ញុំក៏មកដល់ ហើយក៏គាត់ថា "បើអ៊ីចឹងយ៉ាងម៉េច?" ខ្ញុំថា "ខ្ញុំសួរថាយ៉ាងម៉េចទៅ ចុះអ៊ំបើ០៦? ខាងលើដកទៅមណ្ឌលគិរីបាត់ហើយ ដូច្នេះទាល់តែឯងមកនៅកន្លែងនេះជំនួស០៦"។ នេះសូមខ្ញុំចង់ជម្រាបអ៊ីចឹង ហើយបានជាខ្ញុំត្រឡប់ទៅកន្លែងវិញ។ ដល់អ៊ីចឹងហៅខ្ញុំមកម្ដងទៀត មានទាំង កែវ

សារឿន ហ្នឹងឯង។ បានមក គឺគាត់ថាឥឡូវខាងលើឲ្យខ្ញុំទទួលជំនួស០៦ ហើយ រឿន ហ្នឹង គាត់ទទួលខាងភ័ស្តុភារក្នុងកងពលហ្នឹងដែរ។ និយាយមួយម៉ាត់ ទាំងបី ទាំង ស៊ូ សារឿន ហើយនិង រឿន នេះ ហើយនិងខ្ញុំនេះ គឺទាំងបីនាក់ហ្នឹងវាទៅជាគណៈកងពល បីរូបហ្នឹងឯង។ ពីព្រោះ សាន គាត់ចេញបាត់ហើយ ០៦នោះបាទ។

**ស៖** ខ្ញុំសួរសំណួរទូទៅមួយចំនួនអំពីអគ្គសេនាធិការនៅភ្នំពេញ។ ហើយខ្ញុំនឹងសួរសំណួរជាក់លាក់មួយចំនួនដែលលោកធ្វើការនៅទីនោះនៅពេលក្រោយ។ តើលោកអាចជម្រាបអង្គជំនុំជម្រះអំពីការពិពណ៌នាទូទៅ អំពីតួនាទី ហើយនិងមុខងាររបស់អគ្គសេនាធិការនៅភ្នំពេញ ថាតើគេធ្វើអ្វីខ្លះ មានមុខងារអ្វីខ្លះ?

[១៤:៣១:៥២]

**ឆ៖** ខ្ញុំសូមជម្រាប បញ្ហាសំណួរនេះគឺខ្ញុំបាននិយាយពីមុនខ្លះហើយ គឺបញ្ហាក្រោយពីប្រកាសថាឲ្យខ្ញុំមកទទួលជំនួស០៦ នេះ បានប្រហែល១ខែ ក៏ខ្ញុំត្រូវមករៀននៅភ្នំពេញ។ រៀននៅភ្នំពេញ ខ្ញុំរៀនមិនបាន១អាទិត្យផង ក៏ខ្ញុំឈឺរហូត។ ហើយក្រោយមកគ្រាន់បើហើយ គឺមកនៅកន្លែងសេនាធិការនេះ។ តាមពិតគឺគ្មានប្រកាសចាត់តាំងជាសេនាធិការអី ដឹកនាំអីអត់ទេ។ ព្រោះនៅហ្នឹង គឺទម្រាំនឹងមានកម្លាំងស្រួលបួល។ ដូច្នេះ មិនមែនមកដល់ប្រកាសដូចកងពលដែលរៀបចំកងពល៨០១ ទៅព្លិសានអីប្រកាសអ្នកនេះអ្នកនោះអី អត់ទេ។ គឺនៅគ្រាន់តែមកគ្រាន់តែរបៀបនៅហ្នឹងហើយ តែប៉ុណ្ណឹងឯង។ អត់មានថាភារកិច្ចធ្វើអីៗអត់មានទេ។ ហើយតាមពិតសេនាធិការរបស់គេឯណោះ មានសោម, មានណាត, មានឆាន។ នេះខ្ញុំក្តាប់បានតែប៉ុណ្ណឹងឯង។ ឯតួនាទីរបស់គេធ្វើអីៗ គឺខ្ញុំក្តាប់មិនបាន ហើយព្រឹកព្រលឹមឡើង គឺគេចេញខ្វោកៗទៅ។ ហើយខ្ញុំមិនដឹងជាធ្វើស្អី ព្រោះដូចថាសម្រាក អត់មានភារកិច្ច អត់មានប្រគល់អីច្បាស់លាស់ ខ្ញុំមិនដឹងធ្វើអី ហើយម្យ៉ាងអត់ សុខភាពមិនល្អផង។ ដូច្នេះ ខ្ញុំជម្រាបប៉ុណ្ណឹង។

**ស៖** តើ សោម ហើយនិង ណាត ជាសមាជិក ជាកម្មាភិបាលនៅសេនាធិការដែរឬទេ នៅក្នុងពេលដែលលោកមកភ្នំពេញនាកាលនោះនុ៎ះ?

[១៤:៣៣:៥៣]

**ឆ៖** បាទ ខ្ញុំជម្រាបថា តាមខ្ញុំដឹងគឺ សោម ហើយ ណាត នេះ ហើយនិង ឆាន នេះជាសេនាធិការរបស់ខាងលើ នៅពេលនោះ។ ព្រោះឃើញព្រឹកឡើងអីការងាររបស់គេសស្រាក់សស្រាំ ព្រោះគេការងាររបស់គេ គេដឹងភារកិច្ចរបស់គេធ្វើអីៗ។

**សៈ** ថាតើមន្ទីរសេនាធិការស្ថិតនៅកន្លែងណា នៅត្រង់ចំណុចណានៅក្នុងទីក្រុងភ្នំពេញនោះ?

**ឆៈ** បាទ មន្ទីរសេនាធិការនៅខាងក្រោយក្រសួងការពារជាតិ។

**សៈ** តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅមន្ទីរសេនាធិការនាកាលនោះ លោកអាចជម្រាបបានទេ?

**ឆៈ** បាទ នៅកាលនោះខ្ញុំបានចូលទៅហ្នឹងគឺមានសេនាធិការហ្នឹងគឺបីនាក់ ហើយសរុបមកមាន ៣០នាក់។

**សៈ** នៅពេលដែលលោកនៅមន្ទីរសេនាធិការ តើលោកបានឃើញថានៅទីនោះគេមានម៉ាស៊ីនសារទូរលេខ ឬក៏ឧបករណ៍សម្រាប់ប្រាស្រ័យទាក់ទងទៅនឹងអង្គភាព ឬក៏កងពលអ្វីផ្សេងទៀតនៅក្រៅទីក្រុងភ្នំពេញដែរឬទេ?

[១៤:៣៦:០០]

**ឆៈ** បាទ ខ្ញុំមិនដែលបានឡើងទៅមើលគេមានស្អីទេ ប៉ុន្តែគ្រាន់តែថាឃើញ ឮស្នូរសំឡេងទូរលេខមានអី ប៉ុន្តែដឹងគេទាក់ទងទៅខាងណាមកខាងណា ក៏ខ្ញុំមិនដែលបានចូលទៅដល់ទេ។ ព្រោះបញ្ហាធំគឺ បញ្ហារក្សាការសម្ងាត់ ហើយជាពិន័យអ្នកដែលមិនមានអី ត្រូវការទៅ វាអត់ទៅបានទេ។

**សៈ** តាមអ្វីដែលខ្ញុំយល់ ហើយលោកនិយាយថាម៉ាស៊ីនទូរលេខនោះនៅជាន់ទី២ នៃមន្ទីរសេនាធិការ តើលោកបានឆ្លើយអ៊ីចឹងទេអំមិញនេះបាទ?

**ឆៈ** ខ្ញុំអត់ទាន់បានឆ្លើយត្រង់ហ្នឹង ប៉ុន្តែ -- អត់បានឆ្លើយត្រង់ហ្នឹងទេ ប៉ុន្តែគ្រាន់តែថាសារទូរលេខមាន ពីព្រោះមើលពីចម្ងាយទៅក៏ដឹងថាមានដែរ ព្រោះខ្សែខ្វែងខ្វាត់។

**សៈ** តើលោកអាចប្រាប់ខ្ញុំបានទេថា តើសេនាធិការ ហើយសេនាធិការមានការទទួលខុសត្រូវក្នុងការផ្គត់ផ្គង់អាវុធ គ្រាប់រំសេវទៅកងពលផ្សេងៗ ហើយនិងកងវរសេនាធំនានាដែរឬទេ?

**ឆៈ** បាទ បើនិយាយពីខ្ញុំនៅ -- ខ្ញុំអត់ដែលឃើញមានសេនាធិការនេះចុះទៅផ្ទាល់ចែកចាយគ្រាប់រំសេវអីទេ ប៉ុន្តែអាចមានភ័ស្តុភារសេនាធិការហ្នឹងទៀត បើចំពោះប៉ុន្មាននាក់ បីរូបនេះគឺបីរូបនេះមិនដែលឃើញទៅដឹកគ្រាប់ទៅអីទេ អាចមានភ័ស្តុភារទៀត ប៉ុន្តែពិតជាមាន។

**សៈ** តើសេនាធិការមានការិយាល័យភ័ស្តុភារដាច់ដោយឡែករបស់ខ្លួនដែរឬទេ?

**ឆៈ** បាទ សេនាធិការ ខ្ញុំភ្លាប់មិនបានត្រង់ថា ខ្ញុំមកនៅ ខ្ញុំឃើញតែបីនាក់ហ្នឹងទេ ហើយក៏មិនដែលឃើញកន្លែងការិយាល័យម្តុំណា ហើយអ្នកណាទទួលអីៗ អត់ ខ្ញុំអត់ដឹងទេ។

[១៤:៣៩:១៧]

**លោក ឌេល លីសាក់៖**

ខ្ញុំចង់ត្រឡប់មកចំណុចមួយទៀត លោកប្រធាន ខ្ញុំប្តូរទៅប្រធានបទមួយផ្សេងទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក នៅក្នុងបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** លោកសាក្សីនៅពេលនេះ ខ្ញុំសូមសួរលោកនូវសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងដំណើរការដែលកម្មាភិបាលត្រូវបានដាក់ពិន័យ ឬក៏បោសសម្អាត។ តើលោកដឹងទេ តើនរណាគេដែលមានអំណាច

មានសិទ្ធិក្នុងការចាត់ចែងទៅលើការដាក់ពិន័យ ឬក៏បោសសម្អាតនេះ? ខ្ញុំចង់ឲ្យលោកពិនិត្យមើល កំណត់ហេតុស្តាប់ចម្លើយលើកទី២ ជាមួយនឹងចៅក្រមស៊ើបអង្កេតដែលនៅក្នុងនោះលោកបាននិយាយរៀបរាប់អំពីសារទូរលេខមួយដែល ស៊ូ សារឿន ជាអ្នកបង្ហាញជូនលោក។ ឯកសារនោះ គឺមានលេខ E3/84 ការដកស្រង់នោះត្រង់ទំព័រលេខ 00398513, អង់គ្លេសត្រង់ទំព័រ 00408395 រហូតទៅដល់លេខ 00408396, បារាំង 00434422 រហូតទៅដល់លេខ 23។

[១៥:០៣:២៣]

ខ្ញុំសូមដកស្រង់សម្តីរបស់លោក "នៅពេលដែលខ្ញុំទៅរៀននៅភ្នំពេញ មានសារទូរលេខមួយមកពីកងវរសេនាធំ៨១ ដែលខាងនុំងគេផ្ញើមកមេរបស់ខ្ញុំ ស៊ូ សារឿន" ហើយនៅក្នុងនោះ នៅពេល -- ហើយនៅក្នុងនោះបានមានខ្លឹមសារលើកឡើងថា "កែវ សារឿន បានខូចសីលធម៌ជាមួយនារីឈ្មោះហេង ដែលកាន់នាទីខាងដឹកជញ្ជូន"។ ខ្ញុំចង់សួរលោកថា តើធ្វើម្តេចបានជាលោកដឹងថា ព័ត៌មានទាំងអស់នេះ? ហើយលោកបាននិយាយបន្ថែមទៀតថា "ស៊ូ សារឿន បានបង្ហាញខ្ញុំ ខ្ញុំគ្រាន់តែដឹងខ្លឹមសារប៉ុណ្ណឹង។ ស៊ូ សារឿន បានដកទូរលេខនោះពីហោប៉ៅមកបង្ហាញខ្ញុំ ដោយនិយាយថា មន្ទីរ៨៧០ បានយកមកឲ្យគាត់" បញ្ចប់ការដកស្រង់សម្តីរបស់លោក។ សំណួរទី១ របស់ខ្ញុំសូមសួរលោក គឺថា តើ កែវ សារឿន មានតួនាទីអ្វីដែរ នៅក្នុង៨០១ ហើយតើគាត់ជានរណាដែរ?

[១៥:០៤:៥១]

**លោក អ៊ុំ រ៉ែន៖**

**ឆ៖** បាទ កែវ សារឿន គឺតាមពិតគាត់ជាប្រធានកងពល៨១ របស់៨០១ ប៉ុន្តែក្រោយដែលទទួលសារនេះ គាត់ហើយនិងខ្ញុំហ្នឹងបានរួមជាមួយនឹង ស៊ូ សារឿន នេះរៀបចំជាកងពល។ ដូច្នេះក្នុងរបាយការណ៍ដែលមក ស៊ូ សារឿន ស្តីអំពីបញ្ហាដែលខូចសីលធម៌នេះ គឺគាត់លែងនៅក្នុងកងពល -- លែងនៅក្នុងវរសេនាធំទៅហើយ គឺគាត់នៅក្នុងកង ហៅថា គណៈកងពលហើយបាទ។ គាត់ចេញពីអង្គភាពវរសេនាធំមកនៅក្នុងកងពលហើយ។

**ស៖** តើខូចសីលធម៌នេះ ខូចសីលធម៌អ្វីដែរ? តើលោកនៅចាំទេ ខូចសីលធម៌ដែលគេចោទ កែវ សារឿន នេះគេចោទថាខូចសីលធម៌យ៉ាងម៉េចដែរ?

**ឆ៖** បាទ បញ្ហាខូចសីលធម៌នេះ គឺក្នុងសារនេះក៏និយាយពីបញ្ហាខូចសីលធម៌ជាមួយនារីនេះឯង និងសារហ្នឹង គឺចេញមកពីកន្លែងកងពលហ្នឹងឯង។ មិនមែនមកពី៨១ទេ។

[១៥:០៦:៤២]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែលនេះ ត្រង់ខ្មែរលេខ 00398514, អង់គ្លេសមានលេខ 00408396, បារាំងមានលេខ 00434423។ ក្រោយមកគេសួរលោកថា ហេតុដូចម្តេចបានជាមន្ទីរ៨៧០ ធ្វើការងារទៅលើបញ្ហាទូរលេខ ហើយបានលើកឡើងអំពី កែវ សារឿន ខូចសីលធម៌។ លោកបានឆ្លើយដូចតទៅថា "តាមខ្ញុំសង្កេត បញ្ហាដែលទាក់ទងទៅនឹងវិន័យដូចនេះ គឺត្រូវតែឆ្លងកាត់មន្ទីរ៨៧០"។ បន្តទៅខាងក្រោយបន្តិច លោកបានឆ្លើយថា ដកស្រង់សម្តីរបស់លោក "តាមខ្ញុំដឹងអ្នកធំៗ ដូចជាគណៈមជ្ឈិម ឬគណៈ៨៧០ ជាទូទៅតែងតែជជែកពិភាក្សាគ្នាអំពីបញ្ហាដែលកើតឡើងទើបសម្រេចអ្វីមួយ" បញ្ចប់ការដកស្រង់សម្តីលោក។ តើមានហេតុផលអ្វីដែរ ដែលធ្វើឲ្យលោកជឿថា អ្នកខាងលើនោះ គឺបានចូលរួមធ្វើសេចក្តីសម្រេចលើកម្មាភិបាលដែលខូចសីលធម៌ ឬក៏មានបញ្ហាមួយចំនួន ឧទាហរណ៍ជាក់ស្តែងដូចករណី កែវ សារឿន?

[១៥:០៨:១៣]

**ឆ៖** បាទ ចំពោះបញ្ហានេះ ខ្ញុំបញ្ជាក់ជូនថា បញ្ហានេះគឺ ពីព្រោះមេបញ្ជាការ ឬហៅថាមេបញ្ជាការ ឬក៏ប្រធានកងពលមកធ្វើការនៅភ្នំពេញនេះឯង។ ដូច្នេះសារទូរលេខ ឬក៏តេអូតាមរយៈហ្នឹងទាល់តែមកតាមរយៈ៨៨០ -- ៨៧០។ ដូចនេះគាត់មានតេអូណា មានអីមកតាមទៀត ដូច្នេះតាមរយៈហ្នឹងឯង បាទ។ ហើយក្នុងនោះទៀត ខ្ញុំឃើញថា បានជាខ្ញុំចាប់អារម្មណ៍ថា កែវ សារឿន ច្បាស់ជាគាត់មិនហ្នឹងតទៀតទេ ច្បាស់ជាគេឃុំឃាំង ឬក៏យ៉ាងណាហើយ ពីព្រោះកន្លងមកគាត់ឧស្សាហ៍បញ្ហានេះគឺខាងស្រីញីនេះគាត់ ជាប្រចាំរបស់គាត់ដែរ។ ហើយដូច្នេះក្នុងរបបនោះមិនសូវរវីរវល់នឹងបញ្ហានេះប៉ុន្មានទេ។ តែមានរឿងគឺថា ច្បាស់ជាទៅហើយ។ ដូចនេះ ខ្ញុំចង់បញ្ជាក់អ៊ីចឹង។

[១៥:០៩:៤០]

**លោក ឌេល លីសាក់៖**

លោកប្រធាន ពេលនេះខ្ញុំសូមអនុញ្ញាតបញ្ចាំង -- បញ្ជូនឯកសារមួយទៀតជូនទៅកាន់សាក្សីគឺឯកសារពាក់ព័ន្ធទៅនឹង កែវ សារឿន។ ឯកសារនេះលេខ E3/806 ជាកំណត់ហេតុចុះ -- ប្រជុំចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ៧៦ ប្រជុំរវាង ៨០១ និងបង៨៩។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបញ្ជូនឯកសារនេះទៅកាន់សាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីនេះគឺជាកំណត់ហេតុនៃការប្រជុំថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធទៅនឹងការប្រជុំជាមួយនឹងកងពល៨០១ ។ នៅក្នុងចំណុច៣ នៃរបៀបវារៈ គឺលើកឡើងអំពីបញ្ហាសមមិត្ត កែវ សារឿន ហើយប្រសិនបើលោកមើលចុងនៃចុងទំព័រនៃឯកសារនេះដែលពាក់ព័ន្ធទៅនឹងយោបល់ពីបង៨៩ យោបល់នោះបានសរសេរថា “ចំពោះបញ្ហា កែវ សារឿន ទុកឲ្យគាត់អ៊ីចឹងសិនទៅ” ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដីត្រង់ចំណុចនេះ។ ខ្ញុំសូមសួរលោកអំពីឯកសារមួយនេះ។ បុគ្គលដែលនៅក្នុងនេះថាជាអ្នកកាន់កាប់៨០១ នោះ គឺបុគ្គលឈ្មោះ ធឿន និង ធី តើលោកចាំទេ? បុគ្គលឈ្មោះ ធឿន និង ធី នេះជានរណាដែរ ដែលថាជាអ្នកកាន់កាប់ ៨០១នេះ?

[១៥:១១:៥៣]

**លោក អ៊ុំ រ៉ែន៖**

**ឆ៖** បាទគឺខ្ញុំសូមជម្រាបថា ចំពោះ ធឿន និង ធី នេះ ខ្ញុំអត់ស្គាល់តែម្ដង អត់ស្គាល់ទេ។

**ស៖** តើលោកចាំបុគ្គលម្នាក់ឈ្មោះ សឿន ដែលធ្វើជាអនុប្រធានកងវរសេនាធំ៨២ តើលោកចាំទេ បុគ្គលឈ្មោះ សឿន ហ្នឹង?

**ឆ៖** ខ្ញុំស្គាល់ដែរឈ្មោះ សឿន។

**ស៖** តើលោកដឹងទេ បញ្ហាពាក់ព័ន្ធទៅនឹង កែវ សារឿន នោះតើមានបញ្ហាអ្វីដែរ? តើគេបានពិភាក្សាគ្នាអំពីបញ្ហាគាត់ខូចសីលធម៌ ដែលយើងបាននិយាយអំពីចំណុចនេះអម្បាញ់មិញនេះ ឬក៏យ៉ាងម៉េចដែរ នៅពេលដែលគេពិភាក្សាគ្នាអំពីបញ្ហា កែវ សារឿន?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា បញ្ហាព្រឹត្តិការណ៍ កែវ សារឿន នេះ ដូចខ្ញុំបានបញ្ជាក់ពីខាងដើម។ ខ្ញុំមកដល់ខ្ញុំរៀន ហើយក៏គ្រុន ៗហើយក៏នៅហ្នឹង។ ដូច្នេះ កងពលមេបញ្ជាការកងពលត្រឡប់ទៅកន្លែងវិញ មិនដឹងគេប្រជុំដោះស្រាយយ៉ាងណាៗទេ ក៏ខ្ញុំក្ដាប់មិនបាន ប៉ុន្តែក្រោយមកខ្ញុំត្រឡប់ទៅពីនេះវិញក៏មិនដឹងថា កែវ សារឿន ទៅនៅកន្លែងណាដែរ។

[១៥:១៣:៤៥]

**ស៖** លោកសាក្សី តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ? តើកងពល៨០១នេះបានរាយការណ៍អំពីការខូចសីលធម៌របស់ កែវ សារឿន ទៅអគ្គសេនាធិការដែរឬទេ? តើខាង៨០១នេះ ខាងកងពល៨០១មានរាយការណ៍តាមរយៈធ្វើកំណត់ហេតុ ឬក៏ជូនដំណឹងដោយផ្ទាល់មាត់ទៅអគ្គសេនាធិការដែរឬទេ អំពីការខូចសីលធម៌របស់ កែវ សារឿន?

**ឆ៖** បាទខ្ញុំចង់បញ្ជាក់បញ្ហានេះដែរគឺ តាមពិតគឺសារទូរលេខនេះ គឺចេញមកពីមន្ទីរ៨៧០។ ដូច្នេះ សារទូរលេខនេះ តាមពិត គឺខ្ញុំថាច្បាស់ជា០៥ ហ្នឹងយកទៅឲ្យជូនខាងលើហើយ ពីព្រោះគាត់ថាទុកមួយជូនខាងលើហើយ ឲ្យមួយមកខ្ញុំនេះ។ ហើយខ្ញុំក៏ទុកបាត់ទៅ។

[១៥:១៥:០០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោក។ លោកប្រធាន ខ្ញុំចង់បង្ហាញសាក្សីនូវរបាយការណ៍ចំនួនពីរផ្សេងទៀតដែលកងពល៨០១នេះ បញ្ជូនទៅឲ្យបង៨៩។ ឯកសារមួយនោះ គឺមានលេខ E3/1061 គឺចុះថ្ងៃ០៤ ខែមីនា ឆ្នាំ៧៧។ ហើយរបាយការណ៍មួយទៀត គឺលេខ E3/1060 ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឯកសាររបាយការណ៍ពីរនេះ ជូនទៅកាន់សាក្សី។ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ្វីដែលខ្ញុំចង់ឲ្យលោកពិនិត្យមើលឯកសារនេះ គឺថាឲ្យលោកពិនិត្យមើលហត្ថលេខានៅចុងទំព័រខាងក្រោយ នៅក្នុងឯកសារនេះ ហើយតើលោកអាចបញ្ជាក់ដែរឬទេ តើនរណាគេជាអ្នកចុះហត្ថលេខា និងបញ្ជូនរបាយការណ៍នេះ? គឺឯកសារលេខ E3/1061 និង E3/1060 តើនរណាគេដែលជាអ្នកចុះហត្ថលេខា និងបញ្ជូនរបាយការណ៍នេះ ឡើងទៅលើ?

**លោក អ៊ុង វ៉ែន៖**

**ឆ៖** នេះ ខ្ញុំមើលតែហត្ថលេខាទេ គឺដាក់ថា "មិត្តរឿន" ព្រោះ រឿន នោះគឺជាប្រធានកងពលនេះឯង។

**ស៖** តើលោកស្គាល់ហត្ថលេខារបស់ខាងដែលប្រធានកងពលឈ្មោះ រឿន នេះដែរឬទេ?

[១៥:១៧:២២]

**ធ៖** ខ្ញុំស្គាល់តើ។ ខ្ញុំស្គាល់ស៊ីញ៉េរបស់ ស៊ូ សារឿន។

**ស៖** របាយការណ៍ទាំងពីរ កំណត់ហេតុទាំងពីរនេះ គឺថាយើងឃើញមានចំណារផ្ទាល់ដៃនៅទំព័រទី១ ផ្នែកខាងឆ្វេងខាងលើ គឺមានចំណារសរសេរដោយដៃ។ ចំណារនេះ គឺសរសេរថា "របាយ-ការណ៍កំណត់ហេតុនេះ បញ្ជូនទៅអង្គការ"។ តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ លោកស្គាល់ទេចំណារសរសេរដោយផ្ទាល់ដៃនេះ ដែលដាក់ថា "ផ្ញើជូនបន្តទៅដល់អង្គការនោះ"។ តើលោកស្គាល់ចំណារនេះទេ?

**ធ៖** ខ្ញុំមិនស្គាល់ទេ។

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរបាយការណ៍នេះ។ ខ្ញុំសូមចាប់ផ្តើមឲ្យលោកពិនិត្យមើលឯកសារ E3/1061 គឺចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ នៅចំណុចលេខ៣ នៅក្នុងរបាយការណ៍មួយនេះ។ នៅក្នុងចំណុចទី៣ហ្នឹង គឺថា មេកងពល សារឿន និយាយអំពីការចាប់ខ្លួនយួន៧នាក់ ហើយនិងការឆ្លើយតបមកវិញ។ ខ្ញុំចង់សួរលោក តើនរណាគេជាអ្នកទទួលខុសត្រូវធ្វើការសួរចម្លើយខ្មាំងយួន៧នាក់ ឬក៏គិញយួន៧នាក់នោះ ដែលត្រូវបានចាប់ខ្លួននោះ?

[១៥:១៩:១៣]

**ធ៖** បាទ ដូចខ្ញុំជម្រាបខាងមន្ត្រីស៊ើបអង្កេតអ៊ីចឹង គឺចំពោះបញ្ហារឿងថាចាប់យួនបានអី គឺខ្ញុំមិនដែលចាប់បានទេ នៅក្នុងអង្គភាពខ្ញុំ។ ប៉ុន្តែដោយឡែក នៅតាមអង្គភាពផ្សេង គេចាប់បានក៏មិនដឹងបើខ្ញុំ ខ្ញុំក្តាប់មិនទេ ព្រោះខ្ញុំនៅវ៉ឺនសៃឯណោះ បាទ។ ហើយបញ្ជូនទៅខាងណា ខាងលើ ឬក៏នៅកន្លែងណាៗខ្ញុំអត់ដឹងទេ។

**ស៖** ប្រសិនបើលោកមើលឯកសារមួយទៀត គឺឯកសារ E3/1060 គឺចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ ផ្ញើពី សារឿន ទៅដល់បង៨៩។ ចំណុចទី១ នៃរបាយការណ៍នេះនិយាយអំពីសភាពការណ៍ខ្មាំង។ នៅក្នុងចំណុចទី១នេះ លេខាកងពលគឺបានផ្តល់របាយការណ៍លម្អិតពាក់ព័ន្ធទៅនឹងបាតុភាពខ្មាំងនៅមូលដ្ឋាន រួមទាំងតំបន់១០៧, ១០១ និង១០៤។ សំណួរដែលខ្ញុំចង់សួរលោកនោះ គឺថា តើលោកយល់ ឬក៏បានដឹង ថាតើលេខា សារឿន នោះ គាត់ធ្វើយ៉ាងម៉េចទើបអាចរាយការណ៍អំពីសភាពការណ៍ខ្មាំងនៅមូលដ្ឋាន? តើលោកដឹងទេ គាត់ទទួលរបាយការណ៍ ឬព័ត៌មានអំពីស្ថានភាពខ្មាំងនេះពីបុគ្គលណាដែរ?

**ឆ៖** បញ្ហាដូចខ្ញុំបានជម្រាបពីខាងដើមនេះ គឺពិតមែនតែនៅក្នុងកងពលតែមួយ ប៉ុន្តែវរសេនាធំខ្ញុំ គឺនៅឆ្ងាយដាច់ស្រយាល ដូច្នេះមិនមែននៅជាប់គ្នាមួយគីឡូពីរគីឡូឯណា។ ដូច្នេះសភាពការណ៍មុខសញ្ញាអង្គភាពណា អង្គភាពនោះរាយការណ៍ទៅកន្លែងកងពល។ ដូច្នេះ កងពលអត់មានបានប្រាប់មកកន្លែងវរសេនាធំផ្សេង ដូច្នេះបានជាបញ្ហានេះមិនដឹង ហ្នឹងមួយ។ ដូច្នេះ ខ្ញុំតាមពិនិត្យមើលចំណារនេះក៏មិនមែនជាចំណាររបស់ ស៊ូ សារឿន មិនដឹងចំណារពីខាងណាទេ ព្រោះអក្សរ ខ្ញុំធ្លាប់ស្គាល់។

[១៥:២១:៥១]

**ស៖** ប្រសិនបើលោកមើលចំណុចចុងក្រោយនៅក្នុងរបាយការណ៍នេះដាក់ថា ផ្សេងៗ។ ខ្មែរគឺត្រង់លេខ 00231375។ ខ្ញុំចង់ឲ្យលោកមើលចំណុចបួននៅក្នុងសេចក្តីផ្សេងៗនេះ ដែលបានចែងដូចតទៅ៖ "ចំណុចទី១ គឺសភាពការណ៍នៅមូលដ្ឋានសៀមប៉ាង កន្លងមកគ្មានអ្វីប្លែកទេ។ តែបច្ចុប្បន្ននេះមានបាតុភាពមួយឲ្យចាប់អារម្មណ៍នៅអំពីមូលដ្ឋាន។ ឧទាហរណ៍ថា ពីមុនកន្លែងណាស្មុគស្មាញបានឯកភាពគ្នាឲ្យកងទ័ពចុះ ដើម្បីចុះជួយធ្វើប្រជាជន ដូចជាជួយក្តាប់"។ សូមបញ្ចប់ការដកស្រង់សម្តី។ យើងដឹងហើយថា មូលដ្ឋានសៀមប៉ាងនេះ គឺជាតំបន់មួយដែលលោកប្រតិបត្តិការផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា តំបន់សៀមប៉ាងនេះ គឺតាមពិតគឺពេលដែលខ្ញុំនៅមិនទាន់មានបញ្ហាអីស្មុគស្មាញទេ។ ទី១ ប្រជាជនក៏មិនមានអី។ ទី២ ចំពោះតាមព្រំដែនជាយួន ជាលាវ អីក៏អត់មានឃើញមានសភាពការណ៍អី។ ជារួមមកអត់ទាន់មានអីប្រែប្រួលដូចក្នុងឯកសារនេះទេ។

**ស៖** តើវាអាចដែរឬទេថា នៅពេលដែលគេបញ្ជូនរបាយការណ៍នេះនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ នោះ គឺលោកបានចាកចេញពីសៀមប៉ាងទៅធ្វើការនៅកន្លែងផ្សេងរួចទៅហើយ តើអ៊ីចឹងដែរឬទេ?

[១៥:២៤:00]

**ឆ៖** បាទ បញ្ហានេះគឺច្បាស់អ៊ីចឹង ព្រោះបើសិនណាជាខ្ញុំនៅហ្នឹង ខ្ញុំដឹងថាសភាពការណ៍នៅប្រជាជន ឬក៏សភាពការណ៍លាវអីយ៉ាងម៉េចៗ ខ្ញុំក្តាប់បានដូចនិយាយពីខាងដើមថា កាលខ្ញុំនៅមិនទាន់មានអីប្រែប្រួលទេ។ ហើយកន្លងមកគឺគិតតែតាមព្រំដែន អត់មានចាប់អារម្មណ៍អីទេ។ ដូច្នេះអត់ទាន់មានបញ្ហាអី។ ដូច្នេះក្នុងរបាយការណ៍គ្រប់ទាំងអស់នេះ ខ្ញុំផុតអស់ហើយតាមខ្ញុំពិនិត្យមើលទៅ អត់មាននៅក្នុងកន្លែងដែលខ្ញុំនៅហ្នឹងទេ។

**ស៖** ប្រសិនបើលោកមើលចំណុច៣វិញម្តង ត្រង់ទំព័រអម្បាញ់មិញនេះ។ នៅក្នុងចំណុច៣នេះ សារឿន និយាយអំពីបញ្ហានៅតំបន់១០១ ខ្ញុំសូមដកស្រង់សម្តី "នៅពេលគេ -- កងទ័ពចាប់ខ្មាំង គឺថាខ្មាំងនោះ គឺយើងធ្វើការកម្ទេចខ្មាំង ហើយធ្វើឲ្យវាបាត់ដានទៅលើខ្មាំងតែម្តង"។ ហើយខ្ញុំសូមដកស្រង់បន្ត "ក៏ប៉ុន្តែខ្ញុំបានជួប ហើយនិយាយបញ្ហាហ្នឹងជាមួយនឹង ធិន"។ សំណួររបស់ខ្ញុំនោះគឺថា នៅពេលឯកសារនេះបានធ្វើរបាយការណ៍ តើ ធិន នេះគឺជាប្រធាន៨០១ ដដែល ឬក៏គាត់បានផ្លាស់ទៅតំបន់១០១រួចទៅហើយ ដែលគាត់នៅក្នុងនេះនិយាយអំពី១០១ ផងដែរ។ ហើយលោកក៏បានឆ្លើយទៅលើចំណុចហ្នឹងនៅក្នុងរបាយការណ៍ចៅក្រមស៊ើបអង្កេត។ តើ ធិន ហ្នឹងផ្លាស់រួចហើយឬនៅ?

**ឆ៖** បញ្ហា ធិន នេះគឺខ្ញុំគ្រាន់តែដឹងថាគាត់នៅក្នុង៨០១ ក៏អង្គភាព៨៣។ ប៉ុន្តែក្រោយមកខ្ញុំឮថាគាត់ទៅនៅធ្វើជាគណៈតំបន់នៅម្តុំរ៉ុនសៃនោះវិញ។ ដកពីយោធា -- ពីកងពល៨០១ទៅ។ ខ្ញុំបានឮប្រធានកងពលខ្ញុំប្រាប់ថាអ៊ីចឹង ថាមូលហេតុអីបានគាត់ទៅនៅហ្នឹងវិញ? គឺថាបញ្ហាសភាពការណ៍នេះទាល់តែ ធិន ហើយ ព្រោះ ធិន គាត់ជាជនជាតិទំពួន ដូច្នេះទាល់តែយកបងប្អូនជនជាតិទៅនៅជាមួយទើបវាសុខស្រួល។ នេះគ្រាន់តែខ្ញុំក្តាប់បានតែប៉ុណ្ណឹងឯង។

[១៥:២៦:៤៥]

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ តើវាជាគោលនយោបាយនៅក្នុងជួរកងទ័ពកម្ពុជាប្រជាធិបតេយ្យដែរឬទេ ដែលថាអ្នកដែលត្រូវបានចាប់ខ្លួនដោយទាហាននៃរបបកម្ពុជាប្រជាធិបតេយ្យនោះត្រូវតែយកមកសួរចម្លើយដើម្បីស្វែងរកខ្សែក្បត់របស់ពួកវាបន្ត មុនពេលយកពួកវាទៅសម្លាប់ចោល។ តើវាជាគោលនយោបាយអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថាបញ្ហានេះគឺខាងខ្ញុំគឺក្តាប់មិនបានទេ រឿងបញ្ហាចាប់ទាហានក្តី ឬក៏ចាប់ផ្ទៃក្នុង ដែលចោទថាអ៊ីចេះអ៊ីចុះ គឺដូចថាគ្មាននយោបាយអីទៅសួរចម្លើយ សួរនាំអី គឺមានតែដាក់គុកដាក់ច្រវាក់អ៊ីចឹង ហើយសួរចម្លើយ គឺចាប់បង្ខំឲ្យគ្នានិយាយ ឲ្យគ្នាស្រែកទៅ បានវាចេះតែវាលដានអ៊ីចឹង តាមខ្ញុំយល់អ៊ីចឹងទេ។ ប៉ុន្តែមិនដែលឃើញថាមានអីដែលត្រូវដោះស្រាយឲ្យស្រួលទេ ហើយមានអីដែលដឹងថាចាប់អ្នកណា ថ្ងៃណាអី ក៏អត់ដឹងដែរ ច្រើនតែបាត់មនុស្សមិនដឹងខ្លួន។ ដូច្នេះ មិនដឹងជាមានគោលបយោបាយអប់រំយ៉ាងម៉េចៗ គឺខ្ញុំក្តាប់មិនបានទេ។ ប៉ុន្តែសម្រាប់ដែលខ្ញុំនៅអង្គភាពរបស់ខ្ញុំនៅសៀមប៉ាង កម្លាំងរបស់ខ្ញុំនៅទាំងអស់ គឺគ្មានរង្គោះរង្គើទេ។ ប៉ុន្តែដោយឡែក ខ្ញុំមកនៅក្នុងកងពល៨០១ ដោយ០៦ ទៅនៅមណ្ឌលគិរី មកវិញចេះតែរពើតរពើង ហើយសួរពីនេះក៏បាត់ ពីនោះបាត់។ ខ្ញុំដឹង

ថាមនុស្សដែលបាត់មិនដឹងទៅខាងណា។ ខ្ញុំចង់ជម្រាបប៉ុណ្ណឹងហើយ។

[១៥:២៨:៤៦]

**ស៖** សូមអរគុណ។ ប្រសិនបើលោកមើលចំណុចចុងក្រោយទំព័រចុងក្រោយនៃឯកសារនេះ គឺថានៅក្នុងចំណុច៥ នៅជិតចុងក្រោយនៃទំព័រនេះ។ គឺរបាយការណ៍ដែលធ្វើឡើងដោយ រឿន បាន លើកឡើងថា ដកស្រង់សម្ដី “ស្ថានភាពអង្គភាពយើងកំពុងតែតាមដានសភាពដែលអន្តរាយដល់បដិវត្តន៍ ទាំងថ្មីទាំងចាស់ គឺអ្នកទំនាស់នឹងមាគ៌ា និងពួកខ្មាំងឆ្លើយដាក់ទាំងចាស់ទាំងថ្មី” សូមបញ្ចប់ការដកស្រង់ សម្ដី។ ពាក់ព័ន្ធទៅនឹងការលើកឡើងមាគ៌ាបដិវត្តន៍ តើលោកដែលធ្លាប់ដឹងថា សារឿន នេះមានធ្លាប់មក អប់រំអំពីមាគ៌ាបក្សដែរឬទេ? តើមាគ៌ាបក្សនិងមាគ៌ាបដិវត្តន៍ហ្នឹងមានចំណុចដូចគ្នាដែរឬទេ? តើវាដូចគ្នា ដែរឬទេ ចំពោះមាគ៌ាបក្ស និងមាគ៌ាបដិវត្តន៍?

**ឆ៖** បាទ តាមពិតនិយមន័យនេះជាន័យតែមួយទេ ប៉ុន្តែជាក់ស្ដែងការអនុវត្តលើបញ្ហាគោល ការណ៍នេះ គឺអត់ស្របនឹងមតិដែលគោលការណ៍ថា មាគ៌ាល្អត្រឹមត្រូវ នោះអត់ត្រូវតាមហ្នឹងទេ។ ឃើញតែការខូចខាត ឃើញតែការវិនាសអន្តរាយ បាទ។

**ស៖** ចំពោះអ្នកដែលតវ៉ា ឬជំទាស់នឹងមាគ៌ាបដិវត្តន៍នោះត្រូវបានគេចោទថា ជាខ្មាំងរបស់របប ហ្នឹងដែរឬទេ?

[១៥:៣០:៤៥]

**ឆ៖** បាទ បញ្ហានេះ ខ្ញុំសូមបញ្ជាក់ថា តាមពិតគឺខ្ញុំនិយាយតែនៅអង្គភាពខ្ញុំទេ ហើយក្រៅពីនោះ ខ្ញុំក្ដាប់មិនបាន ខ្ញុំមិននិយាយ។ ហើយក្រោយពីខ្ញុំត្រឡប់ពី ទៅពី*(ឮមិនច្បាស់)* នេះទៅវិញ ឲ្យទៅនៅ ហៅថា បឹងកន្សែងបានលុង។ តាមពិតមុនមក ដែលមកដល់វ៉ុនសែនេះក៏មិនដឹងថា គេមានសន្តិសុខ របៀបណាអី យ៉ាងណាអី ចាប់ចងយ៉ាងម៉េចក៏អត់ដឹងទេ។ បាទ ទៅពីនេះវិញទៅដល់គេថា ឲ្យទៅជួយ ធ្វើការងារអង្គភាពវិញបាទ។ ហើយទៅដល់មិនឲ្យទៅសៀមប៉ាង ឬទៅណាទេ ទៅដល់ចុះពីលើ កប៉ាល់ហោះ គេឲ្យជូនទៅម៉ូតឌុបទៅដាក់នៅបឹងកន្សែង នៅរហូតទាល់តែព្រឹត្តិការណ៍នៅភ្នំពេញនេះ តែម្ដង។

ហើយតាមពិតដែលក្ដាប់បាន គឺបានដឹងថានៅបឹងកន្សែង នៅបានលុងមានគុកនេះ អ៎! មាន សន្តិសុខ មានគុកនេះ គឺតាមរយៈប្រជាជនដែលនៅក្បែរៗនោះទេ។ បាទ គាត់មានកូនម្នាក់ពីរនាក់អីចឹង ធ្វើការហាត់ហេរទៅក្នុងសហករណ៍គេ ទៅលួចដំឡូង ទៅគាស់ដំឡូងយកមកដុតមកអីហ្នឹងចោទគ្នា

អ៊ីចេះអ៊ីចុះ គាត់ចេះតែមករអ៊ូរទាំនិយាយប្រាប់ខ្ញុំអ៊ីចេះអ៊ីចុះទៅ ក៏មិនទាន់ដឹងថា មានសន្តិសុខអីយ៉ាងណាទេ។

[១៥:៣២:១៦]

ទាល់តែពេលថ្ងៃមួយមានអ្នកទោសរត់ពី-- គាស់គុករត់មកអូរកន្សែងនេះបានប្រជាជនប្រាប់ថា អ៊ូ! គុកអូរកន្សែងនេះរត់។ បានខ្ញុំថា អ៊ូ! កងពលនេះក៏មានកន្លែងសន្តិសុខដែរ ខ្ញុំអ៊ីចឹង។ ដូច្នេះក៏ប្រជាជនសូមសំណូមពរខ្ញុំឲ្យជួយដោះស្រាយកូន។ ហើយជាក់ស្តែងខ្ញុំ និង០៥ ដែលគាត់មកពីសមរភូមិវិញ ខ្ញុំនៅបឹងកន្សែង ក៏គាត់អញ្ជើញគាត់ទៅលេងផ្ទះខ្ញុំហ្នឹង ក៏ខ្ញុំនិយាយជម្រាបគាត់អ៊ីចេះទៅ បញ្ហាមនុស្សនេះអ៊ីចេះៗចំនួនប្អូនដប់ម្ភៃនាក់ អាហ្នឹងមានតែបញ្ហារឿងដកដំឡូង រឿងបញ្ហាអីប៉ុណ្ណឹងទេ អត់មានអីធំដុំទេ។ ដូច្នេះបងគិតយ៉ាងម៉េច? ដល់អ៊ីចឹងគាត់ថា ទេបើអ៊ីចឹងគិតឲ្យលែងទៅ។ បាទ ខ្ញុំសម្រួលជាមួយគាត់ហ្នឹងប្រហែលជា ២០នាក់ដែរ នៅបឹងកន្សែងនេះឯង។ បាទ ខ្ញុំដឹងថា អ៊ូ! នៅកន្លែងមានគុកមានអីហើយ។ បាទ អ៊ីចឹងទេ បានអារម្មណ៍របស់ខ្ញុំថា ប្រហែលជាគ្មានច្បាប់ទម្លាប់មិនដឹង ប្រហែលជាមានគុកមានអីមែនដឹង បានជាបាត់មនុស្ស បាត់ៗទៅ។ បាទ ហ្នឹងមួយ។ ដូច្នេះខ្លួនផ្ទាល់ថា ឲ្យទៅជួយការងារតាមអង្គភាពទៅនៅបឹងកន្សែងអត់ការងារអីរលីង។ ហ្នឹងជម្រាបប៉ុណ្ណឹង ជម្រាបវែងបន្តិចហើយ សូមអស់។

**ស៖** ត្រឡប់មកកថាខណ្ឌទី៥ នៃឯកសារនេះ គឺមានកំណត់ត្រា គឺនិយាយថា មនុស្សម្នាក់ដែលជា-- ដែលគេឆ្លើយដាក់ថ្មីៗនេះ ចំពោះមនុស្សដែលគេត្រូវឆ្លើយដាក់ហ្នឹងថា តើគេចង់និយាយដូចម្តេចចំពោះអ្នកនោះ?

[១៥:៣៤:១៦]

**ឆ៖** ខ្ញុំមិនយល់សំណួរ។ សូមម្តងទៀត។

**ស៖** បាទ សំណួរខ្ញុំ គឺនៅកថាខណ្ឌ៥ ចំណុចទី៥ និយាយថា "ទិសដៅ គឺពួកទាំងឆ្លើយដាក់ទាំងចាស់ ទាំងថ្មី ដែលខ្មាំងឆ្លើយដាក់"។ តើមានន័យដូចម្តេចនៅពេលដែលគេនិយាយថា ពួកមនុស្សដែលខ្មាំងឆ្លើយដាក់នោះ?

**ឆ៖** បាទ បញ្ហានេះក៏ខ្ញុំសូមជម្រាបថា ក្នុងសំណួរនេះ គឺផ្ទាល់ខ្លួន ខ្ញុំមិនគឺមិនយល់ទេ ចំពោះកម្លាំងហ្នឹង គឺគេគិតយ៉ាងម៉េច ហើយកម្លាំងថ្មី តែតាមពិតក្នុងអង្គភាពសុទ្ធតែជាកម្លាំងចាស់ទាំងអស់ អត់មានកម្លាំងថ្មីទេ។ ប៉ុន្តែក្នុងនេះ ចង់និយាយថាកម្លាំងចាស់ ហើយកម្លាំងថ្មី។ ដូច្នេះខ្ញុំ មិនដឹងៗ

គាត់ចង់និយាយកម្លាំងយ៉ាងម៉េចក្នុងរបាយការណ៍នេះ។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់ទៅចំណុចមួយអំពីសមមិត្ត កែវ សារឿន ដែលជាអតីតលេខាវរសេនាធំ ហើយត្រូវបានគេចោទប្រកាន់ ហើយការសម្ភាសទី២ របស់លោកគឺ E3/84, 00398513, អង់គ្លេស 00408395, ហើយបារាំង ERN 00434422។ លោកបានឆ្លើយដូចខាងក្រោមនេះ "កែវ សារឿន ដែលត្រូវបានហៅទៅភ្នំពេញ ដោយគណៈមជ្ឈិម ហើយត្រូវបានបាត់ខ្លួនភ្លាមៗ" សូមបញ្ចប់សេចក្ដីដកស្រង់។ តើជារឿងធម្មតាដែរឬទេនៅពេលដែលកម្មាភិបាលកងពលត្រូវបានគេចាប់ខ្លួន ឬបោសសម្អាត គេតែងតែហៅ អញ្ជើញមកភ្នំពេញនោះ?

[១៥:៣៦:៤៩]

**ឆ៖** បាទ តាមពិតគឺក្នុង នៅមតិនេះគឺខ្ញុំចង់បញ្ជាក់ថា កាលដែលខ្ញុំបានមកដល់ភ្នំពេញនេះ គឺមានសារទូរលេខទេ ហើយនិយាយអំពីការខូចសីលធម៌នេះ ចំពោះ កែវ សារឿន តាមរយៈ៨៧០។ ប៉ុន្តែតាមពិតដែលខ្ញុំចង់និយាយនៅពេលនេះ គឺថា កែវ សារឿន ត្រូវខាងអង្គការ ឬខាងលើចាប់អីយ៉ាងម៉េចអាហ្នឹងខ្ញុំ ខ្ញុំមិនច្បាស់ទេ។ ប៉ុន្តែជាទស្សនៈផ្ទាល់ខ្លួនខ្ញុំថា ច្បាស់ជាគេចាប់ហើយ បាទ ពីព្រោះឲ្យតែប៉ះពាល់អីចឹងៗហើយ គឺថាត្រូវតែបាត់ខ្លួនបាទ។ ខ្ញុំចង់បញ្ជាក់តែប៉ុណ្ណឹង ដូចខ្ញុំបញ្ជាក់មុន ខាងមុនខាងដើម។

**ស៖** បន្ទាប់ពី កែវ សារឿន គេហៅទៅភ្នំពេញ ហើយក៏បាត់ខ្លួននោះ តើលោកបានដឹងអ្វីផ្សេងទៀតទេ ថាគេឆ្លើយដាក់ បានន័យថាលោក សារឿន ឆ្លើយដាក់លោកដែរឬទេ?

**ឆ៖** បាទ បញ្ហានេះក៏ខ្ញុំសូមបញ្ជាក់ៗថា ក្រោយពីខ្ញុំទៅដល់ក្នុងវិញទៅ ទៅនៅបឹងកន្សែងនេះ ក៏ជួបមេបញ្ជាការខ្ញុំនេះ ក៏គាត់ប្រាប់ថានៅនេះហើយ អត់មានបញ្ហាអីទេ ហ្នឹងហើយ។ ហើយនែ៎ កែវ សារឿន ហើយនិង ស៊ន នេះឆ្លើយដាក់ឯងនេះបានពីរនាក់ហើយ។ បានជាគេឲ្យឯងមកនៅបឹងកន្សែងនេះ។ នេះខ្ញុំចង់បញ្ជាក់អីចឹង។ ដូច្នេះ ពេលនោះខ្ញុំកំណត់ថា ខ្ញុំ -- ធម្មតាព្រោះអ្នកនៅជាមួយគ្នា បើជំរុំធាក់គ្នាទៅ វាចេះតែមិនមានរឿងអីក៏ឆ្លើយដាក់គ្នាអីចឹងទៅ ចេះតែមានរឿង។ ដូច្នេះបាត់ កែវ សារឿន ទៅខ្ញុំតែបារម្ភដែរហ្នឹង។ បានខ្ញុំថា បើមានរឿងអីចឹងហើយ គឺខ្ញុំហ្នឹងក៏មិនយូរប៉ុន្មានដែរ។

[១៥:៣៨:៥៩]

ហើយម្យ៉ាងទៀត ឲ្យមកធ្វើការនៅបឹងកន្សែង អ៎! មកធ្វើការអង្គភាពវិញ ឲ្យមកនៅវ៉ឺនសៃនៅឆ្ងាយពីអង្គភាពប្រហែលជាដើរបួនប្រាំថ្ងៃមិនដល់ផង ហើយថាបើអីចឹងអត់-- តាំងពីនោះមក

គ្មានឃើញស្អីឯណា ណែនាំស្អីណាទេរហូតដល់មានព្រឹត្តិការណ៍នៅភ្នំពេញនេះតែម្តង។ ដូច្នេះបានការសន្និដ្ឋានរបស់ខ្ញុំ តាំងពីទទួលសារដែលថា កែវ សារឿន ខូច ខ្ញុំថាមិននៅទេបាទ។ ខ្ញុំមានមតិប៉ុណ្ណឹង។

**សះ** លោកបានបញ្ជាក់ថា សារឿន បានប្រាប់លោកថា គឺថាមនុស្សពីរនាក់បានចោទ ឆ្លើយដាក់លោក គឺ កែវ សារឿន ហើយនិង ស៊ន។ តើលោកអាចប្រាប់ខ្ញុំបានទេថា ស៊ន នោះជាអ្នកណា? តើគាត់មានតំណែងជាអ្វីនៅក្នុងកងពល៨០១ នោះ?

**ឆះ** ខ្ញុំសូមជម្រាបថា ស៊ន ហ្នឹងគឺ តាមពិតគឺគាត់ពីដើមនៅជាមួយ កែវ សារឿន ទេ ប៉ុន្តែដល់ពេលរៀបចំកងពល៨០១នេះ គាត់ត្រូវតែនៅជាមួយខ្ញុំវិញ គាត់ទទួលខាងភ័ស្តុភារ។ បញ្ជាក់ឡើងវិញគឺ ស៊ន នេះគឺទៅដល់ សៀមប៉ាង ហើយរៀបចំពីភ្នំពេញនេះ គាត់ត្រូវជាគណៈវរសេនាធំ៨២ គឺទទួលខាងភ័ស្តុភារ នៅជាមួយខ្ញុំនេះឯង។

[១៥:៤០:៥២]

**សះ** សូមអរគុណ។ តើលេខាកងពល សារឿន នោះបានបង្ហាញលោកអំពីចម្លើយសារភាពរបស់ កែវ សារឿន ហើយនិង ស៊ន បង្ហាញលោកទេ? ឬក៏គាត់គ្រាន់តែប្រាប់លោកថា អ្នកទាំងពីរនេះបានឆ្លើយដាក់លោក?

**ឆះ** បាទ បញ្ហានេះគឺគាត់មិនបានឃើញយកឯកសារឆ្លើយដាក់អី មកបង្ហាញទេ ប៉ុន្តែគាត់ប្រាប់អ៊ីចឹង ឱ្យជួបគ្នា និយាយតាមមាត់ផ្ទាល់ "គឺបញ្ហានេះឯងដឹងហើយ ឥឡូវសភាពការណ៍មិនល្អទេ ដូច្នេះ ឯងផ្ទាល់មកពីភ្នំពេញវិញដោយសារតែមូលហេតុគេឆ្លើយដាក់ហ្នឹងឯង"។ ព្រោះខ្ញុំយល់ហើយ ព្រោះពីរនាក់ឆ្លើយដាក់ក៏ត្រូវដែរ ព្រោះមិត្តភក្តិនៅជាមួយគ្នា។

**លោក ឌេល លីសាក់៖**

លោកប្រធាន នេះខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវបញ្ជីអ្នកទោសនៅ ស-២១ គឺដែលមានកម្មាភិបាលមកពី កងពល៨០១ ដើម្បីឱ្យគាត់បញ្ជាក់។ ឯកសារ D108/26.86 ជាពិសេស ខ្មែរ ERN 00009293 រហូតទៅដល់ 00009302 ដែលជាបញ្ជីស-២១ មានន័យថាឈ្មោះអ្នកទោស ដែលត្រូវបានកម្ទេចនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧ ដើម្បីឱ្យសាក្សីអាចនឹងបញ្ជាក់ឈ្មោះណាដែលគាត់ស្គាល់ ដែលចេញមកពីអតីតកងពលរបស់គាត់។ សូមតុលាការអនុញ្ញាត។

[១៥:៤៣:០០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសូមទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សីពិនិត្យ)*

[១៥:៤៣:២០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងឯកសារនេះលោកសាក្សី ខ្ញុំសូមឲ្យលោកមើលទំព័រខ្មែរ 00009298, ទំព័រជាភាសាអង់គ្លេស 00873622។ ហើយជាពិសេសនៅអ្នកទោសលេខ១៨៣ រហូតដល់ ១៩១ ដែលគេបញ្ជាក់ថា ជាអ្នកមកពីកងពល៨០១។ ហើយទី១, ១៨៩ នៅក្នុងបញ្ជីនេះ ដែលមានឈ្មោះថា កែវ សារឿន ហៅ សេង សមាជិកកងពល៨០១ ដែលចូលមកស-២១ នៅខែឧសភា ១៩៧៧។ តើលោកអាចប្រាប់ខ្ញុំ បានដែរឬទេ ថា សេង នេះជាឈ្មោះ ហៅក្រៅរបស់ កែវ សារឿន ផងដែរនោះ?

**លោក អ៊ឹង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំស្តាប់ក្នុងសំណួរនេះហើយ ព្រោះខ្ញុំកំណត់ថា កែវ សារឿន ដូចខ្ញុំបានបញ្ជាក់ពីខាងដើមដែរ។ ព្រោះ កែវ សារឿន គឺអាចចាប់ក្នុងរយៈពេលដែលឃើញសារហ្នឹង ហើយបាន១ថ្ងៃពីរទេតាមខ្ញុំមើល។ ហើយតាមពិត កែវ សារឿន នេះគឺឈ្មោះ សេង ហ្នឹងឯង។ ខ្ញុំស្គាល់ទាំងផ្ទះអីគាត់ថែមទៀត។

**ស៖** ១៨៤ នៅលើបញ្ជីនេះជាបុគ្គលម្នាក់មានឈ្មោះថា ទូច ស៊ន ជាអនុ -- បាទ អនុកងពល -- អនុសេនាធំ៨២ គឺទៅដល់ស-២១ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៧។ តើនេះជាបុគ្គលដែលឈ្មោះ ស៊ន ដែលលោកថានៅក្នុងវរសេនាធំ៨២ ដែលបានឆ្លើយដាក់លោកហ្នឹងដែរឬទេ ដែលមានឈ្មោះ ទូច ស៊ន នៅលើបញ្ជីនេះ?

[១៥:៤៦:០៣]

**ឆ៖** ទូច ស៊ន គឺដូចខ្ញុំបានបញ្ជាក់ថា គាត់ជាភ័ស្តុភារវរសេនាធំនៅជាមួយខ្ញុំនេះ។

**ស៖** ឥឡូវនេះយើងមើលកម្មាភិបាលរបស់កងពល៨០១ គឺក្នុងពី១៨៣ រហូតដល់ ១៩១ តើលោកស្គាល់អ្នកណាផ្សេងទៀតទេនៅក្នុងបញ្ជីនេះគឺចាប់ពីលេខរៀង១៨៣ រហូតមកដល់ ១៩១ បាទ?

*(សម្រាករយៈពេលខ្លី)*

[១៥:៤៨:៣៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅជួយចង្អុលបង្ហាញគាត់កម្រិតត្រឹមតែលេខរៀង ដែលតំណាងសហព្រះរាជអាជ្ញាសួរបានហើយ។

**លោក អ៊ុង វ៉ែន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយចំពោះទំព័រ១៨៣ នេះ ខ្ញុំពិនិត្យឃើញអង្គភាពរបស់ខ្ញុំ គឺដែលខ្ញុំស្គាល់គឺមានតែពីរនាក់ដូចខ្ញុំបានជម្រាបពីខាងដើមអ៊ីចឹង គឺ១) ស៊ន ហើយ ២) កែវ សារឿន នេះឯង។ ហើយក្រៅពីនេះអង្គភាព៨០១ ដែរ ប៉ុន្តែអង្គភាពផ្សេង។ សូមបញ្ជាក់ប៉ុណ្ណឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណ។

លោកប្រធាន ឥឡូវនេះខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវផ្នែកមួយនៃចម្លើយសារភាពរបស់កែវ សារឿន នៅភ្នំពេញ។ គឺថាយើង នៅក្នុងបទសម្ភាសន៍របស់គាត់នោះ គឺគេបានបង្ហាញផ្នែកនេះជូនគាត់មើលដែលមាននៅក្នុងនោះមានចំណាររបស់ ឌុច ដែលៗគេបានសួរគាត់នៅក្នុងបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ។ សូមអនុញ្ញាតដាក់ជូន គឺថាឯកសារ D267/2.2 ខ្មែរទំព័រ 00414996, អង់គ្លេស ERN 005283155។ សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញឯកសារនេះជូនទៅលោកសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៥០:០០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ផ្នែកនៃឯកសារនេះដែលខ្ញុំចង់ឲ្យលោកពិនិត្យនោះ គឺចំណារផ្ទាល់ដៃនៅលើក្រប លើចម្លើយសារភាពរបស់ កែវ សារឿន ដែលមានសំណេរផ្ទាល់ដៃចុះថ្ងៃទី០៥ មិថុនា ឆ្នាំ១៩៧៧ ដោយ ឌុច ជូនបងជាទីគោរព ដែលនិយាយថា "នៅពេលសួរអំពីសភាពការណ៍កង អាកែវ សារឿន វារាយការណ៍មនុស្សនៅក្នុងកន្លែងវាបង្កប់នូវ៨០១ ដល់ទៅ៥៨នាក់ ក្នុងនោះមានឈ្មោះ ឆោម, ឡែម, ណាត, ថន, កែវ, ណាង, បាវ ហៅ បាវ ដែលដកឲ្យទៅមូលដ្ឋានវិញហើយជាដើម"។ កាលបរិច្ឆេទនៃ

ចំណាររបស់ ឌុច នេះគឺរាយការណ៍ដែលថា មានមនុស្ស ៥៨នាក់ នៅក្នុងកងពល៨០១ នេះ គឺដែល កែវ សារឿន បានឆ្លើយដាក់នោះ គឺថាមាននៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ៧៧។

[១៥:៥២:២៤]

តើលោកស្គាល់ឈ្មោះទេ ដែលថាអ្នកណាខ្លះដែល កែវ សារឿន ឆ្លើយដាក់ ហើយដែលក្នុងនោះ លោកក៏ សារឿន នោះឆ្លើយដាក់ដែរ?

**លោក អ៊ុង វ៉េន៖**

**ឆ៖** បាទ បញ្ហានេះ គឺខ្ញុំគឺបញ្ជាក់អំពីបញ្ហាកំណត់ហេតុនេះ គឺការដែលមិត្ត សារឿន ឆ្លើយដាក់ ខ្ញុំមើលត្រួសៗនេះ ខ្ញុំស្គាល់តែ ឆោម ហ្នឹងមួយទេ ហើយជាក់ស្តែងគឺ បើសិនណាជាពាក់ព័ន្ធនឹងអង្គភាព ខ្ញុំ ខ្ញុំថា កែវ សារឿន គ្មានលទ្ធភាពទៅចូលក្នុងអង្គភាពខ្ញុំបានទេ ពីព្រោះឆ្ងាយពីគ្នា ហើយមិនស្គាល់ អង្គភាពខ្ញុំតែម្នាក់ក៏មិនស្គាល់ផង។ ដូច្នេះអាចឆ្លើយពាក់ព័ន្ធនឹងអង្គភាពរបស់គាត់ដែលស្គាល់ថា កម្លាំង ៥០នាក់អី គាត់ គេឆ្លើយដាក់អីនុ៎ង អាចមានរឿងអ៊ីចឹង។

**ស៖** យើងបាននិយាយរួចហើយអំពីៗអ្វីដែលលោកបានទទួលដំណឹងពីលេខាកងពល ដែលថា កែវ សារឿន ឆ្លើយដាក់លោក តើលោកនៅចាំពីខែឆ្នាំដែលគេប្រាប់លោកអំពីការឆ្លើយដាក់នោះដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែគ្រាន់តែអាចតាមការប៉ាន់ប្រមាណ គឺអាចចុង៧៧ ហ្នឹងហើយ។

[១៥:៥៤:២៥]

**លោក ឌេល លីសាក់៖**

លោកប្រធាន ឥឡូវនេះខ្ញុំចង់បង្ហាញជូនសាក្សីនូវចម្លើយសារភាព ស-២១ ទៀត ដែលមាន ចំណារផ្ទាល់ដៃទាក់ទងទៅនឹងកងពល៨០១។ ឯកសារនេះ D43/4 ឧបសម្ព័ន្ធ២២ ចំណារនោះ គឺទាក់ ទងទៅនឹងកងពល៨០១ គឺនៅក្នុងទំព័រខ្មែរ 00173999, អង់គ្លេស ERN 00224628, បារាំង ERN 00271447។ សូមអនុញ្ញាតតុលាការឲ្យខ្ញុំបានបង្ហាញឯកសារនេះជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីជាថ្មីម្តងទៀត គឺផ្នែកឯកសារដែលខ្ញុំចង់ឲ្យលោកមើលនោះ គឺអក្សរផ្ទាល់ដៃ នៅក្របលើ ក្របនេះដែលជាចម្លើយសារភាពរបស់កម្មាភិបាល សួរ ទួន ហៅម៉ៅ ប៉ុន្តែមានសំណេរ

ផ្ទាល់របស់ ខៀវ ជូនទៅសមមិត្ត រឿន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧ នៅក្នុងនោះនិយាយថា

"១)ជូនសមមិត្ត រឿន សូមអានឯកសារអាម៉ៅ ហើយស្រង់ឈ្មោះតែកងពល៨០១។ ២)ស្អែកខ្ញុំជួបសមមិត្ត ដោយសារល្ងាចនេះ ខ្ញុំរវល់នៅឡើយ"។ បញ្ចប់សេចក្ដីដកស្រង់។

ឥឡូវនេះលោកបានប្រាប់ខ្ញុំអំពីឱកាសមួយដែល សារឿន ប្រាប់លោកថា ចម្លើយសារភាពពីរឆ្លើយដាក់លោក តើលោកនៅនឹកឃើញឱកាសណាផ្សេងទៀតទេ ដែល សារឿន និយាយអំពីចម្លើយសារភាពដែលគាត់បានទទួល ឬក៏មនុស្សផ្សេងទៀតដែលគេឆ្លើយដាក់មនុស្សនៅក្នុងកងពលរបស់លោកហ្នឹងដែរឬទេ?

**ឆ៖** តាមពិត គឺខ្ញុំបានជម្រាបហើយ គឺថាខ្ញុំក្ដាប់បានដែលគេឆ្លើយដាក់តែពីរហ្នឹងទេ ប៉ុន្តែក្រោយមកទៀត ខ្ញុំមិនដឹងជាខាងណាទៀត បើតាមខ្ញុំក្ដាប់បានគឺមានតែពីរហ្នឹងឯង។

**ស៖** តើលោកស្គាល់ ឬក៏ដឹងថា សារឿន ប្រាប់លោកថា តើវាអាចទៅម៉េចនឹងរួច ថាគាត់បានទទួលចម្លើយសារភាពនេះមកពីណា? ទទួលដោយរបៀបណា? ហើយតើគាត់ដឹងថា គេឆ្លើយដាក់

លោកហ្នឹង គាត់ដឹងដោយរបៀបណា?

[១៥:៥៨:០១]

**ឆ៖** បាទ ខ្ញុំមិនច្បាស់ទេ រឿងបញ្ហាគេឆ្លើយដាក់ហ្នឹង ប៉ុន្តែតាមរយៈហ្នឹង គឺរបៀបណាៗ គឺខ្ញុំមិនដឹង ប៉ុន្តែធម្មតាគឺគាត់ប្រាប់ខ្ញុំហើយ គឺថាមានគេឆ្លើយដាក់ហើយ គឺមាន កែវ សារឿន និង ស៊ន ហើយខ្ញុំយល់ច្បាស់ថា កែវ សារឿន ហើយនិង ស៊ន ហើយនិងខ្ញុំហ្នឹង គឺមនុស្សនៅជាមួយគ្នាបាទ។ ខ្ញុំយល់អ៊ីចេះឯង។ ដូច្នេះការដែលគាត់ប្រាប់ហ្នឹង គាត់មានឯកសារឆ្លើយ ឬក៏មិនរៀន បញ្ហានេះខ្ញុំក៏មិនច្បាស់ដែរ។ ប៉ុន្តែធម្មតាបើសិនណាជាមិនមាន ក៏មិនប៉ាននិយាយ បាទមិនប៉ាននិយាយទេ។ ពីព្រោះម្នាក់ៗ គឺត្រូវលាក់ការណ៍ដែលមិនស្រួល ខ្លាចរត់ទៅនេះទៅណោះអី វាខាត។ ហ្នឹងហើយវាបាត់។ ដឹងទៅគឺថាគេចាប់ទាំងខ្លួនឯងទៀត។ អ៊ីចឹងទេបានជាគាត់គ្រាន់តែប្រាប់ប៉ុណ្ណឹងទេ អត់ទេ មានគេឆ្លើយដាក់ហើយឥឡូវ ខំធ្វើការ អ៎! ខំ-- នៅកុំទៅណាឆ្វេចឆ្វាចអី។ ខ្ញុំដូចបាន ដែលអ្នកសង្កេតទៅពិនិត្យប្រាប់ទៅសួរខ្ញុំថា "អត់ទៅមានដើរទៅណាទេ។ នៅទាល់តែមានព្រឹត្តិការណ៍នេះបានរត់ព្រាតព្រោងតែម្ដង"។ ខ្ញុំចង់បញ្ជាក់អ៊ីចឹងទេ។ ដូច្នេះមិនមានជាឯកសារអីយមកបង្ហាញ ឬក៏ស្អីទេ គឺនិយាយជួបគ្នា គឺនិយាយទល់មុខគ្នាតែម្ដង។ គ្រាន់ឥឡូវមិនស្រួលទេ សភាពការណ៍ឥឡូវហើយ មានគេឆ្លើយដាក់ហើយ។ ហើយខ្លួនគាត់ផ្ទាល់ទៀត គឺថាមិនដឹងជាយ៉ាងណាទេ ពីព្រោះគាត់អ្នកស្គាល់គេច្រើនហើយ បើមានបាត់បង់គេ

អីណេះណោះ គាត់ក៏ភ័យខ្លាចដូចគ្នា។ ហើយក្នុងរយៈពេលនោះ មកជួបគ្នាក៏មិនសូវចេះញញឹមញញែម ដាក់គ្នាដែរ។ បាទ ខ្លាចអានេះគេចាប់ទៅ វាឆ្លើយដាក់អានោះ អានោះគេចាប់ ឆ្លើយដាក់អានេះអីចេះ។ ខ្ញុំពិបាកនិយាយ។

[១៦:០០:០៣]

**ស៖** តើមានពេលណាទេក្រោយមក ក្រោយពីលោកបានដឹងដំណឹងពីលេខាកងពល សារឿន ដែលថា គេឆ្លើយដាក់លោក ថាតើពេលក្រោយមកហ្នឹងមានអ្នកណាគេមកហៅលោកឲ្យមកភ្នំពេញដែរ ឬទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បញ្ហាហ្នឹង គឺពេលដែលខ្ញុំទៅនៅនោះបានប្រហែលជា១ខែ ២ខែ គ្រាន់តែទៅដល់ភ្លាម គឺបានជួបជាមួយ ស៊ូ សារឿន ដូចបានបញ្ជាក់ថា គាត់ប្រាប់អីចេះចុះ ហើយ ក៏ខ្ញុំនៅនោះ។ ពេលដែលប៉ុន្មានខែក្រោយមក សារទូរលេខហ្នឹងក៏ខូចទៅ ហើយតាមគាត់និយាយហើយ បានធ្វើទូរលេខហ្នឹងកើតហើយ ក៏យកសារហ្នឹង បកសារហ្នឹងមកឲ្យខ្ញុំប្រាប់ថា "ឥឡូវ ៨៧០ ឲ្យឯងទៅ ភ្នំពេញ ហើយទៅស្អែកនេះឯង!"។ ខ្ញុំក៏មកភ្នំពេញ អារម្មណ៍ចេះតែគិតហើយ បើថាភ្នំពេញមិនដឹងជា យ៉ាងណាយ៉ាងណីទេបាទ ចេះបារម្ភអីចឹង។ ពីព្រោះបានសេចក្តីថា បើ កែវ សារឿន គាត់ប្រាប់អីចឹង ឲ្យមកភ្នំពេញមានតែបញ្ហាដូច កែវ សារឿន ដូចគ្នា។ នេះគេប្រាប់ហើយអត់មាននេះទេ យកសារ ហើយ សារជាអក្សរយកមកឲ្យមើលតែម្តង ដាក់៨៧០។ ហើយឲ្យម្នាក់ឯងទេ មកដល់ស្ទឹងត្រែង យន្តហោះចាំទទួលទៅ។ ខ្ញុំស្អែកឡើងខ្ញុំចេញរឹងមក ដល់អីចឹងចូលមកដល់កួនមុំហ្នឹង ឃើញឡាន កូនឡានកងពលហ្នឹង ចេញមកហៅភ្លាមថា "ប្រញាប់ៗទៅវិញ! បងគាត់នៅចាំនៅកន្លែងផ្ទះខ្ញុំនៅ បឹងកន្សែងហ្នឹងឯង"។ ខ្ញុំក៏ទៅជួបគាត់ហ្នឹង "ថាឥឡូវសភាពការណ៍អត់ស្រួលទេ ឥឡូវមិនបាច់ទៅទេ។ នៅនេះហើយ ឥឡូវទៅចាត់ចែងខាងមុខ"។ ខ្ញុំទៅខាងក្រោយ ដើម្បីរៀបចំខាងក្រោយ។ បាទ និយាយ ទៅក៏បែកគ្នាទៅ ខ្ញុំក៏ទៅមុខបានប្រហែលជាកន្លះគីឡូ ក៏ព្រាតព្រោងបាត់ទៅហើយ អ៊ើ។ ជម្រាបប៉ុណ្ណឹង។

[១៦:០២:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញានិងសាក្សី។ បាទ ឥឡូវដំណើរការកិច្ចដំណើរការ សវនាការថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១០ ខែមករា ឆ្នាំ២០១៣

ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី អ៊ុង រ៉ែន បញ្ចប់ ហើយនិងមានត្រៀមបម្រុងទុកនូវសាក្សីដែលមានរហស្សនាម TCW-100។

លោក អ៊ុង រ៉ែន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មលោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

[១៦:០៣:៣៦]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ បង្គាប់ឲ្យអនុមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកត្រឹមបន្ទប់ឃុំខ្លួន នៅពីក្រោមសាលសវនាការដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*